សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale De Droit et des Sciences Économiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# នីតិវិធីបណ្តឹងលែងលះ

ស្រាវជ្រាវ ចាប់ពីថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០២៣ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០២៣

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ៖ **សាលី ឧត្តរិយ៉ា**
**សេង ឧនីនាថ**

ណែនាំដោយ
លោកជំទាវ **ចាំង ស៊ីណាត**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី២៣

ឆ្នាំចូលសិក្សា ២០១៩
ឆ្នាំសរសេរសារណា ២០២៣

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំទាំងពីរ ឈ្មោះ **សាលី ឧត្តរិយ៉ា** និងឈ្មោះ **សេង ជនីនាថ** ជានិស្សិតឆ្នាំទី៤ ជំនាន់ទី២៣ នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ផ្នែកនីតិសាស្រ្ត ឆ្នាំសិក្សា ២០១៩ ដល់ ឆ្នាំសិក្សា ២០២៣ ។ យើងខ្ញុំសូមថ្លែងអំណរគុណជូនចំពោះលោកឪពុក និងអ្នកម្តាយជាទីគោរពស្រលាញ់ដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សាកូនដោយក្តីមេត្តាករុណា និងផ្តល់ក្តីស្រលាញ់តាំងពីតូចរហូតធំពេញវ័យ ដោយរូបលោកបានលះបង់ទាំងកម្លាំងកាយ កម្លាំងចិត្ត និងថវិកា ដើម្បីអោយរូបកូនបានសិក្សារៀនសូត្រ ព្រមទាំងខិតខំអប់រំផ្តល់ដំបូន្មានប្រៀនប្រដៅអោយរូបកូនដើរផ្លូវល្អ មានសេចក្តីថ្លៃថ្នូរ និងស្មោះត្រង់ ដោយអោយកូនប្រតិបត្តិតែអំពើសុច្ចរឹតទៀងត្រង់ ព្រមទាំងបានជំរុញលើកទឹកចិត្តដល់រូបកូនក្នុងការសិក្សារៀនសូត្រ និងតម្រង់ទិសកូនអោយក្លាយជាពលរដ្ឋល្អក្នុងសង្គម។ ក្រោមការយកចិត្តទុកដាក់ កូនបានបញ្ចប់ថ្នាក់បរិញ្ញាបត្រដោយជោគជ័យ ហើយមានចំណេះដឹងខ្លះសម្រាប់ធ្វើជាទន់ក្នុងការរស់នៅ។

ទន្ទឹមនឹងនេះ យើងខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ **ឯកឧត្តម លុយ ចន្ធា សាកលវិទ្យាធិការ នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច** ដែលលោកជាអ្នកគ្រប់គ្រង ហើយលោកបានផ្តល់កន្លែងសិក្សាដល់យើងខ្ញុំទាំងពីរ បានសិក្សារហូតសម្រេចលទ្ធផលបង្កើតស្នាដៃនេះឡើង។

ជាពិសេស យើងខ្ញុំក៏សូមថ្លែងអំណរគុណដល់ **លោកជំទាវ ចាំង ស៊ីណាត** ដែលជាសាស្រ្តាចារ្យណែនាំយើងខ្ញុំ ក្នុងការសរសេរចងក្រងសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្រ្តនេះផងដែរ ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ដើម្បីធ្វើការបង្ហាត់បង្ហាញអស់ពីកម្លាំងចិត្ត កម្លាំងកាយ និងណែនាំកែតម្រូវផ្តល់នូវចំណេះដឹងយ៉ាងច្រើន ក៏ដូចជាផ្តល់ជាអានុសាសន៍ និងតម្រង់ទិសដៅអោយយើងខ្ញុំក្នុងការបង្កើតកិច្ចការស្រាវជ្រាវបានជោគជ័យ។

ម៉្យាងទៀត យើងខ្ញុំទាំងពីរសូមថ្លែងអំណរគុណ និងសម្តែងនូវការដឹងគុណចំពោះលោកគ្រូ អ្នកគ្រូ សាស្រ្តាចារ្យទាំងអស់ដែលបានខិតខំបង្ហាត់បង្រៀនអស់ពីកម្លាំងកាយកម្លាំងចិត្ត និងផ្តល់ចំណេះដឹងយ៉ាងច្រើន និងពិតប្រាកដដល់យើងខ្ញុំទាំងពីរអោយឈានដល់ការបង្កើតស្នាដៃនេះឡើង។ មួយវិញទៀតសូមថ្លែងអំណរគុណដល់បងប្អូនសិស្សច្បងមិត្តភក្តិទាំងអស់ដែលបានជួយជ្រោមជ្រែង លើកទឹកចិត្ត និងការផ្តល់មតិយោបលល្អៗជាច្រើន និងការចែករំលែកបទពិសោធន៍ល្អៗ។

ជាទីបញ្ចប់ យើងខ្ញុំ សូមបួងសួងដល់វត្ថុស័ក្តសិទ្ធិទាំងអស់ក្នុងលោក ជួយថែរក្សាការពារ និងប្រសិទ្ធពរជ័យជូនដល់អស់លោកទាំងអស់ ជួបតែសេចក្តីសុខសេចក្តីចម្រើន សុខភាពល្អ អាយុយឺនយូរ និងទទួលបានជោគជ័យគ្រប់ភារៈកិច្ចនិងជួបតែពុទ្ធិពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

នៅក្នុងអំឡុងពេល ៤ ឆ្នាំ ដែលយើងខ្ញុំបានសិក្សាថ្នាក់បរិញ្ញាបត្រកន្លងមកនេះ យើងខ្ញុំបានសិក្សាលើមុខវិជ្ជាជាច្រើន រួមបញ្ចូលទាំងផ្នែកនីតិឯកជន និងនីតិសាធារណៈ ដែលបានធ្វើឲ្យយើងខ្ញុំទទួលបាននូវចំណេះដឹងបន្ថែមទូលំទូលាយលើមុខវិជ្ជាទាំងអស់នោះ ក្រោមការប្រឹងប្រែងបង្ហាត់បង្រៀនដោយយកចិត្តទុកដាក់ពីសំណាក់លោកគ្រូ អ្នកគ្រូ ជាសាស្ត្រាចារ្យទាំងអស់។

តាមរយៈការខិតខំជ្រោមជ្រែងនេះ យើងខ្ញុំអាចចងក្រងនូវសារណាការពារបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រនេះ ដែលមានប្រធានបទមួយ ក្រោមចំណងជើងថា "នីតិវិធីបណ្តឹងលែងលះ" ។ ការជ្រើសរើសប្រធានបទនេះ គឺធ្វើឡើងក្នុងគោលបំណងពង្រីកនូវការយល់ដឹងរបស់សាធារណៈជនជាពិសេសអ្នកសិក្សាច្បាប់ជាអ្នកអាន អំពីការបង្កើតចំណងអាពាហ៍ពិពាហ៍ សិទ្ធិនិងករណីយកិច្ចទាំងឡាយដែលកើតចេញពីចំណងអាពាហ៍ពិពាហ៍ ការលែងលះ នីតិវិធីនៃការលែងលះ ការផ្សះផ្សា និងអានុភាពនៃការលែងលះទៅលើបុគ្គលពាក់ព័ន្ធ ។

យើងខ្ញុំសង្ឃឹមថា សារណានេះនឹងអាចជាជំនួយការសិក្សាស្រាវជ្រាវរបស់សិស្សនិស្សិតនិងប្រជាពលរដ្ឋខ្មែរគ្រប់រូបដែលចង់ស្វែងយល់បន្ថែមទាក់ទងនឹងអាពាហ៍ពិពាហ៍ និងការលែងលះដែលបានកំណត់ក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ហើយនឹងទុកស្នាដៃសម្រាប់អ្នកសិក្សាជំនាន់ក្រោយ ដើម្បីសិក្សាបន្ថែមអោយកាន់តែច្បាស់អំពីនីតិវិធី ក្នុងការរៀបអាពាហ៍ពិពាហ៍ និងការលែងលះ ក្នុងព្រះរាជាណាចក្រកម្ពុជា។

យើងខ្ញុំសូមអភ័យទោសទុកជាមុននូវរាល់ការចំណុចខ្វះខាតមួយចំនួនដូចជាពាក្យពេចន៍ខ្លឹមសារអត្ថន័យឬអក្ខរាវិរុទ្ធទាំងឡាយដែលមាននៅក្នុងកិច្ចការស្រាវជ្រាវមួយនេះដោយអចេតនា។

# សេចក្ដីផ្ដើម

# សេចក្ដីផ្ដើម

នៅក្នុងសង្គមនាអតីតកាល និងនាពេលបច្ចុប្បន្ន មនុស្សប្រុសនិងស្រីតែងតែចាប់ដៃគ្នាបង្កើតនូវក្រុមគ្រួសារមួយជាមួយគ្នា ចំណងនេះត្រូវបានទទួលស្គាល់ដោយមនុស្សនៅជុំវិញខ្លួនអ្នកទាំងពីរនោះគឺជាការរៀបអាពាហ៍ពិពាហ៍ក្លាយទៅជាប្ដីប្រពន្ធ។ ការចាប់ដៃគ្នាបង្កើតនូវចំណងអាពាហ៍ពិពាហ៍កើតឡើងដោយឆន្ទៈព្រមព្រៀងរវាងអ្នកទាំងពីរ និងការស្រឡាញ់គ្នារបស់អ្នកទាំងពីរតែប៉ុណ្ណោះ។

នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលជាប្រទេសដែលមានវប្បធម៌និងប្រពៃណីជាយូរអង្វែងមកហើយ យើងអាចសង្កេតទៅមើលការប្រារព្ធពិធីអាពាហ៍ពិពាហ៍នាពេលបច្ចុប្បន្ននៅតែធ្វើឡើងតាមបែបប្រពៃណីដដែល ដែលជាមូលហេតុដែលប្រជាជនកម្ពុជាមួយចំនួនរស់នៅជាមួយគ្នាជាអនីតិសង្វាស ដោយមិនទៅចុះសំបុត្រអាពាហ៍ពិពាហ៍នោះឡើយ ដោយគិតថា ការរៀបអាពាហ៍ពិពាហ៍បែបប្រពៃណីនេះគ្រប់គ្រាន់ទៅហើយ ។ ផ្ទុយទៅវិញ ច្បាប់ទទួលស្គាល់និងការពារតែប្ដីប្រពន្ធដែលបានចុះសំបុត្រអាពាហ៍ពិពាហ៍ជាមួយគ្នាតាមលក្ខខណ្ឌទម្រង់ ត្រឹមត្រូវដែលច្បាប់បានកំណត់ប៉ុណ្ណោះ ។ ទន្ទឹមនឹងនេះដែរ ប្ដីប្រពន្ធដែលបានរស់នៅជាមួយគ្នារយៈពេលយូរអាចតែងតែមានជម្លោះជាមួយគ្នា និងមានបំណងចង់ផ្ដាច់នូវចំណងអាពាហ៍ពិពាហ៍រវាងអ្នកទាំងពីរ ដោយផ្អែកលើមូលហេតុមួយចំនួនដែលបានកំណត់នៅក្នុងច្បាប់ដូចជាការរស់នៅមិនចុះសម្រុងពីគ្នាជាដើម ។ ការផ្ដាច់នូវចំណងនេះ នាំមកនូវការប៉ះពាល់ជាច្រើនដល់សាមីភាគី និងអ្នកនៅជុំវិញខ្លួន ជាពិសេសគឺកូនរបស់អ្នកទាំងពីរ។

បន្ថែមពីលើនេះ ការលែងលះគ្នារវាងប្ដីប្រពន្ធមួយគូត្រូវធ្វើឡើងតាមនីតិវិធីដែលស្មុគស្មាញតាមផ្លូវតុលាការផងដែរ ដែលក្នុងនោះតុលាការនឹងខិតខំប្រឹងប្រែងផ្សះផ្សានូវចំណងអាពាហ៍ពិពាហ៍របស់អ្នកទាំងពីរយ៉ាងអស់ពីលទ្ធភាពទាំងស្រុងមុននឹងសម្រេចផងដែរ។

អាស្រ័យហេតុនេះ ទើបក្រុមយើងខ្ញុំលើកយកប្រធានបទទាក់ទងនឹង "នីតិវិធីបណ្ដឹងលែងលះ" មកបកស្រាយ ដើម្បីជួយជាជំនួយក្នុងការអនុវត្តមួយចំនួន និងជាការរំលែកនូវចំណេះដឹងដល់មហាជនទាំងអស់ស្វែងយល់កាន់តែច្បាស់។ ប្រធានបទនេះ ត្រូវស្ថិតក្រោមច្បាប់គ្រប់គ្រងមួយចំនួន មានដូចជា រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦ អនុក្រឹត្យស្ដីពីអត្រានុកូលដ្ឋាន ច្បាប់ស្ដីពីឯកពន្ធភាព ឆ្នាំ ២០០៦ ច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល និងច្បាប់ស្ដីពីនីតិវិធីរឿងក្ដីរដ្ឋប្បវេណីមិនមែនបណ្ដឹង។

ប្រធានបទនេះមានសារៈសំខាន់ ដើម្បីសិក្សានុសិស្ស ក៏ដូចជាមហាជនទាំងអស់បានយល់អំពីនីតិវិធីបណ្ដឹងនេះ ដែលជាបណ្ដឹងមានលក្ខណៈស្មុគស្មាញជាងនីតិវិធីបណ្ដឹងរដ្ឋប្បវេណីធម្មតា ដោយបណ្ដឹងលែងលះជាបណ្ដឹងដែលទាក់ទងនឹងឋានៈបុគ្គល និងអាចពាក់ព័ន្ធជាមួយនឹងច្បាប់ជាច្រើន ក្នុងករណីដែល

មានកម្មវត្ថុបែងចែកទ្រព្យសម្បត្តិនិងបំណុល ការកំណត់អ្នកមានអំណាចមេបាលើកូន សិទ្ធិចូលជាប្រាស្រ័យទាក់ទង អាហារកាតព្វកិច្ច សោហ៊ុយចិញ្ចឹមបីបាច់កូន ។ល។ នៅក្នុងសារណានេះ អ្នកអានក៏អាចយល់ដឹងអំពីនីតិវិធីក្នុងការចុះសំបុត្រអាពាហ៍ពិពាហ៍ និងអានុភាពនៃអាពាហ៍ពិពាហ៍ផងដែរ។

ការចងក្រងសារណានេះ ក៏ជាការចូលរួមចំណែកមួយក្នុងការអភិវឌ្ឍនូវប្រព័ន្ធច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីឆ្ពោះទៅរកការរីកចម្រើនផងដែរ។

# ជំពូកទី ១
# អាពាហ៍ពិពាហ៍

# ជំពូកទី ១
# អាពាហ៍ពិពាហ៍

អាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាមួយធ្វើឡើងដោយបុរសម្នាក់និងស្ត្រីម្នាក់យ៉ាងឱឡារិក ដើម្បីបង្កើតនូវចំណងនីតិសង្វាសដោយការបង្ហាញឆន្ទៈយល់ព្រមដោយគូភាគី និងធ្វើឡើងស្របតាមនីតិវិធីដែលប្រទេសនីមួយៗ បានកំណត់ ។ ហើយចំណងអាពាហ៍ពិពាហ៍មិនអាចរំលាយទៅវិញបានតាមទំនើងចិត្តរបស់ខ្លួនឡើយ។

អាពាហ៍ពិពាហ៍នឹងមានអានុភាព កាលណាដែលសាមីខ្លួនទាំងពីរបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និងការចុះបញ្ជី អាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន។ ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹង ជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និងការចុះបញ្ជីអាពាហ៍ពិពាហ៍ ត្រូវធ្វើឡើងស្របតាមនីតិវិធីដែលកំណត់ដោយបទប្បញ្ញត្តិស្តីពីការចុះបញ្ជីអត្រានុកូលដ្ឋាន។

គប្បីចំណាំថា ការរៀបអាពាហ៍តាមបែបប្រពៃណី មិនមែនជាការរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់នោះទេ ។

## ១. អាពាហ៍ពិពាហ៍

### ១.១ លក្ខខណ្ឌនៃអាពាហ៍ពិពាហ៍

ដើម្បីចុះបញ្ជីអាពាហ៍ពិពាហ៍ សាមីខ្លួននីមួយៗ ត្រូវបំពេញនូវលក្ខខណ្ឌមួយចំនួនដែលកំណត់ដោយច្បាប់ ក្នុងគោលបំណងការពារនូវផលប្រយោជន៍របស់គូភាគីក្នុងចំណងនេះ ។ លក្ខខណ្ឌទាំងនោះ រួមមាន៖

#### ១.១.១ លក្ខខណ្ឌអាយុ ឬនីតិភាព៖

បុរស និងនារី ត្រូវមានអាយុ ១៨ ឆ្នាំ ដើម្បីរៀបអាពាហ៍ពិពាហ៍ ។ ក៏ប៉ុន្តែ ចំពោះនារីអាចរៀបអាពាហ៍ពិពាហ៍ បានក្នុងអាយុ ១៦ ឆ្នាំ កាលបើមានការយល់ព្រមពីអ្នកដែលមានអំណាចមេបា ឬអាណាព្យាបាលរបស់នាង។ ក្នុងករណីដែលមានអាណាព្យាបាលនៃអនីតិជននោះ មិនយល់ព្រម

អាពាហ៍ពិពាហ៍នេះនៅតែអាចប្រព្រឹត្តទៅបានក្នុងករណីដែលអាណាព្យាបាលម្ខាងទៀតយល់ព្រមចំពោះការរៀបអាពាហ៍ពិពាហ៍នេះ។[1]

ផ្ទុយទៅវិញ ក្នុងករណីដែលអាណាព្យាបាលទាំងពីរពុំយល់ព្រមនឹងការរៀបអាពាហ៍ពិពាហ៍របស់អនីតិជន នោះអនីតិជនអាចស្នើសុំឱ្យតុលាការចេញនូវសេចក្តីសម្រេចជំនួសការយល់ព្រមនេះ។ ការស្នើសុំនេះ ត្រូវបានធ្វើឡើងតាមរយៈប្បញ្ញត្តិស្តីពីអត្តាធីនភាព។ ក្រោយពេលដែលអនីតិជនបានរៀបអាពាហ៍ពិពាហ៍រួច អនីតិជននឹងក្លាយជានីតិជន ទោះបីជាលែងលះក៏ដោយ ក៏បុគ្គលនោះនៅតែត្រូវបានចាត់ទុកជានីតិជនដែរ។[2]

**ជាឧទាហរណ៍៖**

លីហ្សា មានវ័យ ១៦ ឆ្នាំ បានរៀបអាពាហ៍ពិពាហ៍ជាមួយ កក្កដា ដោយ ទទួលបានការយល់ព្រមពីអាណាព្យាបាលទាំងសងខាង។ ជាអកុសល តែ ១ ឆ្នាំក្រោយ កក្កដា បានបាត់ បង់ជីវិតក្នុងឧប្បត្តិហេតុមួយ ។ ទោះបីជា លីហ្សា នៅមានវ័យ ១៧ ឆ្នាំ ក៏ដោយ ក៏នាងត្រូវបានចាត់ទុកថា នាងបានទទួលនីតិភាពនិងអាចរៀបអាពាហ៍ពិពាហ៍ថ្មី ដោយពុំចាំបាច់ទទួលការយល់ព្រមពីអាណាព្យាបាលរបស់នាងទៀតឡើយ។

### ១.១.២ លក្ខខណ្ឌសមត្ថភាព៖

គូភាគីនៅក្នុងចំណងអាពាហ៍ពិពាហ៍ជាចាំបាច់ត្រូវមានសមត្ថភាពបង្ហាញឆន្ទៈ។

ចំពោះជននៅក្រោមអាណាព្យាបាលទូទៅ ដែលជាជនស្ថិតនៅក្នុងស្ថានភាពជានិរន្តរ៍ដែលខ្វះសមត្ថភាពក្នុងការយល់ដឹងនិងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់ នៃសកម្មភាពរបស់ខ្លួនដោយមូលហេតុ វិបត្តិផ្នែកបញ្ញាស្មារតី អាចរៀបអាពាហ៍ពិពាហ៍បាន ក្នុងករណីដែលជននោះបានបង្ហាញនូវឆន្ទៈយល់ព្រម ក្នុងកម្រិតអប្បបរមា។ ក្នុងករណីបែបនេះ ជននៅក្រោមអាណាព្យាបាលនោះ មិនចាំបាច់តម្រូវឱ្យមានការយល់ព្រមពីអាណាព្យាបាលឡើយ។

រីឯចំពោះជនដែលនៅក្រោមហិតូបត្ថម្ភ ដែលជាបុគ្គលមានសមត្ថភាពតិចតួចក្នុងការយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់ នៃសកម្មភាពរបស់ខ្លួន ដោយមូលហេតុវិបត្តិផ្នែកបញ្ញាស្មារតី អាចរៀប អាពាហ៍ពិពាហ៍ដោយពុំចាំបាច់ទទួលបានយល់ព្រមពីហិតូបត្ថម្ភកៈនោះទេ។

[1] មាត្រា ៩៤៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[2] មាត្រា ៩៥៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

### ១.១.៣ លក្ខខណ្ឌឯកពន្ធភាព៖

បុរសនិងនារីត្រូវនៅលីវមុនពេលចុះសំបុត្រអាពាហ៍ពិពាហ៍ ដោយច្បាប់ស្តីពីឯកពន្ធភាពនៃព្រះរាជាណាចក្រកម្ពុជា បានហាមឃាត់ពុំឱ្យមានទ្វេពន្ធភាពឡើយ។ បានន័យថា បុគ្គលដែលមានសហព័ទ្ធរួច ពុំអាចរៀបអាពាហ៍ពិពាហ៍បានទៀតឡើយ លើកលែងតែចំណងអាពាហ៍ពិពាហ៍មុនត្រូវបានរំលាយ។[3]

ចំពោះការបំពានលក្ខខណ្ឌនេះ អាចត្រូវបានចាត់ទុកជាបទល្មើសព្រហ្មទណ្ឌដែល មានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤ និងមាត្រា ៩ នៃច្បាប់ស្តីពីឯកពន្ធភាព (ឆ្នាំ២០០៦) ទោសដាក់ពន្ធនាគារពី ៦ ខែ ទៅ ១ ឆ្នាំ និង/ឬ ពិន័យជាប្រាក់ពី ២០០.០០០ រៀល ទៅ ២.០០០.០០០ រៀល។

### ១.១.៤ លក្ខខណ្ឌព្រមព្រៀង

អាពាហ៍ពិពាហ៍ត្រូវបានធ្វើឡើងដោយពុំមានការបង្ខំ ការគំរាម ការឆបោក ឬការភាន់ច្រឡំលើបុគ្គលឡើយ ។ ទោះបីជាក្រមរដ្ឋប្បវេណីពុំបានឱ្យនិយមន័យទៅលើពាក្យទាំងនេះក៏ដោយ ក៏យើងអាចកំណត់និយមន័យចំពោះពាក្យទាំងនេះតាមន័យសាមញ្ញ ដូចតទៅ៖

- ការបង្ខំ សំដៅលើការដែលភាគីណាម្នាក់ក្នុងអាពាហ៍ពិពាហ៍បានរៀបអាពាហ៍ពិពាហ៍ដោយពុំមានសេរីភាព និងពុំស្របតាមឆន្ទៈរបស់ខ្លួន។
- ឆបោក៖ ក្រមព្រហ្មទណ្ឌបានឱ្យនិយមន័យពាក្យនេះថា គឺជាអំពើបន្លំចំពោះរូបវន្តបុគ្គល ឬ នីតិបុគ្គលណាមួយ ដោយប្រើឈ្មោះក្លែង ដោយអះអាងទៅលើឋានៈក្លែង ដោយរំលោភលើឋានៈពិត ប្រាកដ ឬដោយប្រើឧបាយកលទុច្ចរិត ជាហេតុដែលនាំឱ្យខូចប្រយោជន៍របស់បុគ្គល ឬរបស់តតិយជននូវ ៖
    - ការប្រគល់មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយ ។
    - ការផ្តត់ផ្គង់សេវា ។
    - ការធ្វើលិខិតដែលមានតម្លៃជាកាតព្វកិច្ច ឬជាការឱ្យរួចពីកាតព្វកិច្ច ។

ក៏ប៉ុន្តែ ក្នុងករណីនេះ ការបន្លំសំដៅលើ៖

- ការគំរាម៖ ត្រូវបានឱ្យនិយមន័យតាមវចនានុក្រមសម្តេច ជួន ណាត ថា៖ (ក) កំហែង។ ក៏ប៉ុន្តែ ជាន័យសាមញ្ញអាចសំដៅទៅលើកិរិយាដែលធ្វើឱ្យបុគ្គលណាមួយភ័យខ្លាចតាមពាក្យសំដីឬកាយវិការ ។
- ការភាន់ច្រឡំ សំដៅលើការច្រឡំលើមនុស្ស ឬអត្តសញ្ញាណបុគ្គល ជាឧទាហរណ៍ ការភាន់ច្រឡំកូនភ្លោះ ជាដើម។

[3] មាត្រា ៩៤៩ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

### ១.១.៥ លក្ខខណ្ឌទម្រង់នៃអាពាហ៍ពិពាហ៍[4]

ការរៀបអាពាហ៍ពិពាហ៍ធ្វើឡើងមាន ៤ ប្រភេទ គឺៈ

- ការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ នៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស នៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ការរៀបអាពាហ៍ពិពាហ៍រវាងជនបរទេស និងជនបរទេស ដែលរស់នៅស្របច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ ឬពលរដ្ឋខ្មែរ និងជនបរទេស ដែលកំពុងរស់នៅស្របច្បាប់នៅឯបរទេស។

ចំណុចនេះ នឹងផ្តោតសំខាន់ទៅលើអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរដែលមាននីតិវិធីដូចតទៅៈ

#### ១.១.៥.១ ការដាក់ពាក្យសុំ

ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍នេះ ត្រូវធ្វើឡើងឃុំសង្កាត់នៃលំនៅឋានរបស់សាមីខ្លួនខាងនារី និងត្រូវដាក់នៅមន្ត្រីអត្រានុកូលដ្ឋានឃុំសង្កាត់។ ពាក្យសុំនេះត្រូវភ្ជាប់ជាមួយនូវៈ

- សេចក្តីចម្លងសំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើត
- លិខិតបញ្ជាក់ភាពនៅលីវ ឬ មេម៉ាយ ឬ ពោះម៉ាយ របស់សាមីខ្លួនទាំងពីរនាក់ ដោយលិខិតនេះត្រូវចេញដោយមេឃុំ ចៅសង្កាត់នៃសាមីខ្លួននីមួយៗ។ (ចំពោះបុគ្គលដែលមេម៉ាយ ឬពោះម៉ាយដោយការលែងលះ ចាំបាច់ត្រូវភ្ជាប់នូវសាលក្រមតុលាការជាមួយនឹងពាក្យសុំរៀបអាពាហ៍ពិពាហ៍។)
- សៀវភៅគ្រួសារ។

#### ១.១.៥.២ បណ្ណប្រកាសជាសាធារណៈ

នៅពេលដែលមន្ត្រីអត្រានុកូលដ្ឋាន បានពិនិត្យឃើញថា ពាក្យសុំនេះមានលក្ខណៈត្រឹមត្រូវតាមលក្ខខណ្ឌនៃក្រមរដ្ឋប្បវេណី និងបទប្បញ្ញត្តិទាក់ទងនឹងអត្រានុកូលដ្ឋានរួច មន្ត្រីអត្រានុកូលដ្ឋានត្រូវចេញប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ជាសាធារណៈចំនួន ៥ ច្បាប់ ដើម្បីបិទផ្សាយតាមកន្លែងដូចតទៅៈ

[4] មាត្រា ៩៥៥ នៃក្រមរដ្ឋប្បវេណី

- ១ ច្បាប់ បិទផ្សាយជាសាធារណៈ នៅលំនៅឋានសាមីខ្លួននារី
- ១ ច្បាប់ បិទផ្សាយជាសាធារណៈ នៅសាលាឃុំ ឬសង្កាត់សាមីខ្លួននារី
- ១ ច្បាប់ រក្សាទុកជាឯកសារនៅសាលាឃុំ ឬសង្កាត់សាមីខ្លួននារី
- ០២ ច្បាប់ទៀត ត្រូវបានផ្ញើជូនទៅមន្ត្រីអត្រានុកូលដ្ឋានខាងបុរស ដើម្បី បិទផ្សាយជាសាធារណៈ នៅលំនៅឋានសាមីខ្លួនបុរស និងនៅសាលាឃុំ ឬសង្កាត់សាមីខ្លួនបុរស។

ប័ណ្ណនេះត្រូវបិទផ្សាយជាសាធារណៈក្នុងរយៈពេល ១០ ថ្ងៃ មុនថ្ងៃរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី ឬថ្ងៃចុះបញ្ជីអាពាហ៍ពិពាហ៍ ដើម្បីឱ្យជនដែលមានប្រយោជន៍ក្នុងរឿងនោះ អាចប្តឹងជំទាស់បានក្នុងករណី មិនយល់ស្របនឹងអាពាហ៍ពិពាហ៍នេះ។ នៅក្នុងប័ណ្ណប្រកាសអាពាហ៍ពិពាហ៍មន្ត្រីអត្រានុកូលដ្ឋានត្រូវសរសេរខ្លឹមសារដូចជា នាមត្រកូលនិងនាមខ្លួន សញ្ជាតិ ថ្ងៃខែឆ្នាំកំណើត មុខរបរ និងទីលំនៅបច្ចុប្បន្ននៃអនាគតប្តីឬប្រពន្ធ និងនាមត្រកូលនិងនាមខ្លួន ថ្ងៃខែឆ្នាំកំណើត មុខរបរ និងទីលំនៅបច្ចុប្បន្ន របស់ឪពុកម្តាយ នៃអនាគតប្តីឬប្រពន្ធ ក្នុងករណី ឪពុក ឬ ម្តាយ បានទទួលមរណភាព ត្រូវបញ្ជាក់ថា ស្លាប់។ ក្រោយពេលរយៈពេល ១០ ថ្ងៃ នេះ បានកន្លងផុតទៅ ហើយពុំមានអ្នកណាមួយប្តឹងជំទាស់ នឹងអាពាហ៍ពិពាហ៍នេះ នោះសាមីខ្លួនទាំងពីរអាចរៀបអាពាហ៍ពិពាហ៍ និងចុះសំបុត្រអាពាហ៍ពិពាហ៍បាន។

ក្នុងករណីមានការប្តឹងជំទាស់អាពាហ៍ពិពាហ៍អាចធ្វើទៅបានលុះត្រាតែ បណ្តឹងជំទាស់អាពាហ៍ពិពាហ៍បានដោះស្រាយរួចរាល់ជាមុនសិន ដោយយោងតាមច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារបានបញ្ញត្តិ។

អាពាហ៍ពិពាហ៍នឹងអាចចាត់ទុកជាត្រឹមត្រូវតាមតាមលក្ខណៈច្បាប់បាន លុះត្រាតែបុរស និងនារីដែលស្ម័គ្រចិត្តយកគ្នាជាប្តីប្រពន្ធចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ខាងលំនៅរបស់នារី ។ កិច្ចសន្យាត្រូវចុះក្នុងបញ្ជីអាពាហ៍ពិពាហ៍ ហើយត្រូវចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋាន ប្តីប្រពន្ធ និងសាក្សីជានីតិជនចំនួនពីរនាក់ ។

### ១.១.៥.៣ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និងការចេញសំបុត្រអាពាហ៍ពិពាហ៍

កិច្ចសន្យាអាពាហ៍ពិពាហ៍ ត្រូវចុះក្នុងសៀវភៅអាពាហ៍ពិពាហ៍ ដោយតម្រូវឱ្យមានការចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋាន ផ្តិតស្នាមមេដៃរបស់ប្តីប្រពន្ធ និងសាក្សីមានអាយុលើស ១៨ ឆ្នាំ ចំនួន ២ នាក់ ។ មន្ត្រីអត្រានុកូលដ្ឋាន នឹងប្រគល់ឱ្យសាក្សីនូវសំបុត្រអាពាហ៍ពិពាហ៍ច្បាប់ដើមចំនួន ១ សន្លឹក និងចេញសេចក្តីចម្លង តាមការស្នើសុំរបស់ខ្លួន។

សំបុត្រអាពាហ៍ពិពាហ៍នេះ ត្រូវបានចេញជូនដល់សាមីទាំងពីរក្រោយពេលដែលសាមីទាំងពីរបាន ចុះកិច្ចសន្យាអាពាហ៍ពិពាហ៍នេះរួចរាល់។

ម្យ៉ាងវិញទៀត អាពាហ៍ពិពាហ៍ដែលនឹងមានអានុភាពពេញលក្ខណៈច្បាប់បានលុះត្រាតែ សាមីខ្លួនបុរស និងនារីបានទៅចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ ដោយផ្ទាល់នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ដោយនាំមកនូវសាក្សីដែលជានីតិជនចំនួន ០២ រូបផង ដែលស្របទៅតាមទម្រង់បែបបទ និងនីតិវិធីនៃការងារអត្រានុកូលដ្ឋាន។

## ១.២ ករណីដែលច្បាប់បានហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍

ក្រមរដ្ឋប្បវេណីបានបញ្ញត្តិអំពីលក្ខខណ្ឌក្នុងការអនុញ្ញាតឱ្យរៀបអាពាហ៍ពិពាហ៍ ហើយក៏បានបញ្ញត្តិអំពីករណីមួយចំនួនដែលពុំអនុញ្ញាតឱ្យរៀបអាពាហ៍ពិពាហ៍ផងដែរ ។

### ១.២.១ ទំនាក់ទំនងញាតិ

ញាតិ តាមវចនានុក្រម ត្រូវបានឱ្យនិយមន័យថា ជាអ្នកដែលរួមខ្សែលោហិតនឹងគ្នាខាងមាតាឬខាងបិតា; ដែលហៅថា ញាតិ ៧ សន្តាន ឬញាតិ ៧ ជួរ នោះ តាមន័យក្នុងគម្ពីរពុទ្ធសាសនាលោកឱ្យរាប់ថ្នាក់ខាងលើ ៣ ជាន់ គឺថ្នាក់មាតាបិតា ១,ថ្នាក់ជីដូនជីតា ១, ថ្នាក់យាយទួតតាទួត ១; ថ្នាក់ខាងក្រោមខ្លួន ៣ ជាន់ទៀត គឺថ្នាក់កូន ១, ថ្នាក់ចៅ ១,ថ្នាក់ចៅទួត ១ រួមជា ៦ ថ្នាក់, ជា ៧ ថ្នាក់នឹងខ្លួនយើង; មនុស្សទាំងអស់នោះ ហៅថា ញាតិ ៧ សន្តាន ។

រីឯតាមន័យដែលបានកំណត់ក្នុងក្រមរដ្ឋប្បវេណី បានឱ្យនិយមន័យថា ជាអ្នកដែលកើតចេញមកពីត្រកូលតែមួយ ហៅថា ញាតិ ហើយទំហំនៃញាតិនេះ ត្រូវបានកំណត់ដោយក្រមរដ្ឋប្បវេណី ត្រង់មាត្រា ៩៣៨ ថា បុគ្គលដែលជាញាតិមានញាតិលោហិតក្នុង ៦ ថ្នាក់ សហព័ទ្ធ និងញាតិពន្ធក្នុង ៣ ថ្នាក់។ ។

អាពាហ៍ពិពាហ៍រវាងញាតិលោហិត និងញាតិពន្ធត្រូវបានហាមឃាត់ដោយច្បាប់។

ញាតិលោហិត សំដៅដល់បុគ្គលដែលកើតចេញពីតំណពូជតាមលក្ខណៈធម្មជាតិ ពីបុគ្គលម្នាក់ទៀត។ ញាតិលោហិត ត្រូវបានបែងចែកជាពីរ គឺញាតិលោហិតខ្សែផ្ទាល់ និងសាខាញាតិ។ ញាតិលោហិតខ្សែផ្ទាល់ ជាញាតិដែលមានឈាមជ័រតែមួយ ហើយកើតតគ្នាពីមួយទៅមួយតាមលំដាប់។ ទំនាក់ទនងញាតិនេះ រួមបញ្ចូលទាំងញាតិដែលកើតឡើងតាមរយៈការសុំកូនផងដែរ ដោយហេតុថាសុំកូន ជាការបង្កើតនូវទំនាក់ទំនងញាតិភាពរវាងឪពុកម្តាយចិញ្ចឹម និងកូនសុំ រួមទាំងញាតិលោហិតរបស់ឪពុកម្តាយចិញ្ចឹម។ ចំពោះការហាមឃាត់អាពាហ៍ពិពាហ៍រវាងញាតិលោហិតនេះ គឺហាមឃាត់ចំពោះញាតិលោហិតផ្ទាល់

ចំនួនបីថ្នាក់ ។ ញាតិលោហិតទាំងបីថ្នាក់នេះ រួមមាន ឪពុក ម្ដាយ កូន (ថ្នាក់ទី១) បងប្អូនបង្កើត (ថ្នាក់ទី២) និង ពូ មីង ក្មួយ (ថ្នាក់ទី៣)។ [5]

ញាតិពន្ធ គឺជាចំណងគតិយុត្តរវាងសហព័ទ្ធម្ខាង និងញាតិលោហិតរបស់សហព័ទ្ធម្ខាងទៀត ដែលភាសាសាមញ្ញហៅថា សាច់ថ្លៃ។ ចំពោះការហាមឃាត់អាពាហ៍ពិពាហ៍រវាងញាតិពន្ធនេះ គឺហាមឃាត់ចំពោះញាតិលោហិតផ្ទាល់ សំដៅលើញាតិដែលមានឈាមជាមួយគ្នា ចំនួនបីថ្នាក់ [6]។

ឧទាហរណ៍ ចំពោះការហាមឃាត់អាពាហ៍ពិពាហ៍រវាងញាតិលោហិតនេះ៖ អាពាហ៍ពិពាហ៍រវាងឪពុកឬម្ដាយ ជាមួយនឹងកូនសុំពេញលេញ ឬកូនសុំធម្មតា ត្រូវបានហាមឃាត់ទោះបីជាមានការកាត់កាលសុំកូនពេញលេញឬសុំកូនធម្មតា។

ឧទាហរណ៍ ចំពោះការហាមឃាត់អាពាហ៍ពិពាហ៍រវាងញាតិពន្ធ៖ មករា ត្រូវបានចិញ្ចឹមបីបាច់ដោយ សីហា ដែលជាឪពុកចិញ្ចឹម ដែលបានសុំកូនធម្មតា ដើម្បីទទួលស្គាល់មករាជាកូន។ ក្រោយពេលដែល មករា បានទទួលនីតិភាព មករា បានរៀបអាពាហ៍ពិពាហ៍ជាមួយនឹង មីនា ។ ក្នុងករណីដែល មករា និង មីនា បានលែងលះគ្នាចប់ជាស្ថាពរ ក៏ សីហា ពុំអាចរៀបអាពាហ៍ពិពាហ៍ជាមួយនឹង មីនា បានឡើយ។

### ១.២.២ ទ្វេពន្ធភាព

ច្បាប់នៃព្រះរាជាណាចក្រកម្ពុជាបានហាមឃាត់យ៉ាងដាច់ខាតចំពោះទ្វេពន្ធភាព ដោយបុរសម្នាក់អាចយកប្រពន្ធមួយតែប៉ុណ្ណោះ ហើយស្ត្រីម្នាក់អាចយកប្ដីតែមួយទេ។[7] ក្រៅពីបញ្ញត្តិនៅក្នុងក្រមរដ្ឋប្បវេណីអំពីការហាមឃាត់នេះ រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាបានអនុម័តច្បាប់ស្ដីពីឯកពន្ធភាព នៅថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០០៦ ក្នុងគោលបំណងការពារសេចក្ដីថ្លៃថ្នូរ និងពង្រឹងសុខដុមរមនា សុភមង្គល ក្នុងគ្រួសារ និងការគោរពសិទ្ធិគ្នាទៅវិញទៅមករវាងប្ដីនិងប្រពន្ធ ស្របតាមមាត្រា ៤៥ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។[8]

[5] មាត្រា ៩៥១ នៃក្រមរដ្ឋប្បវេណី

[6] មាត្រា ៩៥២ នៃក្រមរដ្ឋប្បវេណី

[7] មាត្រា ៩៤៨ នៃក្រមរដ្ឋប្បវេណី

[8] មាត្រា ១ នៃច្បាប់ស្ដីពីឯកពន្ធភាព ឆ្នាំ ២០០៦

### ១.២.៣ អំឡុងពេលហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ថ្មី

ចំណុចនេះត្រូវបានយកមកអនុវត្តតែចំពោះនារីនោះទេ ដោយនារីពុំអាចរៀបអាពាហ៍ពិពាហ៍ថ្មីបានឡើយក្នុងអំឡុងពេល ១២០ ថ្ងៃ ក្រោយពេលដែលអាពាហ៍ពិពាហ៍មុនត្រូវបានរំលាយឬលុបចោល។ ក៏ប៉ុន្តែបញ្ញត្តិនេះមិនត្រូវបានអនុវត្តចំពោះ ករណីដែលនារីនោះមានផ្ទៃពោះនៅមុនពេលអាពាហ៍ពិពាហ៍ត្រូវបានរំលាយ ឬលុបចោល ហើយបានសម្រាលកូនរួច។ នារីក៏អាចស្នើសុំលិខិតបញ្ជាក់ពីការគ្មានផ្ទៃពោះ ពីវេជ្ជបណ្ឌិតផងដែរ ដើម្បីពុំចាំបាច់អនុវត្តតាមបញ្ញត្តិនេះ។[9]

## ១.៣ អានុភាពនៃអាពាហ៍ពិពាហ៍

ក្រោយពេលដែលបុរសនិងនារីបានរៀបអាពាហ៍ពិពាហ៍ស្របតាមលក្ខខណ្ឌសារធាតុ និងលក្ខខណ្ឌទម្រង់ដែលច្បាប់បានកំណត់ ហើយពុំអាចត្រូវបានចាត់ទុកថា មោឃភាព ឬ អាចលុបចោល បាននោះអ្នកទាំងពីរនឹងទទួលបាននូវសិទ្ធិនិងករណីយកិច្ចមួយចំនួន ដែលបានកំណត់ដោយក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា។

### ១.៣.១ នាមត្រកូលរបស់ប្តីនិងប្រពន្ធ

ការប្រើប្រាស់នាមត្រកូលរបស់សហព័ទ្ធ គឺជាការសិទ្ធិបុគ្គលនិងការសម្រេចចិត្តរបស់បុគ្គលម្នាក់ៗ ហេតុដូច្នេះ ការប្រើនាមត្រកូលនេះ ប្តីអាចប្រើប្រាស់នាមត្រកូលប្រពន្ធ ហើយប្រពន្ធអាចប្រើប្រាស់នាមត្រកូលប្តីបាន ឬអាចជ្រើសរើសប្រើប្រាស់នាមត្រកូលដើមរៀងៗខ្លួន ដែលប្រើប្រាស់មុនពេលរៀបអាពាហ៍ពិពាហ៍ក៏បាន។[10]

ក្នុងន័យនេះ អាចឱ្យជាឧទាហរណ៍ថា សុខា និង បុផា បានរៀបអាពាហ៍ពិពាហ៍ជាមួយនឹងគ្នាដែលនាំឱ្យបុផា និង សុខា មានសិទ្ធិជ្រើសរើសប្រើប្រាស់នាមត្រកូលរបស់សហព័ទ្ធម្ខាងទៀត ឬអាចរក្សានាមត្រកូលខ្លួននៅដដែល។

ក៏ប៉ុន្តែ យើងអាចសង្កេតឃើញថា នៅព្រះរាជាណាចក្រកម្ពុជានាពេលសព្វថ្ងៃ ពុំមានការនិយមប្តូរនាមត្រកូលទៅតាមនាមត្រកូលរបស់សហព័ទ្ធនោះឡើយ ដោយភាគច្រើនរក្សានូវនាមត្រកូលខ្លួនមុនពេលរៀបអាពាហ៍ពិពាហ៍។

---

[9] មាត្រា ៩៥០ នៃក្រមរដ្ឋប្បវេណី

[10] មាត្រា ៩៦៥ នៃក្រមរដ្ឋប្បវេណី

### ១.៣.២ ករណីយកិច្ចរួមរស់នឹងគ្នា សហការ និងសង្គ្រោះគ្នាទៅវិញទៅមក

ទោះបីជាប្តីប្រពន្ធត្រូវបានចាត់ទុកជាបុគ្គលឯករាជ្យ និងស្មើភាពគ្នាក៏ដោយ ក៏ប្តីប្រពន្ធមានកាតព្វកិច្ចជួយសង្គ្រោះគ្នារវាងប្តីប្រពន្ធ ជាការគោរពគ្នាទៅវិញទៅមក ថែរក្សាគ្នា និងជួយគ្នា ដើម្បីឈានទៅកាន់វឌ្ឍនភាព ព្រមទាំងការកសាងគ្រួសារមួយដែលប្រកបដោយសុភមង្គល និងសាមគ្គីភាពក្នុងគោលបំណង ថែរក្សា ជីវភាពអាពាហ៍ពិពាហ៍រួម។[11]

នៅក្នុងចំណុចនេះ ចង់បង្ហាញថា ប្តីប្រពន្ធជាភាគីនៃអាពាហ៍ពិពាហ៍ មានករណីយកិច្ចរួមរស់ជាមួយគ្នាក្នុងជីវភាពតែមួយ បានន័យថា គប្បីចេះគោរពស្រឡាញ់គ្នាទៅវិញទៅមក ជួយថែរក្សា និងជួយគ្នា ដើម្បីរក្សានូវចំណងអាពាហ៍ពិពាហ៍រវាងអ្នកទាំងពីរ ដែលនាំឱ្យគ្រួសារអ្នកទាំងពីរមានវឌ្ឍនភាព និងមានសុភមង្គល។

### ១.៣.៣ ការជ្រើសរើសវិជ្ជាជីវៈ និងសិទ្ធិចូលរួមក្នុងសកម្មភាពសង្គម

ការជ្រើសរើសវិជ្ជាជីវៈជាការជ្រើសរើសនូវអាជីព មុខរបរ និងការងារ ដើម្បីប្រកបក្នុងគោលបំណងចិញ្ចឹមជីវភាពនិងពង្រីកនូវទ្រព្យធន ។ ក្រមរដ្ឋប្បវេណីបានអនុញ្ញាតឱ្យប្តីប្រពន្ធមានសេរីភាពក្នុងការជ្រើសរើសវិជ្ជាជីវៈ ដែលខ្លួនពេញចិត្តប្រកបនិងចាប់យក ។

សិទ្ធិចូលរួមប្រាស្រ័យដោយសេរីក្នុងសកម្មភាពនយោបាយ វប្បធម៌ និងសង្គម ដោយពុំចាំបាច់ត្រូវការការយល់ព្រមពីដៃគូ[12] ដោយសិទ្ធិនេះជាសិទ្ធិមួយដែលត្រូវបានផ្តល់ជូនប្រជាពលរដ្ឋគ្រប់រូប។

### ១.៣.៤ ការចាត់ទុកជានីតិជន ដោយអាពាហ៍ពិពាហ៍

ក្រោយពេលដែលអនីតិជនបានរៀបអាពាហ៍ពិពាហ៍ ទោះបីជាចំណងអាពាហ៍ពិពាហ៍នោះត្រូវបានរំលាយក៏ដោយ ក៏អនីតិជនដែលទទួលបាននីតិភាពដោយការរៀបអាពាហ៍ពិពាហ៍នោះ នៅតែត្រូវបានចាត់ទុកជានីតិជន។ សកម្មភាពនេះ ត្រូវបានកំណត់ដោយក្រមរដ្ឋប្បវេណីថា ជាការទទួលបានអត្តាធីនភាព។ ការទទួលបានអត្តាធីនភាពនេះ ត្រូវបានធ្វើឡើងដោយស្វ័យប្រវត្តិដោយពុំចាំបាច់មានសេចក្តីសម្រេចរបស់តុលាការនោះទេ។

យោងតាមសន្ទានុក្រមផ្នែករដ្ឋប្បវេណី "អត្តាធីនភាព" គឺជាស្ថានភាពមួយ ដែលផ្តល់ឱ្យអនីតិជនបានរួចផុតពីរបបអាណាព្យាបាលសម្រាប់អនីតិជន ឬ រួចផុតពីអំណាចមេបា ហើយមានសមត្ថភាពដូចនីតិជនដែរ ។ អត្តាធីនភាព គឺមានអានុភាពអាចធ្វើឱ្យច្បាប់ចាត់ទុកថាអនីតិជននោះបានដល់នីតិភាពហើយ

---

11 មាត្រា ៩៦៦ នៃក្រមរដ្ឋប្បវេណី

12 មាត្រា ៩៦៧ នៃក្រមរដ្ឋប្បវេណី

នឹងអាចធ្វើសកម្មភាពបានដូចជានីតិជនដែរ។ តាមរយៈអានុភាពនេះ អនីតិជននោះអាចធ្វើសកម្មភាពជាច្រើនដែលច្បាប់ហាមឃាត់ចំពោះអនីតិជន មានដូចជាការធ្វើពាណិជ្ជកម្ម អាជីវកម្ម ដោយពុំចាំមានការអនុញ្ញាតពីម្ដាយឪពុក ឬអ្នកដែលមានអំណាចមេបា ឬ អាណាព្យាបាលសម្រាប់អនីតិជន។ ជាពិសេស អនីតិជន អាចធ្វើសកម្មភាពចុះកិច្ចសន្យា ។ លើសពីនេះទៀត អនីតិជនអាចទទួលបាននូវបុគ្គលភាពគតិយុត្ត ដែលជាប្រធាននៃសិទ្ធិនិងកាតព្វកិច្ចយ៉ាងពេញលេញទៀតផង។

### **១.៣.៥ ទ្រព្យសម្បត្តិ**

វចនានុក្រមខ្មែរ បានពន្យល់ពាក្យ "ទ្រព្យ" ថា ជាវត្ថុ, ធនធាន, សម្បត្តិ។ ហើយតាមន័យសាមញ្ញយើងប្រើពាក្យនេះចំពោះតែវត្ថុ មានដូចជា មាសប្រាក់ជាដើម ដែលមានម្ចាស់។ ទ្រព្យធន, ទ្រព្យសម្បត្តិ គឺទ្រព្យផ្សេងៗ, ទ្រព្យសម្រាប់ប្រើប្រាស់។

ចំណែក ច្បាប់ស្ដីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម បានពន្យល់ពាក្យ "ទ្រព្យសម្បត្តិ" ថាជាទ្រព្យគ្រប់ប្រភេទ ចលនទ្រព្យឬអចលនទ្រព្យ ទ្រព្យរូបិយឬទ្រព្យអរូបិយ និងឯកសារឬឧបករណ៍គតិយុត្ត ដែលជាភស្តុតាងនៃកម្មសិទ្ធិឬអត្ថប្រយោជន៍លើទ្រព្យទាំងនេះ។

ចំពោះអានុភាពទាក់ទងនឹងទ្រព្យសម្បត្តិប្ដីប្រពន្ធនេះវិញ ច្បាប់បានផ្ដល់នូវជម្រើសដល់សហព័ទ្ធក្នុងការជ្រើសរើសប្រព័ន្ធទ្រព្យសម្បត្តិដែលអ្នកទាំងពីរចង់ប្រើប្រាស់ ដែលក្នុងនោះរួមមាន[13]៖

- ប្រព័ន្ធកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ
- ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់

#### **១.៣.៥.១ ប្រព័ន្ធកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ**

ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាត្រង់គន្ថីទី៧ ជំពូកទី៣ ផ្នែកទី៣ កថាភាគទី១ បានបញ្ញត្តិអំពីប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យាបានទទួលស្គាល់នូវកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ។

កិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធនេះ ត្រូវបានធ្វើឡើងក្នុងគោលបំណងទប់ស្កាត់វិវាទលើទំនាក់ទំនងទ្រព្យសម្បត្តិនិងបញ្ជាក់អំពីទំនាក់ទំនងសិទ្ធិនិងករណីយកិច្ចប្ដីប្រពន្ធ។ ប្ដីប្រពន្ធអាចធ្វើកិច្ចសន្យានេះ អាចធ្វើឡើងនៅមុន ឬក្រោយពេលរៀបអាពាហ៍ពិពាហ៍បាន។

កិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធនេះ ដាច់ខាតត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ព្រមទាំងចាំបាច់ត្រូវចុះបញ្ជីទើបមានអានុភាពតតាំងជាមួយនឹងតតិយជនបាន ។ ក្នុងករណីដែលប្ដីប្រពន្ធពុំបានចុះបញ្ជី

[13] មាត្រា ៩៦៩ នៃ នៃក្រមរដ្ឋប្បវេណី

កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធនេះ នោះកិច្ចសន្យានេះនឹងពុំមានអានុភាពតតាំងជាមួយតតិយជនឡើយ។[14]

ស្ថាប័នដែលមានសមត្ថកិច្ចលើការចុះបញ្ជី គឺនាយកដ្ឋានកិច្ចការរដ្ឋប្បវេណីនៃក្រសួងយុត្តិធម៌ ដោយមានមន្ត្រីទទួល បន្ទុកកិច្ចការចុះបញ្ជីនេះ និងរក្សាទុកឯកសារកិច្ចសន្យានោះក្នុងក្រូណូទាក់ទងនិងការចុះបញ្ជីកិច្ចសន្យាទ្រព្យ សម្បត្តិប្តីប្រពន្ធនេះ នៅនាយកដ្ឋានកិច្ចការរដ្ឋប្បវេណីនៃក្រសួងយុត្តិធម៌។ ក្រោយពេលចុះបញ្ជីចប់សព្វគ្រប់ នោះនាយកដ្ឋានកិច្ចការរដ្ឋប្បវេណិនៃក្រសួងយុត្តិធម៌នឹងចេញលិខិតបញ្ជាក់ជូន តាមការដាក់ពាក្យសុំរបស់ប្តីប្រពន្ធដែលជាអ្នកដាក់ពាក្យសុំ ។ នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យានេះ ត្រូវបានកំណត់យ៉ាងច្បាស់លាស់នៅក្នុងប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ឆ្នាំ ២០១៣។

ក៏ប៉ុន្តែ ប្រជាជននៃព្រះរាជាណាចក្រកម្ពុជាពុំនិយមក្នុងការធ្វើកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធឡើយ ដូច្នេះហើយ ស្ទើរតែគ្មានអ្នកប្រើប្រាស់នូវការចុះបញ្ជីនេះទេ។

គប្បីចំណាំថា កិច្ចសន្យានេះ មិនអាចធ្វើឡើងផ្ទុយនឹងបញ្ញត្តិស្តីពី សិទ្ធិទាមទារអាហារកាតព្វកិច្ច និងភាគបម្រុងបានឡើយ នៅពេលដែលមិនបានធ្វើកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធទេនឹងត្រូវអនុលោមតាមប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ ។

### ១.៣.៥.២ អំពីប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់

ក្នុងករណីដែលប្តីប្រពន្ធពុំបានចុះកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់នឹងត្រូវបានយកមកអនុវត្ត[15] ។ ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ បានបែងចែកទ្រព្យសម្បត្តិប្តីប្រពន្ធជាពីរប្រភេទគឺ ទ្រព្យសម្បត្តិដោយឡែក និងទ្រព្យសម្បត្តិរួម។

### ក. ទ្រព្យសម្បត្តិដោយឡែក

ទ្រព្យសម្បត្តិដោយឡែក [16] ជាទ្រព្យសម្បត្តិដោយឡែកដែលស្ថិតក្រោមកម្មសិទ្ធិរបស់សហព័ទ្ធតែម្ខាងបានន័យថា៖

ក. ជាទ្រព្យសម្បត្តិដែលមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍

---

[14] មាត្រា ៩៧០ នៃក្រមរដ្ឋប្បវេណី

[15] មាត្រា ៩៦៩ នៃក្រមរដ្ឋប្បវេណី

[16] មាត្រា ៩៧២ នៃក្រមរដ្ឋប្បវេណី

ខ. ជាទ្រព្យសម្បត្តិដែលទទួលបានដោយប្រទានកម្ម សន្តតិកម្ម អច្ច័យទាន នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍

គ. ជាទ្រព្យសម្បត្តិជាតម្លៃតប ដែលទទួលបានពីការចាត់ចែងទ្រព្យសម្បត្តិដែលមានមុនពេលរៀបអាពាហ៍ពិពាហ៍ ឬ/និង ទ្រព្យសម្បត្តិដែលទទួលបានដោយប្រទានកម្ម សន្តតិកម្ម អច្ច័យទាន នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ។

## ខ. ទ្រព្យសម្បត្តិរួម

ទ្រព្យសម្បត្តិរួម [17] ជាទ្រព្យសម្បត្តិដែលមានរួមគ្នាហើយសំដៅទៅលើទ្រព្យសម្បត្តិទាំងឡាយណាដែលប្តីប្រពន្ធទាំងសងខាង ឬតែម្ខាងទទួលបាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ក្រៅពីទ្រព្យសម្បត្តិដោយឡែក ។

នេះអាចនិយាយក្នុងន័យសាមញ្ញថា ទ្រព្យសម្បត្តិដែលទទួលបាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ក្រៅពីទ្រព្យសម្បត្តិដោយឡែក នឹងត្រូវក្លាយជាទ្រព្យសម្បត្តិរួម។

## គ. ការគ្រប់គ្រងនិងការប្រើប្រាស់ទ្រព្យសម្បត្តិ

ប្តីប្រពន្ធមានសិទ្ធិស្មើគ្នាក្នុងការប្រើប្រាស់ទទួលផលប្រយោជន៍ និងគ្រប់គ្រងទ្រព្យសម្បត្តិរួម។ ក្រមរដ្ឋប្បវេណីក៏បានចែងអំពីសិទ្ធិប្រើប្រាស់ ទទួលផលប្រយោជន៍ និង គ្រប់គ្រងទ្រព្យសម្បត្តិរបស់បុគ្គល រៀងៗខ្លួនដែរ[18]។

សិទ្ធិប្រើប្រាស់ទ្រព្យសម្បត្តិរួម ត្រូវបានអនុវត្តដោយផ្អែកលើភាពចាំបាច់នៅក្នុងជីវភាព ហើយ ក្រមរដ្ឋប្បវេណីក៏បានទទួលស្គាល់នូវសិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិរួម និងមានសិទ្ធិទាមទារនូវចំណាត់ការ ដើម្បីគ្រប់គ្រងនិងរក្សាទុកនូវទ្រព្យសម្បត្តិរួម ។ ម្យ៉ាងទៀត ប្តីប្រពន្ធអាចទាមទារនូវការសម្រេចសេចក្តីទាក់ទងទៅនឹងការគ្រប់គ្រងនិងប្រើប្រាស់នៅក្នុងករណី ដែលមិនអាចពិភាក្សាគ្នាបានអំពីការគ្រប់គ្រងនិងប្រើប្រាស់លើទ្រព្យសម្បត្តិរួម ។

ក្រៅពីកម្មសិទ្ធិអវិភាគនៃគន្លីស្តីអំពី "សិទ្ធិប្រត្យក្ស" និង បទបញ្ញត្តិពិសេសបានកំណត់ថា ប្តីប្រពន្ធអាចទាមទារនូវការចុះបញ្ជីអំពីទ្រព្យសម្បត្តិរួមប្តីប្រពន្ធហើយនៅចំណុច បានកំណត់ថាប្តីប្រពន្ធអាចទាមទារឱ្យតុលាការធ្វើការចាត់ចែងដែលចាំបាច់ ឬ ចំណាត់ការ នៅពេលដែលមិនអាចនិយាយត្រូវគ្នា។

[17] មាត្រា ៩៧៣ នៃក្រមរដ្ឋប្បវេណី

[18] មាត្រា ៩៧៤ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី

### ឃ. ការទទួលខុសត្រូវដោយសាមគ្គីភាពចំពោះកាតព្វកិច្ច

ប្តីប្រពន្ធត្រូវទទួលខុសត្រូវដោយសាមគ្គីភាពចំពោះ សោហ៊ុយដើម្បីរក្សាជីវភាពរួមរបស់ប្តីប្រពន្ធ និងសោហ៊ុយដើម្បីការអប់រំឬការព្យាបាលថែទាំកូនជាអាទិ៍ កាតព្វកិច្ច និង ករណីយកិច្ចផ្សេងៗទៀត ដែលប្តីប្រពន្ធបានព្រមព្រៀងតាមលិខិតជាលាយលក្ខណ៍អក្សរនៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ សោហ៊ុយដើម្បីគ្រប់គ្រង និង រក្សាទ្រព្យសម្បសត្តិរួម [19]។

### ង. ការចាត់ចែងទ្រព្យសម្បត្តិរួម

ទ្រព្យសម្បត្តិរួម មិនអាចយកទៅលក់ ឬ ធ្វើការចាត់ចែងផ្សេងទៀតដោយមិនមានការយល់ព្រមពីប្តីប្រពន្ធទាំងសងខាងបានឡើយទេ [20] ។ នៅពេលដែលមានស្ថានភាពមិនអាចជៀសវាងបានសម្រាប់ការថែទាំជីវភាពរួមក្នុងអាពាហ៍ពិពាហ៍ និងដើម្បីជីវភាពរស់នៅនោះប្តី ឬ ប្រពន្ធណាម្ខាងអាចលក់ ឬ ធ្វើការចាត់ចែងផ្សេងទៀតនូវទ្រព្យសម្បត្តិរួមបាន ដោយទទួលការអនុញ្ញាតពីតុលាការ [21]។

ក្នុងករណីដែលប្តី ឬ ប្រពន្ធម្ខាងបានធ្វើការលក់ ឬ ធ្វើការចាត់ចែងផ្សេងទៀតនូវទ្រព្យសម្បត្តិរួមដោយគ្មានការយល់ព្រមពីសហព័ទ្ធម្ខាងទៀត និងគ្មានការអនុញ្ញាតពីតុលាការ សហព័ទ្ធដែលមិនបាន ផ្តល់ការយល់ព្រមអាចទាមទារឱ្យលុបចោលនូវការចាត់ចែង តាមរយៈតុលាការបាននៅក្នុងអំឡុងពេល ២(ពីរ) ឆ្នាំ គិតចាប់ពីពេលដែលបានដឹងអំពីការចាត់ចែងនោះ បើទ្រព្យសម្បត្តិរួមដែលត្រូវបានចាត់ចែងនោះជាអចលនវត្ថុនៃការអាស្រ័យនៅ និងក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ គិតចាប់ពីពេលដែលបានដឹងអំពីការចាត់ចែងនោះ បើទ្រព្យសម្បត្តិរួមដែលត្រូវបានចាត់ចែងនោះជាទ្រព្យសម្បត្តិផ្សេង[22]។

### ច. ការអាស្រ័យនៅទ្រព្យសម្បត្តិដោយឡែក

ប្តីប្រពន្ធ អាចអាស្រ័យនៅអចលនវត្ថុដែលជាទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធម្ខាងទៀត ដែលអាចប្រើប្រាស់សម្រាប់ការអាស្រ័យនៅរបស់គ្រួសារបាន ទោះបីជាសហព័ទ្ធម្ខាងទៀតបានចាត់ចែងអចលនវត្ថុនោះក៏ដោយ ក៏អាចបន្តអាស្រ័យនៅអចលនវត្ថុនោះបានដែរ[23] ។

[19] មាត្រា ៩៧៥ នៃក្រមរដ្ឋប្បវេណី

[20] មាត្រា ៩៧៦ កថាខណ្ឌ១ នៃក្រមរដ្ឋប្បវេណី

[21] មាត្រា ៩៧៦ កថាខណ្ឌ២ នៃក្រមរដ្ឋប្បវេណី

[22] មាត្រា ៩៧៦ កថាខណ្ឌ៣ នៃក្រមរដ្ឋប្បវេណី

[23] មាត្រា ៩៧៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

ចំពោះទ្រព្យសម្បត្តិជាអចលនវត្ថុដែលប្ដីប្រពន្ធកំពុងស្នាក់នៅនោះ ទោះបីជាអចលនវត្ថុនោះជាទ្រព្យដោយឡែកក៏ដោយ ក៏ការចាត់ចែងអចលនវត្ថុនោះរួមទាំងសម្ភារៈក្នុងអចលនវត្ថុនោះ ចាំបាច់ត្រូវមានការឯកភាពពីសហព័ទ្ធម្ខាងទៀតដែរ។

## ២. ការលែងលះ

ការលែងលះ គឺជាការផ្ដាច់នូវចំណងអាពាហ៍ពិពាហ៍រវាងសហព័ទ្ធតាមផ្លូវច្បាប់ ។ ការលែងលះជាការផ្លាស់ប្ដូរនូវឋានៈបុគ្គលរបស់មនុស្សពីរនាក់នៅក្នុងសង្គម និងជាការផ្ដាច់នូវសិទ្ធិនិងករណីយកិច្ចដែល កើតចេញពីអានុភាពនៃចំណងអាពាហ៍ពិពាហ៍ ដែលដាច់ខាតត្រូវធ្វើឡើងស្របតាមនីតិវិធីច្បាប់ជាធរមាន។

ការលែងលះ ក៏មានន័យថា ជាការរំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍ ដែលក៏អាចសំដៅលើការរំដោះ ខ្លួនឱ្យរួចពីចំណងនៃទំនាក់ទំនងអាពាហ៍ពិពាហ៍ដែលខ្លួនធ្លាប់ជាសហព័ទ្ធ។ ការរំលាយនេះ នឹងនាំឱ្យករណីយកិច្ចរួមរស់នៅជាមួយគ្នាសហការគ្នា និងមានករណីកិច្ចសង្គ្រោះគ្នាទៅវិញទៅមក ត្រូវរលត់ ហើយទោះបីជាសហព័ទ្ធដែលបានលែងលះអះអាងថា ជីវភាពរស់នៅមានការលំបាកក៏ដោយក៏បុគ្គលម្ខាងទៀត ដែលជាអតីតសហព័ទ្ធមិនមានករណីកិច្ចសង្គ្រោះដែរ ។ បន្ថែមពីលើនេះ ករណីយកិច្ចស្មោះត្រង់ក៏ត្រូវរលត់ ដោយឯកឯងដែរ ដោយអ្នកទាំងពីរអាចរៀបអាពាហ៍ពិពាហ៍ជាថ្មីម្ដងទៀតបាន។

អាពាហ៍ពិពាហ៍ក៏ដូចគ្នាដែរ ដោយសារតែវាកើតឡើងអាស្រ័យទៅលើការព្រមព្រៀងរបស់បុគ្គលដែលនឹកក្លាយទៅជាសហព័ទ្ធ អាចនិយាយបានថា វាជាប្រភេទនៃកិច្ចសន្យាមួយដែលមានអត្ថន័យទូលំទូលាយ។ ការរំលាយទំនាក់ទំនងកិច្ចសន្យាទៅតាមការព្រមព្រៀងរបស់គូភាគីនៃកិច្ចសន្យា ជាគោលការណ៍អាចត្រូវបានទទួលស្គាល់ដោយសេរី ។ ចំពោះករណីនៃអាពាហ៍ពិពាហ៍វិញ ការរំលាយពោលគឺការលែងលះមិនមែនអាចធ្វើបានដោយសេរីនោះទេ។ ហេតុផលគឺថា ដោយសារតែវាមានករណីដែលសហព័ទ្ធម្ខាងទៀតទទួលរងផលប៉ះពាល់យ៉ាងខ្លាំងពីការលែងលះនេះ។

### ២.១ មូលហេតុនៃការលែងលះ

ប្ដីឬប្រពន្ធនៅក្នុងចំណងអាពាហ៍ពិពាហ៍មួយមានបំណងចង់លែងលះ អាចធ្វើបានតែក្នុងករណីដែលបានកំណត់នៅក្នុងមាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណីប៉ុណ្ណោះនោះទេ។ ករណីទាំងនោះរួមមានដូចតទៅៈ

ក. បើបានប្រព្រឹត្តអំពើផិត ទៅលើសហព័ទ្ធ ។

ខ. បើបានបោះបង់សហព័ទ្ធចោល ដោយគ្មានមូលហេតុត្រឹមត្រូវ ។

គ. បើមិន ដឹងច្បាស់ថាសហព័ទ្ធស្លាប់ ឬ រស់ អស់រយៈពេលជាង ១ (មួយ) ឆ្នាំ ។

ឃ. បើសហព័ទ្ធបានរស់នៅបែកគ្នាជាបន្តបន្ទាប់ អស់រយៈពេលជាង ១ (មួយ) ឆ្នាំ ផ្ទុយនឹងគោលបំណងនៃអាពាហ៍ពិពាហ៍ ។

ង. ករណីផ្សេងទៀតដែលទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបាន ។

ក៏ប៉ុន្តែនៅក្នុងករណីខ្លះ បើទោះបីជាលក្ខខណ្ឌខាងលើនេះត្រូវបានបំពេញក៏ដោយ ក៏តុលាការនៅក្នុងករណីដែលខ្លួនយល់ឃើញថា ការលែងលះគ្នានោះនឹងបណ្តាលឱ្យការទ្រទ្រង់ជីវភាពរបស់សហព័ទ្ធ ឬ កូន ក្រលំបាកយ៉ាងខ្លាំង ឬ មានការឈឺចាប់ដែលពុំអាចទ្រាំទ្របាននោះ តុលាការអាចច្រានចោលការទាមទារលែងលះនេះ ដោយពិចារណាទៅលើស្ថានភាពទាំងឡាយបាន ។

ក្នុងករណីដែលមានមូលហេតុថា សហព័ទ្ធបានរស់នៅបែកគ្នាជាបន្តបន្ទាប់ អស់រយៈពេលជាង ១ (មួយ) ឆ្នាំ ផ្ទុយនឹងគោលបំណងនៃអាពាហ៍ពិពាហ៍ ឬ ករណីផ្សេងទៀតដែលទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបាន ប្រសិនបើយល់ឃើញថា ការទាមទារនោះផ្ទុយនឹងភាពសុច្ចរិត ដោយជនដែលទាមទារឱ្យលែងលះគ្នានោះ ធ្វេសប្រហែសយ៉ាងខ្លាំងក្នុងការសហប្រតិបត្តិ និងជួយសង្គ្រោះចំពោះសហព័ទ្ធនោះ តុលាការអាចច្រានចោលការទាមទារ លែងលះគ្នានោះ ដោយឆន្ទានុសិទ្ធិបាន ។

## ២.២ ប្រភេទនៃបណ្តឹងលែងលះ

បណ្តឹងគឺជាសកម្មភាពទាមទារមួយ (ពាក្យសុំ) ដែលដើមចោទបានធ្វើឡើងចំពោះចុងចម្លើយ ទៅតុលាការនៃការជំនុំជម្រះលើកទី១ ដែលត្រូវបានកំណត់ ដោយបានលើកឡើងនូវការអះអាងអំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្ត តាមផ្លូវច្បាប់នីតិឯកជនកំណត់មួយ ហើយទាមទារឱ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារកំណត់មួយ ផ្អែកលើការអះអាងទាំងនោះ ហើយជាគោលការណ៍ សកម្មភាពនៃបណ្តឹងនេះ ត្រូវធ្វើឡើងតាមវិធីដាក់ពាក្យបណ្តឹង ។ តាមរយៈការដាក់ពាក្យបណ្តឹងនេះ នីតិវិធីនៃបណ្តឹងនឹងត្រូវបានចាប់ផ្តើម ។

បណ្តឹងគឺជាពាក្យសុំទាមទារឱ្យតុលាការចេញសាលក្រម ដែលមានខ្លឹមសារកំណត់មួយ ។ តុលាការត្រូវចាំរហូតដល់បានទទួលពាក្យបណ្តឹង ទើបអាចចាប់ផ្តើមនីតិវិធីលើបណ្តឹងនោះបាន ។

ជាគោលការណ៍ តុលាការអាចចេញសាលក្រមអំពីចំណុចដែលដើមចោទបានសុំដែលមាននៅក្នុងពាក្យបណ្តឹងត្រឹមតែទំហំនៃការទាមទារ ដែលដើមចោទបានសុំដែលមាននៅក្នុងពាក្យបណ្តឹងនោះប៉ុណ្ណោះ ដូច្នេះ ជាឧទាហរណ៍ប្រសិនបើដើមចោទទាមទារឱ្យចុងចម្លើយសងប្រាក់ដើម ដែលជាប្រាក់កម្ចី ៥ លានរៀល ទោះជាតុលាការបានទទួលស្គាល់នូវសិទ្ធិទាមទារការប្រាក់ ១០ លានរៀលក៏ដោយ តុលាការមិនអាចចេញ

សាលក្រមបង្គាប់ឱ្យចុងចម្លើយសងប្រាក់ ១០ លានរៀលបានទេ ដោយហេតុថា ការទាមទារនេះ មិននៅក្នុងខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញនោះទេ។

ម្យ៉ាងទៀត ក្នុងករណីដែលដើមចោទបានទាមទារឱ្យតុលាការចេញសាលក្រមបង្គាប់ឱ្យចុងចម្លើយបង់ ១០ លានរៀល ក្នុងចំណោមទឹកប្រាក់ ១២ លានរៀលនោះ តុលាការមិនអាចចេញសាលក្រមបង្គាប់ឱ្យចុងចម្លើយបង់ប្រាក់លើសពី ១០ លានរៀលបានឡើយ បានន័យថា ជាគោលការណ៍ "បើគ្មានបណ្ដឹងទេ ក៏គ្មានមានសាលក្រមដែរ" ហៅថា គោលការណ៍នៃសិទ្ធិចាត់ចែង ។

បណ្ដឹងគឺជាសកម្មភាពដែលធ្វើឡើងចំពោះតុលាការ មិនមែនជាសកម្មភាពដែលទាមទារឱ្យចុងចម្លើយធ្វើសកម្មភាពណាមួយទេ ។ បណ្ដឹងទាក់ទងនឹងការលែងលះ គឺជាបណ្ដឹងទាមទារឱ្យបង្កើត ប្ដូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត ដោយមូលហេតុថា បណ្ដឹងនេះទាក់ទងនឹងឋានៈបុគ្គល ។ បណ្ដឹងទាមទារឱ្យបង្កើត ប្ដូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត គឺជាបណ្ដឹងទាមទារឱ្យតុលាការចេញសាលក្រមប្រកាសបង្កើតជាថ្មីនូវទំនាក់ទំនងគតិយុត្ត (ការកើតមានឡើង ការប្ដូរ ឬ ការរំលត់) ដោយផ្អែកលើការអះអាងអំពីអត្ថិភាពនសិទ្ធិបង្កើត ឬ អំពីមូលហេតុនៃការបង្កើតទំនាក់ទំនងគតិយុត្តកំណត់មួយ ដែលជាការទាមទារតាមផ្លូវបណ្ដឹង បណ្ដឹងប្រភេទនេះ មានដូចជាបណ្ដឹងសុំលែងលះគ្នា ។

បើសិនជាការព្រមព្រៀងលែងលះគ្នារវាងភាគីដែលមានទំនាក់ទំនងអាពាហ៍ពិពាហ៍ មិនអាចសម្រេចបានទេ ហើយក្នុងករណីដែលភាគីខាងប្ដី ឬ ខាងប្រពន្ធ ចង់លែងលះគ្នា ភាគីនោះត្រូវដាក់ពាក្យបណ្ដឹងសុំលែងលះគ្នា ។ ក្នុងករណីនៃការលែងលះគ្នាតាមរយៈបណ្ដឹងសុំលែងលះ ទាល់តែមានសាលក្រមលែងលះទើបមានអានុភាពបង្កើតនូវទំនាក់ទំនងគតិយុត្ត ដែលរំលាយនូវទំនាក់ទំនងអាពាហ៍ពិពាហ៍ ដែលមានពីមុនមករវាងដើមចោទ និង ចុងចម្លើយ ។

ទោះជាមានមូលហេតុលែងលះគ្នាដែលមានចែងក្នុងក្រមរដ្ឋប្បវេណីក៏ដោយ ហើយភាគីម្ខាងបានបង្ហាញឆន្ទៈលែងលះគ្នាក៏ដោយ មិនមានអានុភាពលែងលះគ្នាបានទេ ។ ដើម្បីឱ្យអានុភាពនៃការលែងលះគ្នាដែលជាការរំលាយនូវចំណងអាពាហ៍ពិពាហ៍នោះកើតមានឡើង ទាល់តែតុលាការចេញសាលក្រមលែងលះគ្នា ។ ដូច្នេះហើយ ជាគោលករណ៍ ច្បាប់ទទួលស្គាល់នូវការបង្កើតទំនាក់ទំនងគតិយុត្ត ថ្មី ដោយផ្អែកលើឆន្ទៈរបស់ភាគីណាម្ខាង ក៏ប៉ុន្តែ មានករណីមួយចំនួនដែល ដើម្បីឱ្យអានុភាពនៃការបង្កើតទំនាក់ទំនងគតិយុត្តនោះមានកើតមានឡើង ការបង្ហាញឆន្ទៈរបស់ភាគីមិនមែនជាការគ្រប់គ្រាន់ទេ គឺចាំបាច់មានបណ្ដឹង ហើយឱ្យតុលាការចេញសាលក្រម ។

ការលែងលះអាចធ្វើឡើងដោយរបៀប ២ ៖ ទី១ គឺការដាក់ពាក្យបណ្ដឹងទៅតុលាការមានសមត្ថកិច្ច[24] និងទី២ ការដាក់ពាក្យបណ្ដឹងទៅតុលាការមានសមត្ថកិច្ច ឬ ទៅក្រុមប្រឹក្សាឃុំសង្កាត់[25]។

តាមកំណត់ក្នុងមាត្រា ៩៨២ នៃក្រមរដ្ឋប្បវេណី បណ្ដឹងនៃការលែងលះគ្នាបានកំណត់ថា ចំពោះការដាក់ពាក្យបណ្ដឹងលែងលះគ្នា ត្រូវដាក់ទៅតុលាការមានសមត្ថកិច្ច ត្រូវធ្វើឡើងតាមបញ្ញត្តិនៃមាត្រា ១០ សមត្ថកិច្ចសាលាជម្រះក្ដីពិសេសលើរឿងក្ដីលែងលះគ្នា និងរឿងក្ដីអំពីបុគ្គភាព នៃក្រមនីតិវិធី រដ្ឋប្បវេណី។

រីឯចំពោះការលែងលះដោយការព្រមព្រៀងនោះ ភាគីនៃអាពាហ៍ពិពាហ៍អាចដាក់ពាក្យបណ្ដឹងលែងលះទៅតុលាការបាន ក្នុងទម្រង់ជាពាក្យសុំលែងលះ ទៅតុលាការមានសមត្ថកិច្ច ត្រូវបានធ្វើឡើងក្នុងករណី ដែលប្ដីប្រពន្ធទាំងពីរបានឯកភាពគ្នាក្នុងការលែងលះ និងបានព្រមព្រៀងគ្នាលើចំណុចមួយចំនួនទាក់ទងនឹងសិទ្ធិនិងករណីយកិច្ចផ្សេងៗ ដែលកកើតក្នុងអំឡុងពេលអានុភាពអាពាហ៍ពិពាហ៍។

[24] មាត្រា ៩៧៩ នៃក្រមរដ្ឋប្បវេណី

[25] មាត្រា ៩៨២ នៃក្រមរដ្ឋប្បវេណី

# ជំពូក២

# នីតិវិធីនៃការលែងលះដោយការព្រមព្រៀង

# ជំពូកទី២ នីតិវិធីនៃការលែងលះដោយការព្រមព្រៀង

នីតិវិធីនៃការលែងលះដោយការព្រមព្រៀង ស្ថិតក្នុងវិសាលភាពនៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ហើយមានលក្ខខណ្ឌគ្រឹះពាក់ព័ន្ធទៅនឹងភាពច្បាស់លាស់នៃចំណងគតិយុត្តដែល សំដៅដល់អត្ថិភាពនៃចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់និងឆន្ទៈពិតប្រាកដរបស់ប្តីប្រពន្ធទាំងពីរក្នុងការស្រុះ ស្រួលគ្នាដើម្បីបញ្ចប់ជីវិតជា ប្តីប្រពន្ធនឹងគ្នាទៅទៀត។

អត្ថិភាពនៃចំណងអាពាហ៍ពិពាហ៍គឺជាមូលដ្ឋានចម្បង ដែលធ្វើឱ្យប្តីនិងប្រពន្ធមានទំនាក់ទំនងគតិយុត្តរវាងគ្នា និងអាចបង្កើតជាក្រុមគ្រួសារជាមួយគ្នាបានតាមទម្រង់ច្បាប់ ។ អត្ថិភាពនៃចំណងអាពាហ៍ពិពាហ៍បានដើរតួជាលក្ខខណ្ឌគ្រឹះនៅក្នុងរឿងក្តីនៃការលែងលះ ដោយហេតុថានៅពេលដំណើរការដោះស្រាយរឿងក្តីលែងលះ តុលាការតែងតែបង្គាប់ឱ្យភាគីផ្តល់នូវសំបុត្រអាពាហ៍ពិពាហ៍ ដើម្បីធ្វើការពិនិត្យ។ ក្នុងករណីដែលភាគីមិនបានផ្តល់តាមការបង្គាប់នេះ តុលាការនឹងមិនជឿថាមានអង្គហេតុនៃការបង្កើតចំណងគតិយុត្ត ឬអាចនិយាយបានថា ការចុះបញ្ជីសំបុត្រអាពាហ៍ពិពាហ៍ ដូច្នេះពាក្យសុំនោះនឹងត្រូវបានច្រានចោលដោយដីកាសម្រេច។

## ១. ការដាក់ពាក្យសុំ

ដើម្បីចាប់ផ្តើមជំនុំជម្រះទៅលើសំណុំរឿងមួយ អ្នកដាក់ពាក្យសុំត្រូវដាក់ពាក្យសុំមកតុលាការដើម្បីឱ្យតុលាការរៀបចំកសាងសំណុំរឿង ក្នុងគោលបំណងវិនិច្ឆ័យសេចក្តីនៅលើសំណុំរឿងនោះ។

ចំណុចដែលត្រូវសរសេរក្នុងពាក្យសុំលែងលះដោយការព្រមព្រៀង តាមនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងមានដូចខាងក្រោម[26]៖

- ឈ្មោះ ឬ នាមករណ៍ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់
- ឈ្មោះ ឬ នាមករណ៍ និងអាសយដ្ឋានរបស់ភាគីម្ខាងទៀត
- ខ្លឹមសារនៃដីកាសម្រេច ឬ សកម្មភាពផ្សេងទៀត ដែលអ្នកដាក់ពាក្យសុំទាមទារឱ្យតុលាការចេញ
- អង្គហេតុដែលជាមូលហេតុនៃការទាមទារ

[26] មាត្រា ២៦ នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីមិនមែនបណ្តឹង

- ឯកសារជាភស្តុតាង ។

ពាក្យសុំនេះ ត្រូវយកទៅដាក់នៅតុលាការដែលមានសមត្ថកិច្ច ហើយតុលាការដែលមានសមត្ថកិច្ចនោះជាសមត្ថកិច្ចរបស់សាលាដំបូងដែលត្រូវបានកំណត់ក្នុងតារាងឧបសម្ព័ន្ធ នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីមិនមែនបណ្តឹង ។ នៅក្នុងសំណុំរឿងរដ្ឋប្បវេណីមិនមែនបណ្តឹងទាក់ទងនឹងការលែងលះដោយការព្រមព្រៀងនោះត្រូវបានកំណត់ក្នុងផ្នែកទី៤ ចំណុចទី៥ យោងតាមមាត្រា ៩៧៩ នៃក្រមរដ្ឋប្បវេណី។

ក៏ប៉ុន្តែ ក្នុងករណីដែលតុលាការយល់ឃើញថា សំណុំរឿងនោះមិនស្ថិតក្រោមសមត្ថកិច្ចខ្លួន អាច បញ្ជូនរឿងនេះទៅតុលាការដែលមានសមត្ថកិច្ចតាមពាក្យសុំឬឆន្ទានុសិទ្ធិបាន។[27]

## ២ ការជំនុំជម្រះ

តុលាការអាចយកអង្គហេតុដែលមិនមែនជាការអះអាងរបស់អ្នកដាក់ពាក្យសុំឬភាគីម្ខាងទៀតមកធ្វើជាមូលដ្ឋាននៃដីកាសម្រេចបាន ហើយក្នុងករណីដែលយល់ឃើញថាចាំបាច់ តុលាការអាចស្រាវជ្រាវអង្គហេតុនិងធ្វើការពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិបាន។

ជាគោលការណ៍ ការជំនុំជម្រះលើពាក្យសុំទាក់ទងនឹងការលែងលះដោយការព្រមព្រៀង ត្រូវធ្វើឡើងដោយចៅក្រមមួយរូប ។ នៅក្នុងសំណុំរឿងរដ្ឋប្បវេណីមិនមែនបណ្តឹង ជនដែលពាក់ព័ន្ធនៅក្នុងសំណុំរឿងនោះត្រូវបានហៅថា អ្នកដាក់ពាក្យសុំ និងភាគីម្ខាងទៀត។

នៅក្នុងសំណុំរឿងរដ្ឋប្បវេណីមិនមែនបណ្តឹង ការទាញហេតុដោយផ្ទាល់មាត់ជាការចាំបាច់ ដោយគប្បីមានវត្តមានរបស់គូភាគីទាំងពីរ ដោយហេតុថា បណ្តឹងនេះជាបណ្តឹងទាក់ទងនឹងឋានៈបុគ្គលរបស់ភាគី ហើយតុលាការតាមរយៈឆន្ទានុសិទ្ធិអាចសាកសួរភាគីបាន ។ ការជំនុំជម្រះសំណុំរឿងរដ្ឋប្បវេណីមិនមែនបណ្តឹងទាក់ទងនឹងការលែងលះដោយការព្រមព្រៀង ពុំត្រូវធ្វើឡើងជាសាធារណៈឡើយ ដើម្បីធានានូវការសម្ងាត់ដល់ភាគី។

នៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ តុលាការនឹងព្យាយាមសម្របសម្រួលភាគីឱ្យសះជា ជាមុនសិន មុននឹងចេញសេចក្តីសម្រេច ក្រោយពេលយល់ឃើញថា គូភាគីពិតជាមានបំណងលែងលះពីគ្នាមែន និងពុំមានបំណងសះជានោះឡើយ។

[27] មាត្រា ៦ នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីមិនមែនបណ្តឹង

## ៣. ការសម្រេចសេចក្តី

នៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ ការបង្ហាញឆន្ទៈនៃការព្រមព្រៀងលែងលះរបស់ភាគីពិតជាចំណុចមួយដែលមានសារៈសំខាន់ដើម្បីឱ្យចៅក្រមទទួលចំណាត់ការរឿងក្តីនេះ អាចធ្វើការវិនិច្ឆ័យសេចក្តីបានតាមការស្នើសុំរបស់ភាគី។ មាត្រា ៩៧៩ នៃក្រមរដ្ឋប្បវេណីបានចែងថា ភាគីនៃអាពាហ៍ពិពាហ៍អាចដាក់ពាក្យបណ្តឹងលែងលះទៅតុលាការបាន ក្នុងករណីដែលភាគីសងខាងបានព្រមព្រៀងគ្នាអំពីការលែងលះ ។ ក៏ប៉ុន្តែតុលាការអាចសម្រេចឱ្យលែងលះគ្នាបាន ក្រោយពេលដែលខ្លួនយល់ឃើញថា គូភាគីពិតជាមានបំណងក្នុងការរំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍មែន បានន័យថា ភាគីពិតជាបានបង្ហាញឆន្ទៈនៃការព្រមព្រៀងរបស់ភាគី ដែលចំណុចនេះ ជាលក្ខខណ្ឌមូលដ្ឋានមួយដែលចៅក្រមទទួលបន្ទុកចំណាត់ការមិនអាចរំលងបានឡើយ មុនពេលសម្រេចតាមការស្នើសុំរបស់ភាគី ។

នៅក្នុងការអនុវត្តជាក់ស្តែង ពេលវេលានៃការសម្តែងឆន្ទៈព្រមព្រៀងលែងលះគឺមិនមានភាពច្បាស់លាស់បានដោយហេតុថា មាននីតិវិធីក្លាយពីការដាក់ពាក្យបណ្តឹងមកនីតិវិធីដាក់ពាក្យសុំ។ ដោយដំបូងឡើយ ដើមចោទដាក់ពាក្យបណ្តឹងទាមទារដើម្បីឱ្យតុលាការចេញសាលក្រមលែងលះ នៅពេលធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលផ្ទាល់មាត់ ភាគីទាំងពីរបានព្រមព្រៀងគ្នាលើការលែងលះ និងចំណុចបន្ទាប់បន្សំផ្សេងទៀត ពេលនោះតុលាការក៏បញ្ចប់នីតិវិធីបណ្តឹងហើយចេញដីកាសម្រេចលែងលះឱ្យភាគី។

ក៏ប៉ុន្តែ ប្រសិនបើតុលាការធ្វើនីតិវិនិច្ឆ័យទទួលបាននូវមូលដ្ឋាននៃការពិចារណារួចរាល់ តុលាការ ពិនិត្យឃើញថា លក្ខខណ្ឌគ្រឹះនៃរឿងក្តីមិនបានបំពេញនោះ តុលាការនឹងសម្រេចលើកចោលពាក្យសុំរបស់អ្នកដាក់ពាក្យសុំ ។

ក្រោយពេលចេញដីកាសម្រេច ក្នុងករណីដែលផុតរយៈពេលក្នុងការធ្វើបណ្តឹងឧបាស្រ័យរបស់អ្នកខូចខាតប្រយោជន៍ នោះស្ថានភាពនៃការចូលជាស្ថាពរនឹងត្រូវកើតមានឡើងហើយដីកាសម្រេចក៏បង្កើតអានុភាព ។

### ៣.១ ដីកាសម្រេច

ដីកាសម្រេច គឺជាការសម្រេចសេចក្តីដែលតុលាការ ឬ ចៅក្រមអាចធ្វើដោយមិនឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់បាន ហើយមិនមែនជាសាលក្រម។[28] សំណុំរឿងលែងលះដោយការព្រមព្រៀងត្រូវធ្វើឡើងជាដីកាសម្រេចស្របតាមមាត្រា ៣ កថាខណ្ឌទី២ នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីមិនមែនបណ្តឹង ។ ដីកាសម្រេចដែលជាសេចក្តីសម្រេចលើអង្គសេចក្តីចំពោះការលែងលះដោយការព្រមព្រៀង

[28] មាត្រា ១៧៩ កថាខណ្ឌ ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី

ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ដោយមានសរសេរពីសំអាងហេតុនិងសេចក្តីសម្រេចបញ្ចប់ ហើយចៅក្រមត្រូវចុះហត្ថលេខាលើដីកានេះ ។

- សំអាងហេតុ៖ ចំណុចនេះចៅក្រមដែលទទួលចំណាត់ការសំណុំរឿងនេះ នឹងសរសេរពីការយល់ឃើញរបស់ខ្លួនពាក់ព័ន្ធទៅនឹងអត្ថិភាពនៃអាពាហ៍ពិពាហ៍ផ្លូវច្បាប់ មូលហេតុដែលឈានដល់ការដាក់ពាក្យសុំលែងលះ ឆន្ទៈពិតប្រាកដរបស់ភាគីលើការលែងលះ និងចំណុចពាក់ព័ន្ធផ្សេងទៀត ដែលភាគីបានព្រមព្រៀងគ្នា និងអ្នកដែលត្រូវទទួលបន្ទុកប្រាក់ប្រដាប់ក្តី ។ សំអាងហេតុនេះ គឺជាសំណេរបញ្ជាក់និងពន្យល់អំពីការសម្រេចសេចក្តីបញ្ចប់នៃដីកាសម្រេច។
- សេចក្តីសម្រេចបញ្ចប់ គឺជាការសម្រេចក្តីរបស់តុលាការឆ្លើយតបទៅនឹងការទាមទារនៅក្នុងពាក្យសុំ ។ ជាទូទៅគ្រប់ចំណុចនៃសេចក្តីសម្រេចបញ្ចប់ដាច់ខាតត្រូវមានសំអាងហេតុគាំទ្រ និងមិនអាចមានភាពផ្ទុយគ្នា ។ ប្រសិនបើតុលាការសម្រេចតាមការស្នើសុំ (ពុំសម្រេចច្រានចោលពាក្យសុំ) ចំណុចនេះត្រូវបានធ្វើឡើង ដូចតទៅ ៖

១. ឱ្យឈ្មោះ………………………និងឈ្មោះ.................................... លែងលះពីគ្នាតាមការព្រមព្រៀង (តាមមាត្រា ៩៧៩ នៃក្រមរដ្ឋប្បវេណី) ។

២. កំណត់យកម្តាយ/ឪពុកឈ្មោះ...................... ជាអ្នកមានអំណាចមេបាលើកូនឈ្មោះ................... ភេទ … កើតថ្ងៃ ....... ខែ ..... ឆ្នាំ .............. តាមការព្រមព្រៀងគ្នា (តាមមាត្រា ១០៣៧ នៃក្រមរដ្ឋប្បវេណី)។

៣. ភាគីដែលពុំមានអំណាចមេបាមានសិទ្ធិចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូនក្នុង .... សប្តាហ៍ /ខែ ..... ។ ភាគីដែលមានអំណាចមេបាលើកូនត្រូវបង្កលក្ខណៈងាយស្រួលដល់ភាគីម្ខាងទៀត (តាមមាត្រា ១០៤០ នៃក្រមរដ្ឋប្បវេណី)។ (ប្រសិនបើមានការស្នើសុំ)

៤. ឪពុក/ម្តាយឈ្មោះ .................................. ត្រូវផ្តល់សោហ៊ុយអាហារកិច្ចចាំបាច់ ដើម្បីចិញ្ចឹមថែរក្សាកូនតាមលទ្ធភាព (តាមមាត្រា ១១៤១ នៃក្រមរដ្ឋប្បវេណី) ។ (ប្រសិនបើមានការស្នើសុំ)

៥. ទ្រព្យសម្បត្តិ និងបំណុលរួមដែលត្រូវបែងចែកតាមការព្រមព្រៀងរបស់ភាគីដូចខាងក្រោម ៖

៦. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់អ្នកដាក់ពាក្យសុំ។

ក្រោយដីកាសម្រេចនោះត្រូវបានធ្វើឡើង តុលាការត្រូវជូនដំណឹងទៅជនដែលទទួលដីកាម្រេចនេះតាមរយៈការបញ្ជូន ឬការផ្ញើជូនឯកសារចម្លងយថាភូតនៃដីកាសម្រេច។

### ៣.២ ការចូលជាស្ថាពរ និងអានុភាពនៃដីកាសម្រេច

ក្នុងរឿងក្តីទូទៅដីកាសម្រេច កើតមានអានុភាពដោយការជូនដំណឹង ចំណែកឯសាលក្រមមានអានុភាពដោយការប្រកាស។ ដោយឡែកដីកាសម្រេច ចំពោះការលែងលះដោយការព្រមព្រៀងកើតមានអានុភាពដោយការចូលជាស្ថាពរ។ ដូច្នេះ បន្ទាប់ពីចេញដីកាសម្រេចតុលាការត្រូវធ្វើការជូនដំណឹងដល់ប្តីនិងប្រពន្ធ និងជាយថាហេតុអ្នកមានផលប្រយោជន៍ពាក់ព័ន្ធប្រសិនបើមាន ដើម្បីអាចចាប់ផ្តើមគិត ពេលកំណត់ដែលត្រូវចូលជាស្ថាពរបាន។

ការជូនដំណឹងនេះ អាចធ្វើតាមរយៈការបញ្ជូនឬផ្ញើឯកសារចម្លងយថាភូតនៃដីកាសម្រេច។ បន្ទាប់ ពីទទួលការជូនដំណឹងអំពីដីកាសម្រេច ក្នុងរយៈពេល ២ សប្តាហ៍ ប្រសិនបើគ្មានបណ្តឹងឧបាស្រ័យណាមួយត្រូវបានលើកឡើងនោះ ដីកាសម្រេចលែងលះដោយការព្រមព្រៀងនេះនឹងចូលជាស្ថាពរ ដោយអាជ្ញាអស់ជំនុំមានលក្ខណៈទម្រង់ និងសារធាតុដូចករណីនៃសាលក្រមស្ថាពរក៏នឹងកើតឡើងដែរ។ ម្យ៉ាងវិញទៀត ប្រសិនបើក្នុងដីកាសម្រេចនេះ បានបង្គាប់ឲ្យមានការបង់ប្រាក់ប្រគល់វត្ថុអនុវត្តករណីយកិច្ចចុះបញ្ជី ឬផ្តល់តាវកាលិកផ្សេងទៀត ត្រូវក្លាយជាលិខិតអនុវត្តដែលកំណត់នៅក្នុងមាត្រា ៣៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## ៤. បណ្តឹងឧបាស្រ័យ និងបណ្តឹងជំទាស់

ការធ្វើបណ្តឹងឧបាស្រ័យត្រង់ចំណុចនេះ ជាបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់។ យោងតាមទ្រឹស្តីនីតិវិធីរដ្ឋប្បវេណី បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ជាបណ្តឹងដែលទាមទារដោយភាគីដើម្បី សុំឱ្យតុលាការជាន់ខ្ពស់លុបចោល ឬផ្លាស់ប្តូរសេចក្តីសម្រេចដែលចេញដោយតុលាការជាន់ក្រោមនៅ មុខពេលដែលសេចក្តីសម្រេចនោះចូលជាស្ថាពរ"។

បណ្តឹងជំទាស់ជាទូទៅការធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ចំពោះដីកាសម្រេច ហើយបណ្តឹងជំទាស់នេះអាចធ្វើបានទាល់តែ មានចែងក្នុងក្រមកំណត់ជាក់លាក់ជាមុន និងអាចធ្វើបានតែម្តងគត់។ ចំពោះរឿងក្តីនៃការលែងលះដោយការព្រមព្រៀង គោលការណ៍នេះក៏ត្រូវបានយកមកអនុវត្តដែរ ។ តាមពិតទៅ ក្នុងរឿងក្តីនៃការលែងលះដោយការព្រមព្រៀងកម្រមានបណ្តឹងឧបាស្រ័យកើតឡើងណាស់ លើកលែងតែករណីដែលតុលាការសម្រេចលើកចោលពាក្យសុំ។

ភាពកម្រនេះគឺដោយមូលហេតុថា រឿងក្តីប្រភេទនេះជាសិទ្ធិនិងការចាត់ចែងជីវិតឯកជនរបស់ប្តីប្រពន្ធនៅក្នុងក្រុមគ្រួសារ ហើយជារឿងដែលភាគីព្រមព្រៀងគ្នា។ ដូច្នេះ ការសម្រេចខុសពីការទាមទាររបស់អ្នកដាក់ពាក្យសុំក៏មិនងាយមានឡើយ ។ ទោះបីយ៉ាងនេះក៏ដោយច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណី

ដែលមិនមែនជាបណ្ដឹងនៅតែចែងបង្ការទុកនូវនីតិវិធីឧបាស្រ័យ ដោយបានកំណត់នូវ រយៈពេលនៃការប្ដឹងនិងនីតិវិធីនៃដំណើរការបណ្ដឹងឧបាស្រ័យដូចខាងក្រោម ៖

## ៤.១ រយៈពេលនៃការប្ដឹងជំទាស់

ក្នុងរឿងក្ដីនៃការលែងលះដោយការព្រមព្រៀង មានតែបុគ្គលដែលជាអ្នកដាក់ពាក្យសុំ (ប្ដីឬប្រពន្ធ) ប៉ុណ្ណោះដែលមានសិទ្ធិប្ដឹង ពីព្រោះពួកគាត់ជាអ្នកធ្វើឱ្យរឿងក្ដីចាប់ផ្ដើមដំណើរការ មិនមែនរឿងក្ដីកើតឡើងដោយឆន្ទានុសិទ្ធិនោះទេ។ រយៈពេលនៃការប្ដឹងជំទាស់នេះគឺ ០២ សប្ដាហ៍ ដោយគិតចាប់ពីថ្ងៃបានទទួលការជូនដំណឹងអំពីដីកាសម្រេច ។ ប៉ុន្តែរយៈពេលនេះអាចត្រូវបន្ថែមឱ្យចំនួន ០១ សប្ដាហ៍ទៀត ក្នុងករណីដែលជនអាចប្ដឹងជំទាស់បានមិនគោរពរយៈពេលនៃការប្ដឹងជំទាស់ ដោយគ្មានកំហុសហើយត្រូវបន្ថែមឱ្យចំនួន ០២ ខែ ចំពោះជនដែលមានសិទ្ធិប្ដឹងជាជនបរទេស។ ក្នុងករណីមានការប្ដឹងជំទាស់នៅក្នុងអំឡុងពេលនេះ ការចូលជាស្ថាពរនៃដីកាសម្រេចត្រូវបង្អាក់ ដូច្នេះអានុភាពនៃដីកាសម្រេចក៏មិនកើតមានដែរ មានន័យថាត្រូវរង់ចាំសេចក្ដីសម្រេចថ្មីពីតុលាការនៃបណ្ដឹងជំទាស់ (សាលាឧទ្ធរណ៍)។

## ៤.២ នីតិវិធីនៃការប្ដឹងជំទាស់

ពាក្យបណ្ដឹងជំទាស់ត្រូវយកទៅដាក់នៅ ការិយាល័យរដ្ឋបាលនិងទទួលពាក្យបណ្ដឹងនៃតុលាការដើមដែលចេញដីកាសម្រេច គឺមិនមែនយកទៅដាក់នៅសាលាឧទ្ធរណ៍តែម្ដងនោះទេ។ ពេលដាក់ពាក្យប្ដឹងជំទាស់អ្នកដាក់ពាក្យសុំត្រូវបង់ពន្ធដាក់ពាក្យសុំចំនួន ៥.០០០ (ប្រាំពាន់) រៀល ។ បន្ទាប់មកពាក្យបណ្ដឹងជំទាស់នោះនឹងត្រូវបញ្ជូនទៅចៅក្រមទទួលបន្ទុក (ចៅក្រមដែលចេញដីកាសម្រេច)។ ចៅក្រមនោះ នឹងបង្គាប់ឱ្យក្រឡាបញ្ជីថតចម្លងលិខិតនៃសំណុំរឿងទាំងអស់ ដោយមានបញ្ជាក់ថាបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម រួចបញ្ជូនសំណុំរឿងថតចម្លងនោះជាមួយពាក្យប្ដឹងជំទាស់ទៅកាន់សាលាឧទ្ធរណ៍យ៉ាងឆាប់រហ័ស (ជាទូទៅមិនលើសរយៈពេលពីរសប្ដាហ៍)។ ចំណែកឯសំណុំរឿងដើមដែលជាសំណុំរឿងបង្ការត្រូវរក្សាទុកនៅក្រឡាបញ្ជីនោះ ក្រោមការចាត់ចែងរបស់ចៅក្រមទទួលបន្ទុក។

ចំពោះការការជំនុំជម្រះលើបណ្ដឹងជំទាស់ តុលាការត្រូវអនុវត្តតាមបញ្ញត្តិនៃជំពូកទី៤ (បណ្ដឹងជំទាស់) គន្ថីទី៣ (បណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់) នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

ដើម្បីប្ដឹងជំទាស់ ភាគីត្រូវដាក់ពាក្យបណ្ដឹងជំទាស់ទៅតុលាការដើម ។ នៅក្នុងករណីនេះ តុលាការដើម ត្រូវធ្វើឱ្យបានឆាប់រហ័ស នូវពាក្យបណ្ដឹងជំទាស់ និង សំណុំរឿង ទៅតុលាការនៃបណ្ដឹងជំទាស់ ។ នៅពេលដែលភាគីប្ដឹងជំទាស់ ដើមបណ្ដឹងជំទាស់មានកាតព្វកិច្ចជាដាច់ខាតក្នុងការដាក់លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្ដឹងសាទុក្ខមកតុលាការនៃបណ្ដឹងជំទាស់ ក្នុងរយៈពេល ២ សប្ដាហ៍ គិតចាប់ពីកាលបរិច្ឆេទដែលបានដាក់ពាក្យបណ្ដឹងជំទាស់។

# ជំពូកទី៣
# នីតិវិធីនៃការលែងលះដោយការដាក់ពាក្យបណ្តឹង

# ជំពូកទី៣ នីតិវិធីនៃការលែងលះដោយការដាក់ពាក្យបណ្តឹង

ក្នុងករណីដែលប្តីប្រពន្ធមានបំណងចង់លែងលះពីគ្នា ក៏ប៉ុន្តែពុំមានការព្រមព្រៀងពីភាគីម្ខាងទៀតនៃចំណងអាពាហ៍ពិពាហ៍នោះ ភាគីដែលមានបំណងចង់លែងលះអាចដាក់ពាក្យបណ្តឹងទៅតុលាការមានសមត្ថកិច្ច ដើម្បីឱ្យតុលាការចេញសាលក្រមជូន ឬអាចដាក់ទៅឃុំសង្កាត់នៃលំនៅដ្ឋានរបស់ប្តីប្រពន្ធបាន។

ភាគីណាមួយដែលជាសហព័ន្ធប្តី ឬប្រពន្ធ មានពិតប្រាកដក្នុងការលែងលះគ្នា ដោយផ្អែកលើមូលហេតុត្រឹមត្រូវ អាចដាក់ពាក្យបណ្តឹងទៅតុលាការដែលមានសមត្ថកិច្ច ដែលបានកំណត់ក្នុងបញ្ញត្តិមាត្រា ១០ នៃក្រមនីតិវិធីរដ្ឋប្បវេណី[29] ដែលចែងពីសមត្ថកិច្ចសាលាជម្រះក្តីពិសេសលើរឿងក្តីលែងលះគ្នា និងរឿងក្តីអំពីបុគ្គភាព ។ ក្រៅពីភាគីដែលអាចដាក់ពាក្យសុំលែងលះគ្នាទៅក្រុមប្រឹក្សាឃុំសង្កាត់ ខាងលំនៅឋាន ទីសំណាក់ ដូចបានកំណត់ក្នុងកថាខ័ណ្ឌទី១ និង៣ នៃមាត្រា ១០ នៃក្រមនីតិវិធីរដ្ឋប្បវេណីបាន។

## ១. ការដាក់ពាក្យសុំទៅឃុំសង្កាត់

នៅពេលដែលប្តីប្រពន្ធរស់នៅមិនចុះសម្រុងគ្នា ឬមានមូលហេតុណាមួយដែលកំណត់ក្នុងមាត្រា ៩៤៦ នៃក្រមរដ្ឋប្បវេណី ប្តីប្រពន្ធអាចដាក់ពាក្យសុំលែងលះទៅសាលាឃុំសង្កាត់នៃលំនៅឋានរបស់ខ្លួនដើម្បីដោះស្រាយ។

ក្រុមប្រឹក្សាឃុំសង្កាត់អាចធ្វើការបញ្ចុះបញ្ចូលឱ្យគូភាគីសះជាគ្នាក្នុងអំឡុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីបានទទួលពាក្យសុំនោះ។ ប្រសិនបើក្រុមប្រឹក្សាឃុំសង្កាត់ពុំអាចបញ្ចុះបញ្ចូលឱ្យសះជាគ្នាបាននោះ ត្រូវចាត់ទុកថាមានពាក្យបណ្តឹងលែងលះគ្នា ហើយក្រុមប្រឹក្សាឃុំសង្កាត់ ត្រូវបញ្ជូនពាក្យបណ្តឹងនោះទៅតុលាការជាបន្ទាន់ ។

## ២. ការដាក់ពាក្យបណ្តឹងទៅតុលាការមានសមត្ថកិច្ច

ភាគីដែលមានបំណងចង់លែងលះត្រូវដាក់ពាក្យបណ្តឹង ដោយភ្ជាប់ជាមួយនឹងឯកសារជាភស្តុតាងមួយចំនួនទៅលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងនៃតុលាការដែលមានសមត្ថកិច្ច រួចធ្វើការបង់ពន្ធ (ពន្ធដាក់ពាក្យសុំ) ។ បន្ទាប់ពីមន្ត្រីរដ្ឋបាលដែលទទួលបានពាក្យបណ្តឹងធ្វើការចុះបញ្ជីនិងបោះត្រាចូល

[29] មាត្រា ៩៨២ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

លើពាក្យបណ្តឹង នោះរដ្ឋបាលនឹងធ្វើការបញ្ជូនពាក្យបណ្តឹងនោះទៅចៅក្រមទទួលបន្ទុក តាមមាត្រា ២៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ពាក្យបណ្តឹងនេះ ត្រូវធ្វើឡើងស្របតាមមាត្រា ៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដោយរួមបញ្ចូលនឹងចំណុចដូចតទៅ[30]៖

- ឈ្មោះ ឬនាមការណ៍ និងអាសយដ្ឋាន របស់ភាគី
- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់
- ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ
- អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ
- អង្គហេតុដែលជាមូលហេតុនៃការទាមទារ

## ៣. ការជំនុំជម្រះនៅជាន់សាលាដំបូង

### ៣.១ ការពិនិត្យពាក្យបណ្តឹង

បន្ទាប់ពីចៅក្រមទទួលបានសំណុំរឿង នោះត្រូវពិនិត្យពាក្យបណ្តឹងដែលត្រូវពិនិត្យចំណុចដូចតទៅៈ

- តើពាក្យបណ្តឹងសរសេរត្រឹមត្រូវតាមមាត្រា៧៥ កថាខណ្ឌទី២ ឬនៅ?
- តើដើមចោទបានបង់ពន្ធដាក់ពាក្យសុំរួចឬនៅ?
- តើបណ្តឹងផ្ទុយច្បាប់ដែរឬទេ?

តុលាការនឹងធ្វើការពិនិត្យពាក្យបណ្តឹង ហើយក្នុងករណីដែលតុលាការយល់ឃើញថា ពាក្យបណ្តឹងនេះ ធ្វើឡើងផ្ទុយនឹងមាត្រា ៧៥ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី នោះតុលាការអាចបង្គាប់ឱ្យម្ចាស់បណ្តឹងកែតម្រូវពាក្យបណ្តឹងនេះ ដោយកំណត់អំឡុងពេលសមរម្យជូនបាន។ ចំណុចនេះត្រូវអនុវត្តចំពោះការបង់ពន្ធដាក់ពាក្យសុំផងដែរ ក្នុងករណីដែលម្ចាស់បណ្តឹងពុំបានបង់ពន្ធ នោះតុលាការអាចចេញដីកាបង្គាប់ឱ្យម្ចាស់បណ្តឹង បង់ពន្ធដោយកំណត់អំឡុងពេលសមរម្យជូន។

[30] មាត្រា ៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៧

## ៣.២ ការកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

ក្រោយពីបានពិនិត្យពាក្យបណ្តឹងរួច តុលាការនឹងធ្វើការកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលយ៉ាងយូរ ៣០ថ្ងៃ គិតចាប់ពីថ្ងៃដែលពាក្យបណ្តឹងត្រូវបានដាក់ លើកលែងតែក្នុងករណីពិសេសតែប៉ុណ្ណោះ។

ពាក្យបណ្តឹងត្រូវបញ្ជូន ទៅចុងចម្លើយជាចាំបាច់ ហើយការបញ្ជូននេះអាចធ្វើឡើងតាមវិធីជាច្រើន ដូចមានចែងក្នុងផ្នែក ២ ជំពូកទី៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីស្តីពីការបញ្ជូន ជាឧទាហរណ៍ ក្នុងករណីដែលចុងចម្លើយមិនមានអាសយដ្ឋានច្បាស់លាស់ ទោះបីជាដើមចោទប្រឹងប្រែងស្រាវជ្រាវយ៉ាងណាក៏ដោយ ក៏ដើមចោទអាចអាចដាក់ពាក្យសុំឱ្យធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈ បានផងដែរ។

ជាដំណាក់កាលដើមដំបូងមួយនៃនីតិវិធីក្នុងការដោះស្រាយសំណុំរឿងរដ្ឋប្បវេណីដែលធ្វើឡើង ដើម្បីផ្តល់ឱកាសដល់គូភាគីថ្លែងការណ៍ អំពីពាក្យបណ្តឹងរបស់ខ្លួនត្រៀមរៀបចំសេចក្តីអះអាងបំភ្លឺនូវចំណុចវិវាទ ដែលភាគីយល់មិនស្របគ្នានិងរៀបចំភស្តុតាង ដែលទាក់ទងនឹងចំណុចវិវាទនៅមុនពេលចាប់ផ្តើមកាលបរិច្ឆេទទាញហេតុផលដោយផ្ទាល់មាត់។

ជាដំបូង តុលាការនឹងធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ ដើម្បីកំណត់ចំណុចវិវាទ និងដើម្បីឱ្យភាគីដាក់ភស្តុតាងបន្ថែមក្នុងករណីដែលតុលាការយល់ឃើញថា មានការខ្វះខាត។ នៅក្នុងនីតិវិធីនេះ តុលាការក៏អាចធ្វើការផ្សះផ្សារវាងគូក្តីផងដែរ ក៏ប៉ុន្តែក្នុងករណីដែលគូក្តីនៅតែពុំមានបំណងផ្សះផ្សានោះ តុលាការនឹងត្រូវបន្តនីតិវិធីរឿងក្តីនេះ។

## ៣.៣ ការទាញហេតុផលដោយផ្ទាល់មាត់

ក្រោយពេលដែលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ គូក្តីត្រូវដាក់សេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមជូនតុលាការពិនិត្យ ដោយក្នុងសេចក្តីថ្លែងការណ៍នេះ ភាគីត្រូវចង្អុលបង្ហាញឱ្យបានច្បាស់លាស់នូវអង្គហេតុដែលនឹងត្រូវបញ្ជាក់ដោយការពិនិត្យភស្តុតាង។ ភាគីអាចអះអាងបន្ថែមទៀតអំពីអង្គហេតុនិងដាក់ភស្តុតាងមកទៀតបាន ក្នុងករណីដែលការអះអាងអំពីអង្គហេតុ ឬការដាក់ភស្តុតាងនោះមិនផ្ទុយនឹងមាត្រា ១០៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដែលបញ្ញត្តិអំពីអានុភាពនៃការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់។

ដោយហេតុថា ការសម្រេចសេចក្តីលើពាក្យបណ្តឹងលែងលះ អាចមានភាពស្មុគស្មាញទៅតាមករណីនីមួយៗ តុលាការអាចយកអង្គហេតុដែលមិនបានអះអាងដោយភាគីមកធ្វើជាមូលដ្ឋាន នៃសាលក្រមបានស្របតាមមាត្រា ១៤ នៃច្បាប់ស្តីពីនីតិវិបណ្តឹងទាក់ទងនឹងឋានៈបុគ្គល តាមគោលការណ៍តុលាការសកម្ម និងអាចបង្គាប់ឱ្យភាគីនោះមកបង្ហាញខ្លួនតាមកាលបរិច្ឆេទបាន ក្នុងករណីដែលតុលាការ

មានបំណងសាកសួរភាគីដោយផ្ទាល់។ ក្នុងករណីដែលត្រូវមានការកំណត់អំណាចមេបានោះ តុលាការកំណត់អ្នកមានអំណាចមេបាដោយឆន្ទានុសិទ្ធិ តាមមាត្រា២២ នៃច្បាប់ស្តីពីនីតិវិបណ្តឹងទាក់ទងនឹងឋានៈបុគ្គល។

ជាគោលការណ៍ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ និងការទាញហេតុផលដោយផ្ទាល់មាត់នេះ មិនត្រូវធ្វើជាសាធារណៈឡើយ ។

ក្រោយពេលដែលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នោះ តុលាការនឹងធ្វើការកំណត់កាលបរិច្ឆេទសម្រាប់ការប្រកាសសាលក្រមជាសាធារណៈ។

**សម្គាល់៖** ករណីដែលដើមចោទឬចុងចម្លើយ បានទទួលមរណភាពនៅពេលដែលបណ្តឹងនេះកំពុងត្រូវបានចាត់ការ នោះបណ្តឹងត្រូវចប់ដោយស្វ័យប្រវត្តិ។[31]

## ៣.៤ ការចេញសាលក្រម

ការសម្រេចសេចក្តីក្នុងបណ្តឹងលែងលះ ត្រូវធ្វើឡើងដោយចេញជាសាលក្រម។ សាលក្រម គឺជាការសម្រេចសេចក្តីដែលតុលាការធ្វើលិខិតសាលក្រមដែលមានលក្ខណៈគ្រប់គ្រាន់ ទៅតាមទម្រង់ដែលច្បាប់បានកំណត់ ដោយផ្អែកលើការទាញហេតុផលដោយផ្ទាល់មាត់ លើកលែងតែក្នុងករណីដែលមានកំណត់ពិសេសនៅក្នុងក្រមនេះ ឬ នៅក្នុងច្បាប់ផ្សេង ហើយកើតអានុភាពដោយការប្រកាស ដោយផ្អែកលើលិខិតសាលក្រមនោះ ។[32]

នៅក្នុងសាលក្រមដែលត្រូវបានប្រកាសជាសាធារណៈនោះត្រូវមានចំណុចដូចតទៅ៖[33]

- តុលាការ (តុលាការដែលជំនុំជម្រះលើសំណុំរឿងក្តីនោះ)
- កាលបរិច្ឆេទដែលបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់
- ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់ភាគី និង ឈ្មោះនិងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់
- អង្គហេតុនិងចំណុចវិវាទ (ចំពោះចំណុចនេះ តុលាការនឹងកត់ត្រានូវខ្លឹមសារសំខាន់ ដែលបានលើកឡើងដោយភាគីនៅក្នុងសេចក្តីថ្លែងការណ៍ ក្នុងនីតិវិធីរឿងក្តី)
- សំអាងហេតុ

[31] មាត្រា ១៩ និងមាត្រា ២០ ច្បាប់ស្តីពីនីតិវិបណ្តឹងទាក់ទងនឹងឋានៈបុគ្គល

[32] មាត្រា ១៧៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី

[33] មាត្រា ១៨៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី

- សេចក្តីសម្រេចបញ្ចប់ (សេចក្តីវិនិច្ឆ័យរបស់តុលាការ)

ចៅក្រមដែលទទួលបន្ទុកលើចំណាត់ការនៃសំណុំរឿងក្តីនោះ នឹងធ្វើការចុះហត្ថលេខានៅលើសាលក្រមនោះផងដែរ។

ការប្រកាសសាលក្រមមានសារៈសំខាន់ណាស់ដោយមូលហេតុថា សាលក្រមនឹងមានអានុភាពដោយការប្រកាស។[34] ការប្រកាសសាលក្រម ត្រូវធ្វើឡើងក្នុងអំឡុងពេល ១ (មួយ) ខែ គិតចាប់ពីថ្ងៃដែលបានបញ្ចប់នូវការទាញហេតុផលដោយផ្ទាល់មាត់។ រីឯចំពោះរឿងក្តីដែលមានភាពស្មុគស្មាញខ្លាំងឬ មានកាលៈទេសៈពិសេសផ្សេងទៀត បញ្ញត្តិនេះមិនត្រូវយកមកអនុវត្ត ។

ការប្រកាសសាលក្រមត្រូវធ្វើឡើងតាមកាលបរិច្ឆេទ នៅក្នុងសាលសវនាការដែលបើកជាសាធារណៈដោយចៅក្រមទទួលបន្ទុកចំណាត់ការសំណុំរឿងនោះ ជាអ្នកអានសេចក្តីសម្រេចបញ្ចប់ដោយផ្អែកលើច្បាប់ដើមនៃមូលសាលក្រម ។

ការប្រកាសសាលក្រមអាចធ្វើបាន ទោះបីជាគ្មានវត្តមានរបស់គូភាគីនៅក្នុងសាលសវនាការក៏ដោយ ។ ក្នុងករណីដែលប្រធានក្រុមប្រឹក្សាជំនុំជម្រះយល់ឃើញថាសមរម្យ អាចអានសំអាងហេតុនៃសាលក្រម ឬ អាចពន្យល់ខ្លឹមសារនៃសំអាងហេតុនោះដោយផ្ទាល់មាត់បាន ។

លិខិតសាលក្រមត្រូវបញ្ជូនទៅឱ្យគូភាគីក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ ដោយគិតចាប់ពីថ្ងៃដែលបានប្រកាសសាលក្រមនោះ ដោយការបញ្ជូននេះ ត្រូវឡើងដោយអនុសារសាលក្រម ។ ក៏ប៉ុន្តែ សាលក្រមមិនអាចចូលជាស្ថាពរ នៅមុនពេលផុតអំឡុងពេលដែលបានកំណត់ សម្រាប់ការប្តឹងឧបាស្រ័យ ទៅតុលាការជាន់ខ្ពស់ដែលស្របច្បាប់ ឬ ការប្តឹងទាស់ដែលស្របច្បាប់បានទេ ដោយហេតុថាការចូលជាស្ថាពរនៃសាលក្រម នឹងត្រូវបានបង្អាក់ ដោយការដាក់ពាក្យបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ឬ ពាក្យបណ្តឹងទាស់ ដែលត្រូវបានធ្វើឡើងក្នុងអំឡុងពេលដែលបានកំណត់ក្នុងសាលក្រម ។

## ៤. បណ្តឹងឧបាស្រ័យ

បណ្តឹងឧបាស្រ័យ គឺជាបណ្តឹងរបស់ភាគីដែលមិនយល់ស្របជាមួយនឹងសេចក្តីសម្រេចណាមួយរបស់ចៅក្រមដើម្បីទាមទារឱ្យលុបចោល ឬផ្លាស់ប្តូរសេចក្តីសម្រេចដើម។ ដោយបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ គឺជាវិធីធ្វើឧបាស្រ័យទាមទារដោយភាគី ទៅតុលាការជាន់ខ្ពស់ឱ្យលុបចោល ផ្លាស់ប្តូរនូវសេចក្តីសម្រេច (សាលក្រម សាលដីកា ឬ ដីកាសម្រេច) ដែលចេញដោយតុលាការថ្នាក់ក្រោម នៅមុនពេលដែលសេចក្តីសម្រេចនោះចូលជាស្ថាពរ ។

[34] មាត្រា ១៨៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី

បណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ អាចធ្វើទៅបានតែមុនពេលដែលសេចក្ដីសម្រេចនោះចូលជាស្ថាពរតែប៉ុណ្ណោះ ពេលដែលមានបណ្ដឹងឧបាស័យទៅតុលាការជាន់ខ្ពស់ សេចក្ដីសម្រេចដើមមិនចូលជាស្ថាពរ រហូតដល់ដំណើរការឧបាស្រ័យទៅតុលាការជាន់ខ្ពស់នោះបានបញ្ចប់ (មាត្រា ១៩៣ កថាខណ្ឌទី ២) ផ្ទុយទៅវិញ គេអាចនិយាយបានថា ការចូលជាស្ថាពរនៃសេចក្ដីសម្រេចមួយ គឺជាស្ថានភាពមួយដែលសេចក្ដីសម្រេចនោះ មិនអាចធ្វើឧប្រាស័យទៅតុលាការជាន់ខ្ពស់បាន ។

រីឯចំពោះបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី តាមខ្លឹមសារនៃមាត្រា ៣០៧ និងមាត្រា ៣១៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី គឺជាការប្ដឹងឧបាស្រ័យ ចំពោះសាលក្រមដែលបានចូលជាស្ថាពរហើយ ហេតុដូច្នេះ មិនមនជាបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ទេ ។

គោលបំណងនៃរបបបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ គឺដើម្បីទាមទារឱ្យតុលាការជាន់ខ្ពស់ធ្វើការកែប្រែ ផ្លាស់ប្ដូរ ឬលុបចោលសម្រេចសេចក្ដីរបស់សាលាដំបូង ឬអាចហៅបានថាតុលាការជាន់ទាប ដែលបានធ្វើការវិនិច្ឆ័យខុស ឬ ការភ័ន្តច្រឡំ ដែលអាចនឹងកើតមាន ។ ក៏ប៉ុន្តែ ប្រសិនបើទុកឱ្យស្ថានភាពនៅតដូច្នេះៈ កំហុសនោះ គឺមិនត្រឹមតែបំពានសិទ្ធិរបស់ភាគីប៉ុណ្ណោះទេ គឺធ្វើឱ្យបាត់នូវជំនឿទុកចិត្តចំពោះប្រព័ន្ធតុលាការនោះតែម្ដង ។ ដូច្នេះហើយ ចាំបាច់ត្រូវមាននូវប្រព័ន្ធមួយ ដែលតាមរយៈនោះ តុលាការជាន់ខ្ពស់អាចនឹងពិនិត្យមើលនូវសេចក្ដីសម្រេចរបស់តុលាការថ្នាក់ក្រោមបាន តាមពាក្យសុំរបស់ភាគីម្ខាង ឬ គូភាគី ដែលមិនសុខចិត្តចំពោះសេចក្ដីសម្រេចនោះ ហើយប្រសិនបើសេចក្ដីសម្រេចថ្នាក់ក្រោមនោះ មិនត្រឹមត្រូវតុលាការថ្នាក់ខ្ពស់ជាងនោះអាចធ្វើការកែប្រែ ឬ លុបចោលនូវសេចក្ដីសម្រេចនោះបាន ។ នេះគេហៅថា "របបប្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ដែលជាប្រព័ន្ធមួយដែលតុលាការជាន់ខ្ពស់កែតម្រូវនូវសេចក្ដីសម្រេចរបស់តុលាការថ្នាក់ក្រោម ដោយរង់ចាំពាក្យសុំឧបាស្រ័យ ហេតុដូច្នេះយើងអាចហៅផងដែរថា របបបណ្ដឹងដោយសារឧបាស្រ័យទៅតុលាការជាន់ខ្ពស់ គឺជាយន្តការមួយសម្រាប់ ធ្វើការសង្គ្រោះសិទ្ធិភាគីឱ្យរួចផុតពីឥទ្ធិពលនៃការវិនិច្ឆ័យខុស ឬ កំហុសក្នុងនីតិវិធីនៃការជំនុំជម្រះ ។

តាមរយៈការអនុញ្ញាតឱ្យធ្វើបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ មានរឿងក្ដីជាច្រើនដែលត្រូវបានពិនិត្យ និង ធ្វើការជំនុំជម្រះសារឡើងវិញ ដោយតុលាការជាន់ខ្ពស់មួយចំនួនតូច ហើយចុងបំផុតគឺត្រូវជម្រះដោយតុលាការជាន់ខ្ពស់គឺ តុលាការកំពូល ។ ជាលទ្ធផល ការបកស្រាយ និង អនុវត្តច្បាប់តែមួយផ្សេងៗគ្នា នៅតុលាការជាន់ទាបដ៏ច្រើននោះ នឹងត្រូវបានបង្រួបបង្រួមឱ្យក្លាយទៅជាការបកស្រាយ និង អនុវត្តមួយដោយតុលាការកំពូល ។ ក្នុងន័យនេះ ក្នុងការច្របាច់បញ្ចូលគ្នានូវប្រព័ន្ធជម្រះ ដែលមានបីថ្នាក់ របបបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ មានតួនាទីធ្វើការរួមបញ្ចូលនូវការបកស្រាយច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ហើយ

ដោយសារប្រព័ន្ធនោះ គឺអាចធានានូវប្រព័ន្ធគតិយុត្តដែលប្រកបដោយស្ថិរភាព មានសណ្តាប់ធ្នាប់ និង ប្រកបដោយគុណភាព សម្រាប់ពលរដ្ឋកម្ពុជា ។

បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ចំពោះការសម្រេចសេចក្តីដែល មិនទាន់ចូលជាស្ថាពរមាន ចំនួន ៣ ប្រភេទ៖

ក. បណ្តឹងឧទ្ធរណ៍៖ ការប្តឹងឧទ្ធរណ៍ចំពោះសាលក្រមរបស់សាលាដំបូង ឬ បណ្តឹងសាទុក្ខ ក្នុងករណីមានការព្រមព្រៀងរវាងភាគីដែលបានកំណត់នៅក្នុងចំណុច ក កថាខណ្ឌទី ១ នៃ មាត្រា២៦០ (សាលក្រមដែលអាចប្តឹងឧទ្ធរណ៍បាន ជាអាទិ៍) នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

ខ. បណ្តឹងសាទុក្ខ ចំពោះសាលដីការបស់តុលាការនៃបណ្តឹងឧទ្ធរណ៍ ។

គ. បណ្តឹងជំទាស់ ចំពោះដីកាសម្រេច ។

## ៤.១ បណ្តឹងឧទ្ធរណ៍

បណ្តឹងឧទ្ធរណ៍ គឺជាបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ចំពោះសាលក្រមចុងក្រោយនៃការជំនុំជម្រះលើកទី១ របស់សាលាដំបូង ក្នុងគោលបំណងឱ្យតុលាការជាន់ខ្ពស់លុបចោល ឬផ្លាស់ប្តូរនូវសាលក្រមចុងក្រោយ។

តុលាការដែលធ្វើការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ត្រូវបានហៅថា តុលាការនៃបណ្តឹងឧទ្ធរណ៍។ សព្វថ្ងៃតុលាការដែលមានសមត្ថកិច្ចជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍មានចំនួន ៤ គឺ សាលាឧទ្ធរណ៍ភ្នំពេញ សាលាឧទ្ធរណ៍បាត់ដំបង សាលាឧទ្ធរណ៍ព្រះសីហនុ និងសាលាឧទ្ធរណ៍ត្បូងឃ្មុំ។

បណ្តឹងឧទ្ធរណ៍ អាចធ្វើឡើងដោយដើមចោទ ឬ ចុងចម្លើយ ដែលបានបាត់បង់ផលប្រយោជន៍ដោយសារសាលក្រមរបស់សាលាដំបូង។ ភាគីដែលបាត់បង់ផលប្រយោជន៍ ឬអាចហៅបានថា ចាញ់ក្តីមួយផ្នែក ឬទាំងស្រុង មានសិទ្ធិក្នុងការធ្វើបណ្តឹងឧទ្ធរណ៍ ។ ផ្ទុយទៅវិញ ភាគីដែលឈ្នះក្តីទាំងស្រុងពុំអាចធ្វើបណ្តឹងឧទ្ធរណ៍បានឡើយ ក្នុងករណីដែលភាគីឈ្នះក្តីនោះធ្វើបណ្តឹងឧទ្ធរណ៍ តុលាការដែលជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នោះអាចលើកចោលបណ្តឹងឧទ្ធរណ៍នេះ ដោយមូលហេតុបណ្តឹងនេះធ្វើឡើងផ្ទុយនឹងច្បាប់។

បណ្តឹងឧទ្ធរណ៍ ជាចាំបាច់ត្រូវធ្វើឡើងក្នុងអំឡុងពេល ១ ខែ គិតចាប់ពីពេលដែលភាគីបានទទួលការបញ្ជូនលិខិតសាលក្រម ។ ជាឧទាហរណ៍ ប្រសិនបើ ចុងចម្លើយដែលចាញ់ក្តីបានទទួលការបញ្ជូនលិខិតសាលក្រមនៅថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០២៣ នោះចុងចម្លើយមានពេលត្រឹមថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០២៣ ដើម្បី

ដាក់ពាក្យបណ្ដឹងឧទ្ធរណ៍ ។ ក្នុងករណីដែលចុងចម្លើយខកខានពុំបានដាក់បណ្ដឹងឧទ្ធរណ៍ក្នុងអំឡុងពេលនេះ នោះសាលក្រមនឹងចូលជាស្ថាពរ។

នៅពេលដែលភាគីបានដាក់ពាក្យបណ្ដឹងឧទ្ធរណ៍ចូលមកតុលាការដែលបានជំនុំជម្រះ និងចេញសាលក្រមនោះ ការចូលស្ថាពរនៃសាលក្រមនឹងត្រូវបានបង្អាក់។ ការបង្អាក់នេះនឹងមានអានុភាពលើសេចក្ដីសម្រេចទាំងមូល ទោះបីជាភាគីបានប្ដឹងឧទ្ធរណ៍តែលើមួយផ្នែកនៃសាលក្រមក៏ដោយ។

## ៤.១.១ របៀបធ្វើបណ្ដឹងឧទ្ធរណ៍

ដើម្បីប្ដឹងឧទ្ធរណ៍ ភាគីត្រូវដាក់បណ្ដឹងឧទ្ធរណ៍នេះទៅតុលាការដើមគឺសាលាដំបូង ឬតុលាការដែលចេញសាលក្រមដែលភាគីមានបំណងប្ដឹងឧទ្ធរណ៍[35]។ ពាក្យបណ្ដឹងឧទ្ធរណ៍នេះ ត្រូវសរសេរជាលាយលក្ខណ៍អក្សរដោយបញ្ជាក់អំពី៖

- អត្តសញ្ញាណរបស់ភាគី៖

ដើមបណ្ដឹងឧទ្ធរណ៍ ឈ្មោះ “...........................” មានអាសយដ្ឋានស្ថិតនៅ.......................

ចុងបណ្ដឹងឧទ្ធរណ៍ ឈ្មោះ “...........................” មានអាសយដ្ឋានស្ថិតនៅ.......................

- សញ្ញាណនៃសាលក្រម៖

សាលក្រមរដ្ឋប្បវេណីលេខ ........................ ចុះថ្ងៃទី .......... ខែ ............ ឆ្នាំ ............ របស់សាលាដំបូង.................................

- សេចក្ដីប្ដឹងឧទ្ធរណ៍៖

ឧទាហរណ៍ក្នុងសាលក្រមដែលភាគីបានប្ដឹងឧទ្ធរណ៍បានសម្រេចសេចក្ដីថា ៖

១. ដើមចោទ ឈ្មោះ ....................... លែងលះ ពីចុងចម្លើយឈ្មោះ ......................

២. បង្គាប់ឱ្យចុងចម្លើយ ឈ្មោះ ........................... ធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិលើដី ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ...................... ចេញនៅថ្ងៃទី .......... ខែ ............ ឆ្នាំ........ ដោយមន្ទីររៀបចំដែនដី នគរូបនិយកម្ម សំណង់ និងសុរិយោដីខេត្តតាកែវ មកឱ្យដើមចោទ ឈ្មោះ ....... ចំណែកពាក់កណ្ដាល។

[35] មាត្រា ២៦៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី

ដូច្នេះ សេចក្តីដែលប្តឹងឧទ្ធរណ៍៖ ប្តឹងឧទ្ធរណ៍នឹងសេចក្តីសម្រេចបញ្ចប់ត្រង់ចំណុចទី២ នៃសាលក្រម រដ្ឋប្បវេណីលេខ ........................ ចុះថ្ងៃទី ........... ខែ ............ ឆ្នាំ ............ របស់សាលាដំបូង .................................

- មូលហេតុនៃបណ្តឹងឧទ្ធរណ៍៖ អ្នកប្តឹងត្រូវរៀបរាប់អំពីកំហុសនីតិវិធីធ្ងន់ធ្ងរ ឬកំហុសក្នុងសេចក្តីសម្រេចនៃសាលក្រម ដែលមានភាពពុំត្រឹមត្រូវ។

**ចំណាំ៖** ទោះបីជាពាក្យបណ្តឹងឧទ្ធរណ៍ត្រូវបានដាក់រួចក៏ដោយ ក៏ភាគីដែលដាក់ពាក្យបណ្តឹងនេះ នៅមានសិទ្ធិក្នុងការដកពាក្យបណ្តឹងនេះនៅពេលណាក៏បាន មុនពេលដែលសាលាឧទ្ធរណ៍បានប្រកាសសាលដីកា។ ការដកនេះ នឹងនាំឱ្យមានការបញ្ចប់នូវនីតិវិធីបណ្តឹងលើបណ្តឹងឧទ្ធរណ៍ ហើយតុលាការគឺសាលាឧទ្ធរណ៍នឹងចេញកំណត់ហេតុដកពាក្យបណ្តឹងឧទ្ធរណ៍ជូនភាគី។

### ៤.១.២ ពន្ធដាក់ពាក្យសុំ

ពន្ធដាក់ពាក្យបណ្តឹងឧទ្ធរណ៍ ត្រូវគណនាទៅតាមតម្លៃនៃកម្មវត្ថុនៃបណ្តឹង និងមានតម្លៃ ១.៥ដង នៃពន្ធដាក់ពាក្យបណ្តឹងនៅតុលាការជាន់ទាប ហើយកាតព្វកិច្ចក្នុងការបង់ពន្ធដាក់ពាក្យបណ្តឹងឧទ្ធរណ៍គឺជាកាតព្វកិច្ចដាច់ខាតដែលភាគីអ្នកដាក់បណ្តឹងត្រូវបំពេញ បើមិនដូច្នោះតុលាការនឹងលើកចោលពាក្យបណ្តឹងឧទ្ធរណ៍នោះ។

រីឯចំពោះករណីដែលភាគីដកពាក្យបណ្តឹងឧទ្ធរណ៍មុនពេលកាលបរិច្ឆេទ នៃការទាញហេតុផលដោយផ្ទាល់មាត់លើកដំបូងនោះ ដើមបណ្តឹងឧទ្ធរណ៍អាចដាក់ពាក្យសុំបង្វិលពាក់កណ្តាលនៃពន្ធដាក់ពាក្យសុំបាន។

### ៤.១.៣ ការជំនុំជម្រះបណ្តឹងឧទ្ធរណ៍

#### ៤.១.៣.១ ការទទួល ពិនិត្យ និងបញ្ជូនបណ្តឹងឧទ្ធរណ៍

ភាគីដែលមានបំណងប្តឹងឧទ្ធរណ៍នឹងសាលក្រម អាចដាក់បណ្តឹងឧទ្ធរណ៍បាននៅតុលាការដើមដែលចេញសាលក្រម។ ក្រោយពេលដែលបានទទួលបណ្តឹងឧទ្ធរណ៍ តុលាការដើមនឹងធ្វើការបញ្ជូនសំណុំឯកសារទាំងនេះមកតុលាការនៃបណ្តឹងឧទ្ធរណ៍ ហើយសាលាឧទ្ធរណ៍ដែលមានសមត្ថកិច្ចទទួលបន្ទុកជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នោះនឹងពិនិត្យចាត់ការតាមលក្ខខណ្ឌច្បាប់។

នៅពេលដែលតុលាការនៃបណ្តឹងឧទ្ធរណ៍បានទទួលពាក្យបណ្តឹងឧទ្ធរណ៍ និងសំណុំរឿងរដ្ឋប្បវេណីដែលត្រូវបានបញ្ជូនមកនោះ តុលាការនឹងធ្វើការពិនិត្យទៅលើពាក្យបណ្តឹងឧទ្ធរណ៍នូវលក្ខណៈទម្រង់នៃ

បណ្តឹងនោះ[36]។ ទី១ គឺពិនិត្យទៅលើឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានភាគី ព្រមទាំង ឈ្មោះនិងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់, លើអត្តសញ្ញាណនៃសាលក្រមដែលភាគីបានប្តឹងឧទ្ធរណ៍នោះ និងសេចក្តីដែលត្រូវប្តឹងឧទ្ធរណ៍ចំពោះសាលក្រមនោះ។ ទី២ គឺលើការបង់ប្រាក់ប្រដាប់ក្តី។

ក្នុងករណីដែលដើមបណ្តឹងឧទ្ធរណ៍មិនបានបង់ពន្ធដាក់ពាក្យសុំនោះ ឬមានការខ្វះអាសយដ្ឋាន តុលាការអាចបង្គាប់ឱ្យកែតម្រូវ ដោយកំណត់អំឡុងពេលសមរម្យ ហើយប្រសិនបើដើមបណ្តឹងឧទ្ធរណ៍ពុំបានកែតម្រូវតាមការបង្គាប់នោះ តុលាការអាចចេញដីកាសម្រេចលើកចោលបណ្តឹងឧទ្ធរណ៍បាន។

នៅពេលដែលតុលាការបានពិនិត្យពាក្យបណ្តឹងឧទ្ធរណ៍ហើយពាក្យបណ្តឹងឧទ្ធរណ៍នោះ បានបំពេញលក្ខខណ្ឌតាមច្បាប់នោះ តុលាការនឹងបញ្ជូនពាក្យបណ្តឹងឧទ្ធរណ៍នោះទៅចុងបណ្តឹងឧទ្ធរណ៍ ដើម្បីជូនដំណឹងអំពីការប្តឹងឧទ្ធរណ៍ និងដើម្បីឱ្យចុងបណ្តឹងឧទ្ធរណ៍ត្រៀមខ្លួនឆ្លើយតប។

### ៤.១.៣.២ ការទាញហេតុផលដោយផ្ទាល់មាត់

សាលាឧទ្ធរណ៍ ត្រូវធ្វើការវិនិច្ឆ័យលើភាពត្រឹមត្រូវនៃសាលក្រម ដោយការចេញសាលដីកា ហេតុដូច្នេះដើម្បីធានាថា ការវិនិច្ឆ័យនេះមានលក្ខណៈត្រឹមត្រូវនោះ និងស្របតាមគោលការណ៍ចំពោះមុខ សាលាឧទ្ធរណ៍ត្រូវធ្វើការទាញហេតុផលដោយផ្ទាល់មាត់។

ការទាញហេតុផលដោយផ្ទាល់មាត់ ត្រូវធ្វើលើទំហំដែលភាគីប្តឹងឧទ្ធរណ៍ ទាមទារឱ្យផ្លាស់ប្តូរឬកែប្រែសាលក្រមតែប៉ុណ្ណោះ។ ការទាញហេតុផលដោយផ្ទាល់មាត់ តម្រូវឱ្យភាគីធ្វើសេចក្តីថ្លែងការណ៍ អំពីលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់នៅសាលាដំបូង[37]។

នៅក្នុងការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ ភាគីមិនត្រូវបានអនុញ្ញាតឱ្យដាក់មធ្យោបាយតទល់ ឬ ភស្តុតាង បន្ថែមឬថ្មីណាមួយចូលក្នុងសំណុំរឿងឡើយ ស្របតាមមាត្រា ១០៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ជាគោលការណ៍ សាលាឧទ្ធរណ៍ពុំមានសមត្ថកិច្ចធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនោះទេ ក៏ប៉ុន្តែក្នុងករណីដែលសាលាឧទ្ធរណ៍ពិចារណាឃើញថា ការកំណត់ចំណុចវិវាទរបស់សាលាដំបូងមានលក្ខណៈមិនត្រឹមត្រូវនិងមានភាពចាំបាច់ក្នុងការកំណត់ចំណុចវិវាទជាថ្មីនោះ សាលាឧទ្ធរណ៍អាចបង្វិលសំណុំរឿងនេះទៅនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលវិញបាន តាមរយៈការចេញដីកាសម្រេច។

[36] មាត្រា ២៦៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី

[37] មាត្រា ២៧២ នៃក្រមនីតិវិធីរដ្ឋប្បវេណី

### ៤.១.៤ សាលដីការបស់សាលាឧទ្ធរណ៍

ក្នុងករណីដែលសាលាឧទ្ធរណ៍យល់ឃើញថា សាលក្រមនៃសាលាដំបូងបានសម្រេចសេចក្ដីមានភាពពុំត្រឹមត្រូវ ឬ ខុសនីតិវិធីធ្ងន់ធ្ងរ សាលាឧទ្ធរណ៍អាចលុបចោលសាលក្រមនោះ ដោយធ្វើការវិនិច្ឆ័យដោយខ្លួនឯងជំនួសសាលាដំបូង ឬ បញ្ជូនត្រឡប់ ឬ ផ្ទេររឿងក្ដី។ សាលាឧទ្ធរណ៍អាចលុបចោលសាលក្រមនៃសាលាដំបូង ក្នុងករណីដែលយល់ឃើញថា ការសម្រេចសេចក្ដីមានភាពពុំត្រឹមត្រូវ និងធ្វើការវិនិច្ឆ័យសេចក្ដីដោយខ្លួនឯងលើសំណុំរឿងនោះវិញ[38] ឬអាចចេញសាលដីកាសម្រេចលុបចោលសាលក្រមនោះ និងបង្វិលសំណុំរឿងនេះទៅសាលាដំបូងជំនុំជម្រះសាជាថ្មីបាន [39] បើយល់ឃើញថាចាំបាច់មានការទាញហេតុផលបន្ថែមទៀតចំពោះរឿងក្ដីនោះ។

ក៏ប៉ុន្តែ ក្នុងករណីដែលសាលាឧទ្ធរណ៍យល់ឃើញថា ការសម្រេចសេចក្ដីរបស់សាលាដំបូងមានលក្ខណៈត្រឹមត្រូវហើយ សាលាឧទ្ធរណ៍អាចច្រានចោលពាក្យបណ្ដឹងឧទ្ធរណ៍ និងតម្កល់សាលក្រមរបស់សាលាដំបូងទុកជាបានការ[40]។

## ៤.២ បណ្ដឹងសាទុក្ខ

បណ្ដឹងសាទុក្ខ គឺជាប្រភេទមួយនៃបណ្ដឹងឧបាស្រ័យដែលធ្វើទៅតុលាការជាន់ខ្ពស់និងជាបណ្ដឹងដែលធ្វើឡើងប្រឆាំងនឹងសេចក្ដីសម្រេចចុងក្រោយរបស់សាលាឧទ្ធរណ៍ ឬធ្វើឡើងប្រឆាំងនឹង សាលក្រមរបស់សាលាដំបូងរាជធានី/ខេត្តក្នុងករណីដែលគូភាគីបានព្រមព្រៀងគ្នាមិនប្ដឹងឧទ្ធរណ៍។

បណ្ដឹងសាទុក្ខអាចធ្វើបាន ដោយយកមូលហេតុនៃភាពផ្ទុយនឹងរដ្ឋធម្មនុញ្ញច្បាប់ ឬ បទដ្ឋានគតិយុត្តដែលមានឥទ្ធិពលលើសាលដីកា ឬ សាលក្រម ។

តុលាការដែលមានសមត្ថកិច្ចជំនុំជម្រះលើពាក្យបណ្ដឹងសាទុក្ខ គឺតុលាការកំពូល។

### ៤.២.១ របៀបប្ដឹងសាទុក្ខ និងការបញ្ជូន

ដើម្បីធ្វើការប្ដឹងសាទុក្ខ ភាគីត្រូវដាក់ពាក្យបណ្ដឹងទៅតុលាការដើមនៃសាលដីកាឬសាលក្រម ក្នុងករណីនេះពាក្យបណ្ដឹងសាទុក្ខត្រូវដាក់នៅសាលាឧទ្ធរណ៍ ប្រសិនបើធ្វើការប្ដឹងប្រឆាំងនឹងសាលដីកាចុង

[38] មាត្រា ២៧៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី
[39] មាត្រា ២៨០ នៃក្រមនីតិវិធីរដ្ឋប្បវេណី
[40] មាត្រា ២៧៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី

ក្រោយរបស់សាលាឧទ្ធរណ៍ ឬបណ្តឹងសាទុក្ខត្រូវដាក់នៅសាលាដំបូងរាជធានី/ខេត្ត ចំពោះករណីដែលភាគីព្រមព្រៀងជាលាយ លក្ខណ៍អក្សរមិនប្តឹងឧទ្ធរណ៍។

នៅពេលដែលមានបណ្តឹងសាទុក្ខ ច្បាប់តម្រូវឱ្យតុលាការដើម (សាលាឧទ្ធរណ៍ សាលាដំបូងរាជធានី/ខេត្ត) ធ្វើការបញ្ជូនឱ្យឆាប់រហ័សនូវពាក្យបណ្តឹងសាទុក្ខ និងសំណុំរឿងទៅតុលាការនៃបណ្តឹងសាទុក្ខ (តុលាការកំពូល)។ ចំពោះអំឡុងពេលនៃការប្តឹងសាទុក្ខ ភាគីមានរយៈពេល ០១ (មួយ) ខែ ដែលត្រូវគិតចាប់ពីថ្ងៃដែលទទួលការបញ្ជូនលិខិតសាលក្រម ឬសាលដីកា[41]។

## ៤.២.២ ពន្ធដាក់ពាក្យសុំ

ពន្ធដាក់ពាក្យបណ្តឹងសាទុក្ខ ត្រូវគណនាទៅតាមតម្លៃនៃកម្មវត្ថុនៃបណ្តឹង និងមានតម្លៃ ២ ដង នៃពន្ធដាក់ពាក្យបណ្តឹងនៅតុលាការជាន់ទាប ហើយកាតព្វកិច្ចក្នុងការបង់ពន្ធដាក់ពាក្យបណ្តឹងសាទុក្ខគឺជាកាតព្វកិច្ចដាច់ខាតដែលភាគីអ្នកដាក់បណ្តឹងត្រូវបំពេញ បើមិនដូច្នោះតុលាការនឹងលើកចោលពាក្យបណ្តឹងសាទុក្ខនោះ។

រីឯ ចំពោះករណីដែលភាគីដកពាក្យបណ្តឹងសាទុក្ខមុនពេលកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់លើកដំបូងនោះ ដើមបណ្តឹងសាទុក្ខអាចដាក់ពាក្យសុំបង្វិលពាក់កណ្តាលនៃពន្ធដាក់ពាក្យសុំបាន។

## ៤.២.៣ ការដាក់លិខិតបញ្ជាក់មូលហេតុនៃបណ្តឹងសាទុក្ខ

ការសរសេរមូលហេតុនៃបណ្តឹងសាទុក្ខ បន្ទាប់ពីទទួលពាក្យបណ្តឹងសាទុក្ខរបស់ដើមបណ្តឹងសាទុក្ខ តុលាការកំពូលត្រូវបញ្ជូនលិខិតទទួលពាក្យបណ្តឹងសាទុក្ខទៅភាគី ហើយចំពោះភាគីជាចុងបណ្តឹងសាទុក្ខត្រូវភ្ជាប់មកជាមួយនូវពាក្យបណ្តឹងសាទុក្ខផងដែរ។ បន្ទាប់ពីទទួលបានលិខិតទទួលពាក្យបណ្តឹង ដើមបណ្តឹងសាទុក្ខ ត្រូវដាក់មូលហេតុនៃបណ្តឹងសាទុក្ខ ក្នុងអំឡុងពេល ៣០ (សាមសិប)ថ្ងៃ[42]។

ក្នុងករណីបណ្តឹងសាទុក្ខធ្វើឡើងដោយយោងតាមមូលហេតុទូទៅនៃបណ្តឹងសាទុក្ខ ស្របតាមមាត្រា ២៨៥ មូលហេតុដាច់ខាតនៃបណ្តឹងសាទុក្ខ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដូចខាងក្រោម៖

- តុលាការដែលចេញសាលដីកា ឬ សាលក្រម មិនត្រូវបានចាត់តាំងដោយស្របទៅតាមច្បាប់ ។
- ចៅក្រមដែលច្បាប់មិនអនុញ្ញាតឱ្យ ចូលរួមក្នុងការចេញសាលដីកា ឬ សាលក្រម តែបានចូលរួម ។
- ភាពផ្ទុយនឹងបញ្ញត្តិស្តីពីសមត្ថកិច្ចផ្តាច់មុខរបស់តុលាការ ។

[41] មាត្រា ២៨៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី

[42] មាត្រា ២៨៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី

- ការខ្វះសិទ្ធិតំណាងដែលកំណត់ដោយច្បាប់ សិទ្ធិតំណាងដោយអាណត្តិ ឬ ការប្រគល់សិទ្ធិចាំបាច់សម្រាប់អ្នកតំណាងដើម្បីធ្វើសកម្មភាពបណ្តឹង ។
- ភាពផ្ទុយនឹងបញ្ញត្តិស្តីពីការបើកការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ ។
- សាលដីកា ឬ សាលក្រម គ្មានសំអាងហេតុ ឬ មានសំអាងហេតុ តែផ្ទុយនឹងគ្នា ។

បណ្តឹងសាទុក្ខ នឹងត្រូវបានលើកចោលដោយដីកាសម្រេចក្នុងករណីដូចជា បណ្តឹងសាទុក្ខនោះជាបណ្តឹងខុសច្បាប់ ហើយមិនអាចកែតម្រូវចំណុចខ្វះខាតបាន ឬបើមិនដាក់លិខិតបញ្ជាក់ពីមូលហេតុនៃ បណ្តឹងសាទុក្ខ ឬមិនបានបង់ប្រាក់ប្រដាប់ក្តី។

### ៤.២.៤ នីតិវិធីក្នុងការជំនុំជម្រះ

នៅពេលដែលដើមបណ្តឹងសាទុក្ខបានដាក់លិខិតបញ្ជាក់មូលហេតុនៃបណ្តឹងសាទុក្ខ និងបង់ពន្ធតាមច្បាប់កំណត់នោះ តុលាការកំពូលនឹងចេញដីកាបង្គាប់ឱ្យដាក់ឯកសារត្រៀម ទៅចុងបណ្តឹងសាទុក្ខ ដោយភ្ជាប់ជាមួយនឹងសេចក្តីចម្លងនៃលិខិតបញ្ជាក់មូលហេតុនៃបណ្តឹងសាទុក្ខរបស់ដើមបណ្តឹងសាទុក្ខ។

ក្រោយពេលដែលភាគីបានដាក់លិខិតបញ្ជាក់មូលហេតុនៃបណ្តឹងសាទុក្ខ និងឯកសារត្រៀមរួចតុលាការកំពូលនឹងកំណត់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ និងចេញដីកាកោះទៅដើមបណ្តឹងសាទុក្ខ និងចុងបណ្តឹងសាទុក្ខ និងលិខិតអញ្ជើញទៅអ្នកតំណាងដោយអាណត្តិរបស់គូភាគី។ តុលាការកំពូលក៏អាចច្រានចោលបណ្តឹងសាទុក្ខដោយសាលដីកាបាន ដោយមិនចាំបាច់ឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់ ក្នុងករណីដែលយល់ឃើញថាបណ្តឹងសាទុក្ខនោះគ្មានមូលហេតុ ក្រោយពីបានពិនិត្យពាក្យបណ្តឹងសាទុក្ខ លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខ ឯកសារត្រៀមដែលចុង បណ្តឹងសាទុក្ខបានដាក់ជូន ។

សាលដីកាដែលវិនិច្ឆ័យលើបណ្តឹងសាទុក្ខនោះ ត្រូវប្រកាសក្នុងរយៈពេល ១ ខែ គិតចាប់ពីកាលបរិច្ឆេទបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់។

តុលាការកំពូលមានសិទ្ធិក្នុងវិនិច្ឆ័យសេចក្តី និងចេញសាលដីកាលុបចោលសាលដីការបស់សាលាឧទ្ធរណ៍ និងវិនិច្ឆ័យដោយខ្លួនឯងវិញ តាមមាត្រា ៣០០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឬ បដិសេធសាលដីការបស់សាលាឧទ្ធរណ៍ និងបញ្ជូនត្រឡប់នូវសំណុំរឿងនោះទៅតុលាការដើមវិញ ហើយសេចក្តីវិនិច្ឆ័យលើអង្គហេតុ និងអង្គច្បាប់ ដែលតុលាការនៃបណ្តឹងសាទុក្ខយកជាមូលហេតុនៃការបដិសេធចោល មានចំណងទៅលើតុលាការដែលបានទទួលការបញ្ជូន ។

## ៤.៣ បណ្តឹងជំទាស់

បណ្តឹងជំទាស់ជាប្រភេទនៃបណ្តឹងឧបាស្រ័យដែលធ្វើឡើងចំពោះដីកាសម្រេច ហើយភាគីដែលមានបំណងប្តឹងជំទាស់ត្រូវដាក់ពាក្យបណ្តឹងជំទាស់ទៅតុលាការដើមដែលចេញដីកាសម្រេចនោះ[43] ក្នុងរយៈពេល ១ សប្តាហ៍ តាមមាត្រា ៣០៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។ នៅក្នុងករណីនេះ តុលាការដើមត្រូវធ្វើឱ្យបានឆាប់រហ័សនូវពាក្យបណ្តឹងជំទាស់និងសំណុំរឿង ទៅតុលាការនៃបណ្តឹងជំទាស់ ។

នៅពេលដែលភាគីប្តឹងជំទាស់ ដើមបណ្តឹងជំទាស់មានកាតព្វកិច្ចជាដាច់ខាតក្នុងការដាក់លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខមកតុលាការនៃបណ្តឹងជំទាស់។ ដោយបញ្ញត្តិស្តីពីបណ្តឹងឧទ្ធរណ៍ និងនីតិវិធីនៃការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នឹងត្រូវបានយកមកអនុវត្តដូចគ្នាចំពោះករណីនេះ។

ចំពោះការជំនុំជម្រះលើពាក្យបណ្តឹងជំទាស់នោះ តុលាការនៃបណ្តឹងជំទាស់អាចវិនិច្ឆ័យសេចក្តីលើបណ្តឹងនេះ ដោយការទាញហេតុផលដោយផ្ទាល់មាត់ក៏បាន និងពុំចាំបាច់ឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ក៏បាន[44]។

សេចក្តីសម្រេចលើបណ្តឹងជំទាស់ ពុំអាចប្តឹងជំទាស់ទៀតបានឡើយ។

## ៤.៤ ការប្តឹងទាស់

បណ្តឹងទាស់ ត្រូវបានធ្វើឡើងក្នុងករណីដែលភាគីមិនបានបង្ហាញខ្លួនតាមកាលបរិច្ឆេទទាន់ពេលវេលាដោយសារមានហេតុដែលមិនអាចព្យាករបាន ឬ ហេតុដែលមិនអាចជៀសវាងបានតាមមាត្រា ២០៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ហើយបានទទួលសាលក្រមកំបាំងមុខ ។ បានន័យថា បណ្តឹងទាស់ធ្វើឡើងចំពោះសាលក្រមកំបាំងមុខ។

បណ្តឹងទាស់ចំពោះសាលក្រមកំបាំងមុខ ត្រូវធ្វើឡើងក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ ដោយគិតចាប់ពីថ្ងៃដែលបានទទួលការបញ្ជូនសាលក្រមកំបាំងមុខនោះ ។

[43] មាត្រា ៣០១ នៃក្រមនីតិវិធីរដ្ឋប្បវេណី

[44] មាត្រា ៣០៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី

### ៤.៤.១ របៀបប្តឹងទាស់ចេញសាលក្រមកំបាំងមុខ

ការប្តឹងទាស់ ត្រូវធ្វើឡើងដោយដាក់ពាក្យបណ្តឹងទាស់ទៅតុលាការដែលចេញសាលក្រមកំបាំងមុខនោះ ហើយនៅក្នុងពាក្យបណ្តឹងទាស់ ត្រូវសរសេរចំណុចដូចខាងក្រោម[45]៖

-ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់គូភាគី ហើយនិង ឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ។

-សញ្ញាណសាលក្រមកំបាំងមុខដែលជាកម្មវត្ថុនៃការប្តឹងទាស់ ។

-បំណងនៃការប្តឹងទាស់ចំពោះសាលក្រមដែលជាកម្មវត្ថុនៃការប្តឹងទាស់

-មូលហេតុដែលមិនអាចមកបង្ហាញខ្លួនតាមកាលបរិច្ឆេទទាន់ពេលវេលា

### ៤.៤.២ ការពិនិត្យ ការបញ្ជូន និងការជំនុំជម្រះលើពាក្យបណ្តឹងទាស់

ក្នុងករណីដែលពាក្យបណ្តឹងទាស់មិនស្របតាមកំណត់ច្បាប់ ដូចដែលបានកំណត់ក្នុងមាត្រា ២០៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី តុលាការត្រូវកំណត់អំឡុងពេលសមរម្យ និង បង្គាប់ឱ្យកែតម្រូវចំណុចខ្វះខាតនៃពាក្យបណ្តឹងនោះ ក្នុងអំឡុងពេលនោះ ។ ប្រសិនបើភាគីដែលប្តឹងទាស់នោះមិនបានកែតម្រូវចំណុចខ្វះខាតទេតាមការបង្គាប់ នោះតុលាការត្រូវលើកពាក្យបណ្តឹងទាស់នោះចោលដោយដីកាសម្រេច ។

តុលាការត្រូវធ្វើការស្រាវជ្រាវ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន អំពីភាពត្រឹមត្រូវនៃពាក្យបណ្តឹងទាស់តាមទម្រង់ និង អំឡុងពេលដែលកំណត់ដោយច្បាប់ និង អំពីភាពត្រឹមត្រូវនៃមូលហេតុបណ្តឹងទាស់ ។

ក្នុងករណីដែលតុលាការយល់ឃើញថា ពាក្យបណ្តឹងទាស់នោះមិនត្រឹមត្រូវតាមច្បាប់ នោះតុលាការអាចលើកចោលបណ្តឹងទាស់នេះ ដោយដីកាសម្រេច ក៏ប៉ុន្តែបើបណ្តឹងទាស់នោះគ្មានមូលហេតុត្រឹមត្រូវទេ តុលាការត្រូវច្រានចោលបណ្តឹងនោះដោយដីកាសម្រេច ។[46]

នៅពេលដែលតុលាការពិនិត្យឃើញថា ពាក្យបណ្តឹងទាស់មានភាពត្រឹមត្រូវនោះ តុលាការនឹងទទួលស្គាល់បណ្តឹងទាស់នេះ ហើយនីតិវិធីនៃបណ្តឹងនោះត្រូវត្រឡប់ទៅសភាពដើមវិញ ពីត្រឹមពេលអវត្តមាននោះកើតឡើង ។ តុលាការត្រូវកំណត់កាលបរិច្ឆេទថ្មីដើម្បីចាប់ផ្តើមអនុវត្តនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ ដើម្បីចាប់ផ្តើមធ្វើការទាញហេតុផលដោយផ្ទាល់មាត់ឡើងវិញ ហើយត្រូវជូនដំណឹងនេះទៅឱ្យគូភាគី ។

[45] មាត្រា ២០៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី

[46] មាត្រា ២០៧ ចំណុចទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី

ក៏ប៉ុន្តែ បើដើមបណ្តឹងទាស់ មិនបានបង្ហាញខ្លួននៅកាលបរិច្ឆេទដំបូងក្រោយពេលចាប់ផ្តើមអនុវត្តនីតិវិធីឡើងវិញទេ តុលាការត្រូវច្រានចោលបណ្តឹងទាស់ ដោយសាលក្រមកំបាំងមុខម្តងទៀត លើកលែងតែក្នុងករណីដែលបានកំណត់ក្នុងមាត្រា ២០២ និង មាត្រា ២០៣ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។ ហើយសាលក្រមកំបាំងមុខនេះ ពុំអាចប្តឹងទាស់ទៀតបានឡើយ។

### ៤.៤.៣ សាលក្រមលើបណ្តឹងទាស់

ក្នុងករណីដែលតុលាការសម្រេចចេញសាលក្រមផ្អែកលើការជំនុំជម្រះជាថ្មី បន្ទាប់ពីចាប់ផ្តើមអនុវត្តនីតិវិធីឡើងវិញ ដែលមានលទ្ធផលដូចសាលក្រមកំបាំងមុខ នោះតុលាការត្រូវចេញសាលក្រមថ្មីដែលប្រកាសថា តម្កល់សាលក្រមកំបាំងមុខនោះទុកជាបានការ ។

ក៏ប៉ុន្តែបើសាលក្រមដែលត្រូវចេញដោយផ្អែកលើការជំនុំជម្រះជាថ្មី បន្ទាប់ពីចាប់ផ្តើមអនុវត្តនីតិវិធីឡើងវិញ គ្មានលទ្ធផលដូចសាលក្រមកំបាំងមុខទេ នោះតុលាការត្រូវលុបចោលសាលក្រមកំបាំងមុខនោះនៅក្នុងសាលក្រមថ្មី[47] ។

[47] មាត្រា ២០៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានសិក្សាលើប្រធានបទនេះ និងបានរៀបចំចងក្រងនូវសារណាបញ្ចប់ការសិក្សានេះរួចយើងខ្ញុំទាំងពីរនាក់ បានធ្វើសេចក្តីសន្និដ្ឋានថា ប្រជាជនមួយចំនួនធំ ពុំទាន់មានការយល់ដឹងអំពីសារៈសំខាន់នៃការចុះសំបុត្រអាពាហ៍ពិពាហ៍ ការចុះបញ្ជីទ្រព្យដោយឡែក ដែលមានមុនចំណងអាពាហ៍ពិពាហ៍បានបង្កើតឡើង នីតិវិធីបណ្តឹងលែងលះ ជាអាទិ៍អោយបានស្របតាមច្បាប់កំណត់នៅឡើយទេបើទោះជាមានក្រមរដ្ឋប្បវេណីដែលបានចែងលើជំពូកនេះសព្វគ្រប់ហើយក៍ដោយ។ ចំណុចខ្វះខាតទាំងអស់នេះធ្វើឱ្យមានផលប៉ះពាល់យ៉ាងខ្លាំងដល់ស្មារតីរបស់សហព័ទ្ធ ភាពស្មុគស្មាញលើការបែងចែកទ្រព្យសម្បត្តិ សិទ្ធអំណាចមេបាលើកូន និងបុគ្គលមួយចំនួនដែលមានផលប្រយោជន៍ តួយ៉ាងដូចជាឳពុកម្តាយទាំងសងខាងម្ចាស់បំណុលជាដើម។

នីតិវិធីបណ្តឹងលែងលះ ជានីតិវិធីតុលាការជំនុំជម្រះទៅលើរឿងក្តីរដ្ឋប្បវេណីដែលមានលក្ខណៈស្មុគស្មាញទាក់ទងនឹងឋានៈបុគ្គល ក្រមរដ្ឋប្បវេណី សិទ្ធិនិងកាតព្វកិច្ចរបស់គូភាគី ការបែងចែកទ្រព្យសម្បត្តិ ការកំណត់អំណាចមេបានៃកូន សិទ្ធិចូលជួបប្រាស្រ័យទាក់ទងនឹងកូន អាហារកាតព្វកិច្ច សោហ៊ុយចិញ្ចឹមបីបាច់កូន ការសម្រេចលើបំណុលរួមជាមួយនឹងម្ចាស់បំណុលដែលអាចជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុធនាគារ ឬជារូបវន្តបុគ្គល និងមានផលប៉ះពាល់ទៅដល់ភាគីពាក់ព័ន្ធជាច្រើនទៀតផង ។ នីតិវិធីនៃបណ្តឹងនេះ ក៏មានសារៈសំខាន់ក្នុងការដើរតួនាទីក្នុងការផ្សះផ្សានូវសហព័ទ្ធទាំងសងខាងដើម្បីពន្លត់នូវវិវាទរបស់អ្នកទាំងពីរ និងជួយឱ្យសហព័ទ្ធទាំងសងខាងបន្តនូវចំណងអាពាហ៍ពិពាហ៍នេះទៅពេលអនាគតផងដែរ។

មានភាពចាំបាច់ណាស់ ដែលរាជរដ្ឋាភិបាល អ្នកច្បាប់ អង្គការសង្គមស៊ីវិល មានតួនាទីពន្យល់អប់រំ អំពីផលពិបាក និងសារៈប្រយោជន៍ដ៏សំខាន់ចំពោះបញ្ហាដែលបានលើកឡើងខាងលើ។ ដោយការចុះសំបុត្រអាពាហ៍ពិពាហ៍មានសារៈសំខាន់ណាស់ចំពោះប្តីប្រពន្ធមួយគូ ដើម្បីធានានូវការការពារលើសិទ្ធិនិងកាតព្វកិច្ចរបស់គូភាគីនាពេលអនាគត ជាហេតុដែលប្រជាជនទាំងអស់គ្នាគប្បីទៅចុះសំបុត្រអាពាហ៍ពិពាហ៍នៅអគ្រានុកូលដ្ឋានឃុំស្រុកខណ្ឌ ហើយគប្បីមានអាជ្ញាធរចុះផ្សព្វផ្សាយទៅតំបន់ដាច់ស្រយាលផងដែរ ដោយប្រជាជននៅតំបន់ដាច់ស្រយាលពុំសូវបានដឹងអំពីអានុភាពនៃការចុះសំបុត្រអាពាហ៍ពិពាហ៍នោះទេ ដោយបានត្រឹមតែគិតថាការរៀបអាពាហ៍ពិពាហ៍តាមបែបទំនៀមទម្លាប់ប្រពៃណីមានអានុភាពដូចនឹងការចុះសំបុត្រអាពាហ៍ពិពាហ៍។

# ឯកសារយោង

# ឯកសារយោង


## ១. ច្បាប់និងបទដ្ឋានគតិយុត្តផ្សេងៗ

- រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧
- ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
- ច្បាប់ស្តីពីឯកពន្ធភាព ឆ្នាំ ២០០៦
- ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល
- ច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីមិនមែនបណ្តឹង
- អនុក្រឹត្យស្តីពីអគ្រានុកូលដ្ឋាន

## ២. ឯកសារផ្សេងៗ

- សេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណី ភាគ ៥៖ គន្ថីទី៧ ដែលរៀបចំដោយគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី
- សេចក្តីពន្យល់ អំពី ចំណុចសំខាន់ៗ នៃក្រមនីតិវិធីរដ្ឋប្បវេណី របស់អង្គការ JICA
- សៀវភៅស្តីពីនីតិគ្រួសារ ដោយលោកជំទាវ ចាំង ស៊ីណាត
- អត្ថបទ៖ លក្ខខណ្ឌនៃការលែងលះដោយព្រមព្រៀង ដោយលោក ផុន វណ្ណា ចៅក្រមនៃសាលាដំបូងខេត្តត្បូងឃ្មុំ

## ៣. Websites

- https://www.jica.go.jp/Resource/project/english/cambodia/025/materials/c8h0vm0000c54sbn-att/code_06_03.pdf
- https://www.jica.go.jp/Resource/project/english/cambodia/025/materials/c8h0vm0000c54sbn-att/form_case0405_02.pdf

# មាតិកា

**សេចក្តីផ្តើម** ........................................................................ ១

## ជំពូកទី ១ អាពាហ៍ពិពាហ៍

**១. អាពាហ៍ពិពាហ៍** ........................................................................ ៣

១.១ លក្ខខណ្ឌនៃអាពាហ៍ពិពាហ៍ ........................................................ ៣

១.២ ករណីដែលច្បាប់បានហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ .......................... ៨

១.៣ អានុភាពនៃអាពាហ៍ពិពាហ៍................................................... ១០

**២. ការលែងលះ**........................................................................ ១៦

២.១ មូលហេតុនៃការលែងលះ.................................................... ១៦

២.២ ប្រភេទនៃបណ្តឹងលែងលះ ..................................................១៧

## ជំពូកទី២ នីតិវិធីនៃការលែងលះដោយការព្រមព្រៀង

**១. ការដាក់ពាក្យសុំ** ........................................................................ ២០

**២ ការជំនុំជម្រះ** ........................................................................ ២១

**៣. ការសម្រេចសេចក្តី** ........................................................................ ២២

៣.១ អំពីដីកាសម្រេច ........................................................ ២២

៣.២ ការចូលជាស្ថាពរ និងអានុភាពនៃដីកាសម្រេច ................................... ២៤

**៤. បណ្តឹងឧបាស្រ័យ ឬបណ្តឹងជំទាស់** ................................................... ២៤

៤.១ រយៈពេលនៃការប្តឹងជំទាស់ ................................................ ២៥

៤.២ នីតិវិធីនៃការប្តឹងជំទាស់.................................................... ២៥

## ជំពូកទី៣ នីតិវិធីនៃការលែងលះដោយការដាក់ពាក្យបណ្តឹង

**១. ការដាក់ពាក្យសុំទៅឃុំសង្កាត់** ................................................... ២៦

**២. ការដាក់ពាក្យបណ្តឹងទៅតុលាការមានសមត្ថកិច្ច** ...................................... ២៦

**៣. ការជំនុំជម្រះនៅជាន់សាលាដំបូង**................................................... ២៧

៣.១ ការពិនិត្យពាក្យបណ្តឹង ................................................... ២៧

៣.២ ការកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល .................. ២៨

៣.៣ ការទាញហេតុផលដោយផ្ទាល់មាត់ ………………………………………………………….. ២៨
៣.៤ ការចេញសាលក្រម ………………………………………………………………………. ២៩
**៤. បណ្តឹងឧបាស្រ័យ** ………………………………………………………………………… ៣០
៤.១ បណ្តឹងឧទ្ធរណ៍ ……………………………………………………………………………. ៣២
៤.២ បណ្តឹងសាទុក្ខ ……………………………………………………………………………... ៣៦
៤.៣ បណ្តឹងជំទាស់ ……………………………………………………………………………...៣៩
៤.៤ ការប្តឹងទាស់ ……………………………………………………………………............ ៣៩
**សេចក្តីសន្និដ្ឋាន** ………………………………………………………………………………… ៤២
**ឯកសារយោង**……………………………………………………………………………………….៤៣

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ១៖
# នីតិវិធីនៃការដាក់ពាក្យអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍

- គំរូពាក្យសុំបញ្ជាក់ភាពនៅលីវ ភាពពោះម៉ាយ ភាពមេម៉ាយ
- គំរូលិខិតបញ្ជាក់ភាពនៅលីវ ភាពពោះម៉ាយ ភាពមេម៉ាយ
- គំរូពាក្យសុំរៀបអាពាហ៍ពិពាហ៍
- គំរូប័ណ្ណប្រកាសអាពាហ៍ពិពាហ៍
- គំរូបញ្ជីអាពាហ៍ពិពាហ៍
- គំរូសំបុត្រអាពាហ៍ពិពាហ៍
- គំរូសេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យសុំបញ្ជាក់

### ភាពនៅលីវ ភាពពោះម៉ាយ ភាពមេម៉ាយ

ខ្ញុំបាទ នាងខ្ញុំឈ្មោះ------------------- ភេទ------- សញ្ជាតិ------- កើតនៅថ្ងៃ------- ទី------ ខែ---------- ឆ្នាំ------- នៅភូមិ------------------ ឃុំ សង្កាត់------------------- ក្រុង ស្រុក ខណ្ឌ--------------- រាជធានី ខេត្ត --------------- មុខរបរបច្ចុប្បន្ន------------------- ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ------- ផ្លូវលេខ-------- ក្រុម------ ភូមិ----------- ឃុំ សង្កាត់---------- ក្រុង ស្រុក ខណ្ឌ-------------- រាជធានី ខេត្ត -------------- ។

**គោរពជូន**

**មេឃុំ ចៅសង្កាត់**------------------------

**<u>កម្មវត្ថុ</u>** ៖ សំណើសុំលិខិតបញ្ជាក់ភាព------------------------------ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ សូមជម្រាបលោក លោកស្រីមេឃុំ ចៅសង្កាត់ មេត្តាជ្រាបថា បច្ចុប្បន្ន ខ្ញុំបាទ នាងខ្ញុំ មានស្ថានភាពផ្ទាល់ខ្លួន----------------------- ហើយមានបំណងរៀបអាពាហ៍ពិពាហ៍ ជាមួយឈ្មោះ-------------- ភេទ---------- ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ------ ផ្លូវលេខ---------ក្រុម---------- ភូមិ----------------------- ឃុំ សង្កាត់--------------------- ក្រុង ស្រុក ខណ្ឌ------------------------ រាជធានី ខេត្ត --------------------- ។

អាស្រ័យហេតុនេះ សូមលោក លោកស្រីមេឃុំ ចៅសង្កាត់ មេត្តាចេញលិខិតបញ្ជាក់ឱ្យខ្ញុំបាទ នាងខ្ញុំ ដើម្បីអាចរៀបអាពាហ៍ពិពាហ៍បាន ដោយអនុគ្រោះ។

ដើម្បីជាសក្ខីភាពនៃការអះអាងខាងលើ ខ្ញុំបាទ នាងខ្ញុំ សូមផ្តិតស្នាមមេដៃស្តាំ ទុកជា ភស្តុតាង។

ធ្វើនៅថ្ងៃទី------ ខែ----------- ឆ្នាំ-------

<u>សូមជូនភ្ជាប់ជាមួយនូវ</u> ៖

**ស្នាមមេដៃសាមីខ្លួន**

– -----------------------------

– --------------------------

ឈ្មោះ ------------

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

4x6

រាជធានី ខេត្ត ៖---------------

ក្រុង ស្រុក ខណ្ឌ ៖---------------

ឃុំ សង្កាត់ ៖---------------

លេខ ៖---------------

ថ្ងៃទី----- ខែ--------- ឆ្នាំ------

## លិខិតបញ្ជាក់

## ភាពនៅលីវ ភាពពោះម៉ាយ ភាពមេម៉ាយ

យោងពាក្យសុំបញ្ជាក់ភាព----- ចុះថ្ងៃទី----- ខែ--------- ឆ្នាំ------- របស់---------------------។

**យើងមេឃុំ ចៅសង្កាត់**---------------------

សូមបញ្ជាក់ថា ឈ្មោះ--------------------- ភេទ------ កើតនៅថ្ងៃ------ ទី------ ខែ---------ឆ្នាំ--------
នៅភូមិ----------- ឃុំ សង្កាត់-------------- ក្រុង ស្រុក ខណ្ឌ---------------រាជធានី ខេត្ត-----------------
មុខរបរបច្ចុប្បន្ន------------------------------ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ------- ផ្លូវលេខ------- ក្រុម------
ភូមិ-------------ឃុំ សង្កាត់---------------ក្រុង ស្រុក ខណ្ឌ------------------រាជធានី ខេត្ត---------------
មានស្ថានភាពផ្ទាល់ខ្លួនបច្ចុប្បន្ន ពិតជា-----------------ប្រាកដមែន។

លិខិតបញ្ជាក់នេះ ចេញឱ្យសាមីខ្លួន ដើម្បីយកទៅប្រើប្រាស់ក្នុងការសុំរៀបអាពាហ៍ពិពាហ៍។

(លិខិតបញ្ជាក់នេះ មានសុពលភាពរយៈពេល៣ខែ ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ)

**មេឃុំ ចៅសង្កាត់**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ខ្ញុំបាទ នាងខ្ញុំឈ្មោះ--------------------- ភេទ--------- សញ្ជាតិ--------- ឆ្នាំកំណើត----------- មុខរបរបច្ចុប្បន្ន--------------------------------------------------- ស្ថានភាពផ្ទាល់ខ្លួន------------------ ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ-------- ផ្លូវលេខ--------- ក្រុម--------- ភូមិ----------- ឃុំ សង្កាត់ -------------- ក្រុង ស្រុក ខណ្ឌ---------------- រាជធានី ខេត្ត ---------------- ។ ឪពុកឈ្មោះ------------------ អាយុ------ ឆ្នាំ (រស់ ស្លាប់) ម្តាយឈ្មោះ---------------------អាយុ-------ឆ្នាំ (រស់ ស្លាប់) ។

**គោរពជូន**

**មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់.......................................**

**<u>កម្មវត្ថុ</u>** ៖ សំណើសុំរៀបអាពាហ៍ពិពាហ៍ ។

ដោយខ្ញុំបាទ នាងខ្ញុំ បានស្ម័គ្រចិត្តរៀបអាពាហ៍ពិពាហ៍ជាមួយឈ្មោះ--------------------ភេទ------ សញ្ជាតិ----------ឆ្នាំកំណើត-----------មុខរបរ------------------------------------------------------------ ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ------- ផ្លូវលេខ-------- ក្រុម-------- ភូមិ------------ឃុំ សង្កាត់---------------- ក្រុង ស្រុក ខណ្ឌ------------------ រាជធានី ខេត្ត ----------------- ។

ខ្ញុំសូមអះអាងថា ខ្ញុំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមក្រមរដ្ឋប្បវេណី និងបទប្បញ្ញត្តិនៃអត្រានុកូលដ្ឋាន ។

អាស្រ័យហេតុនេះ សូមមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់------------------------------ មេត្តាអនុញ្ញាត ឱ្យយើងខ្ញុំទាំងពីរបានរៀបអាពាហ៍ពិពាហ៍តាមសំណូមពរដោយអនុគ្រោះ ។

ធ្វើនៅថ្ងៃទី------- ខែ---------- ឆ្នាំ-------

**ស្នាមមេដៃស្តាំសាមីខ្លួន**

<u>សូមជូនភ្ជាប់ជាមួយនូវ</u> ៖

- -----------------------------
- -----------------------------
- -----------------------------

ឈ្មោះ-----------

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
៚៚៛៙៙

ខេត្ត ក្រុង --------------------
ស្រុក ខណ្ឌ --------------------
ឃុំ សង្កាត់ --------------------
លេខ --------------------

# បំណ្ណប្រកាសអាពាហ៍ពិពាហ៍

| អំពីសាមីខ្លួន | ខាងប្រុស | ខាងស្រី |
|---|---|---|
| នាមត្រកូល និង នាមខ្លួន | | |
| ជាអក្សរឡាតាំង | | |
| សញ្ជាតិ | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | |
| ទីកន្លែងកំណើត | | |
| មុខរបរបច្ចុប្បន្ន | | |
| ទីលំនៅបច្ចុប្បន្ន | | |
| រយៈពេលប្តឹងជំទាស់ | | |
| នាមត្រកូល និងនាមខ្លួនឪពុក | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | |
| មុខរបរបច្ចុប្បន្ន | | |
| ទីលំនៅបច្ចុប្បន្ន | | |
| នាមត្រកូល និងនាមខ្លួនម្ដាយ | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | |
| មុខរបរបច្ចុប្បន្ន | | |
| ទីលំនៅបច្ចុប្បន្ន | | |

បណ្ណប្រកាសអាពាហ៍ពិពាហ៍នេះ ត្រូវបិទផ្សាយជាសាធារណៈ នៅថ្ងៃទី............. ខែ........................ ឆ្នាំ................ ។

ធ្វើនៅ....................... ថ្ងៃទី.......... ខែ................ ឆ្នាំ...........

**មន្ត្រីអត្រានុកូលដ្ឋាន**

| | |
|---|---|
| ~~ខេត្ត~~ រាជធានី (១)..... *ភ្នំពេញ* .......... | លេខ (៤)................. *០៩* ............................ |
| ~~ស្រុក~~ ខណ្ឌ (២).... *ឫស្សីកែវ* ........ | សៀវភៅសំបុត្រអាពាហ៍ពិពាហ៍លេខ (៥)...០១/២០១២... |
| ~~ឃុំ~~ សង្កាត់ (៣)...... *បាក់ខែង* ........ | ឆ្នាំ (៦).......... *២០១២* .................................. |

# សំបុត្រអាពាហ៍ពិពាហ៍

| ព័ត៌មានប្ដី ប្រពន្ធ | | ប្ដី | | ប្រពន្ធ | |
|---|---|---|---|---|---|
| នាមត្រកូល (៧) | | *សាយ* | | *អ៊ូ* | |
| នាមខ្លួន (៨) | | *សំអាន* | | *នួនស្រី* | |
| ជាអក្សរឡាតាំង (៩) | នាមត្រកូល | SAY | | OU | |
| | នាមខ្លួន | SAM ANN | | NUON SREY | |
| សញ្ជាតិ (១០) | | *ខ្មែរ* | | *ខ្មែរ* | |
| ថ្ងៃ ខែ ឆ្នាំកំណើត (១១) | | *ថ្ងៃពុធ ទី២៥ ខែសីហា ឆ្នាំ១៩៨៣* | | *ថ្ងៃច័ន្ទ ទី១៧ ខែមករា ឆ្នាំ១៩៨៩* | |
| ទីកន្លែងកំណើត (១២) ភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ខេត្ត ក្រុង ប្រទេស | | *ភូមិពញាព្ញ ឃុំពញាព្ញ ស្រុកពញាព្ញ ខេត្តកណ្ដាល ប្រទេសកម្ពុជា* | | *ភូមិក្ដីចាស់ ឃុំបាក់ខែង ស្រុកមុខកំពូល ខេត្តកណ្ដាល ប្រទេសកម្ពុជា* | |
| មុខរបរពេលចុះបញ្ជីអាពាហ៍ពិពាហ៍ (១៣) | | *សាស្ត្រាចារ្យ* | | *គ្រូពេទ្យ* | |
| ទីលំនៅពេលចុះបញ្ជីអាពាហ៍ពិពាហ៍ (១៤) | | *ភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា* | | *ភូមិក្ដីចាស់ សង្កាត់បាក់ខែង ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា* | |
| លេខអត្តសញ្ញាណប័ណ្ណ (១៥) | | | | | |
| ចុះបញ្ជីអាពាហ៍ពិពាហ៍លើកទី (១៦) | | *មួយ* | | *មួយ* | |
| ថ្ងៃ ខែ ឆ្នាំចុះបញ្ជីអាពាហ៍ពិពាហ៍ (១៧) | | *ថ្ងៃ សុក្រ ទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១២* | | | |
| ទីកន្លែងចុះបញ្ជីអាពាហ៍ពិពាហ៍ (១៨) | | *សង្កាត់បាក់ខែង ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ* | | | |
| លេខ និងថ្ងៃ ខែឆ្នាំប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ (១៩) | | *០៩ ប.ខ ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១២* | | | |
| ព័ត៌មានឪពុក ម្ដាយ | | ខាងប្ដី | | ខាងប្រពន្ធ | |
| នាមត្រកូល និង នាមខ្លួនឪពុក (២០) | | *សាយ សំអឿន* (២១) | សញ្ជាតិ *ខ្មែរ* | *អ៊ូ សែម* | សញ្ជាតិ *ខ្មែរ* |
| ជាអក្សរឡាតាំង (២២) | | SAY SAM OEUN (២៣) | រស់ ឬ ស្លាប់ | OU SEM | រស់ ឬ ស្លាប់ |
| ថ្ងៃ ខែ ឆ្នាំកំណើត (២៤) | | *ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ១៩៥៦* | | *ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៥៥* | |
| មុខរបរបច្ចុប្បន្ន (២៥) | | *កសិករ* | | *ជាងសំណង់* | |
| ទីលំនៅបច្ចុប្បន្ន (២៦) | | *ភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា* | | *ភូមិក្ដីចាស់ សង្កាត់បាក់ខែង ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា* | |
| នាមត្រកូល និង នាមខ្លួនម្ដាយ (២៧) | | *សែម បុប្ផា* (២៨) | សញ្ជាតិ *ខ្មែរ* | *នួន ផល្លា* | សញ្ជាតិ *ខ្មែរ* |
| ជាអក្សរឡាតាំង (២៩) | | SEM BOPHA (៣០) | រស់ ឬ ស្លាប់ | NUON PHALLA | រស់ ឬ ស្លាប់ |
| ថ្ងៃ ខែ ឆ្នាំកំណើត (៣១) | | *ថ្ងៃទី០៥ ខែមករា ឆ្នាំ១៩៥៨* | | *ថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៦០* | |
| មុខរបរបច្ចុប្បន្ន (៣២) | | *ជាងកាត់ដេរ* | | *លក់ដូរ* | |
| ទីលំនៅបច្ចុប្បន្ន (៣៣) | | *ភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា* | | *ភូមិក្ដីចាស់ សង្កាត់បាក់ខែង ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា* | |
| ព័ត៌មានសាក្សី | | សាក្សី | | សាក្សី | |
| នាមត្រកូល និង នាមខ្លួន (៣៤) | | *សោម ទុយ* (៣៥) | ភេទ *ប្រុស* | *សេង ភក្ដី* | ភេទ *ស្រី* |
| សញ្ជាតិ (៣៦) | | *ខ្មែរ* | | *ខ្មែរ* | |
| ថ្ងៃ ខែ ឆ្នាំកំណើត (៣៧) | | *ថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ១៩៧២* | | *ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ១៩៧០* | |
| មុខរបរបច្ចុប្បន្ន (៣៨) | | *កសិករ* | | *គ្រូបង្រៀន* | |
| ទីលំនៅបច្ចុប្បន្ន (៣៩) | | *ភូមិក្ដីចាស់ សង្កាត់បាក់ខែង ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា* | | *ភូមិក្ដីចាស់ សង្កាត់បាក់ខែង ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា* | |
| លេខអត្តសញ្ញាណប័ណ្ណ (៤០) | | | | | |

ជនណាបានរាយការណ៍មិនពិតអំពីអ**ត្រានុកូលដ្ឋាន** មន្ត្រីអត្រានុកូលដ្ឋានណាបានសមគំនិត ឃុបឃិត ក្លែងបន្លំ **ចុះសៀវភៅអត្រានុកូលដ្ឋានអោយប្រជាពលរដ្ឋ** **ដែលមកសុំ ជននោះ និង មន្ត្រីអត្រានុកូលដ្ឋាននោះនឹងត្រូវទទួលទោសតាមបញ្ញត្តិច្បាប់ ។**

(៤២) ធ្វើនៅ.....បាក់ខែង ............ ថ្ងៃទី *២០* ខែ *កុម្ភៈ* ឆ្នាំ *២០១២*

(៤១) **ស្នាមមេដៃស្តាំ**

| ប្ដី | ប្រពន្ធ | សាក្សី | សាក្សី |
|---|---|---|---|
| *សាយ សំអាន* | *អ៊ូ នួន ស្រី* | *សោម ទុយ* | *សេង ភក្ដី* |

(៤៣) **មន្ត្រីអត្រានុកូលដ្ឋាន**

***មេឃុំ***

(៤៤) *ហត្ថលេខា និងត្រា*

***នៃ សុខី***

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង រាជធានី(១) ----- ភ្នំពេញ -----

ស្រុក ខណ្ឌ (២) ----- ឫស្សីកែវ -----

ឃុំ សង្កាត់ (៣) ----- បាក់ខែង -----

លេខ (៤)-------០៩---------------------------

សៀវភៅអាពាហ៍ពិពាហ៍លេខ (៥)-០១/២០១២

ឆ្នាំ (៦)-------- ២០១២ -----------------------

# សំបុត្រអាពាហ៍ពិពាហ៍

| អំពីប្ដី ប្រពន្ធ | | ប្ដី | ប្រពន្ធ |
|---|---|---|---|
| នាមត្រកូល (៧) | | សាយ | អ៊ូ |
| នាមខ្លួន (៨) | | សំអាន | នួនស្រី |
| ជាអក្សរឡាតាំង (៩) | នាមត្រកូល | SAY | OU |
| | នាមខ្លួន | SAM ANN | NUON SREY |
| សញ្ជាតិ (១០) | | ខ្មែរ | ខ្មែរ |
| ថ្ងៃ ខែ ឆ្នាំកំណើត (១១) | | ថ្ងៃពុធ ទី២៥ ខែសីហា ឆ្នាំ១៩៧៣ | ថ្ងៃច័ន្ទ ទី១៧ ខែមករា ឆ្នាំ១៩៧៤ |
| ទីកន្លែងកំណើត (១២)<br>ភូមិ ឃុំសង្កាត់ ស្រុកខណ្ឌ ខេត្ត ក្រុង ប្រទេស | | ភូមិពញាឮ ឃុំពញាឮ ស្រុកពញាឮ ខេត្តកណ្ដាល ប្រទេសកម្ពុជា | ភូមិក្ដីចាស់ ឃុំបាក់ខែង ស្រុកមុខកំពូល ខេត្តកណ្ដាល ប្រទេសកម្ពុជា |
| មុខរបរពេលចុះបញ្ជីអាពាហ៍ពិពាហ៍ (១៣) | | សាស្ត្រាចារ្យ | គ្រូពេទ្យ |
| ទីលំនៅពេលចុះបញ្ជីអាពាហ៍ពិពាហ៍ (១៤) | | ភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា | ភូមិក្ដីចាស់ សង្កាត់បាក់ខែង ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា |
| ថ្ងៃ ខែ ឆ្នាំចុះបញ្ជីអាពាហ៍ពិពាហ៍ (១៥) | | ថ្ងៃ សុក្រ ទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១២ | |
| ទីកន្លែងចុះបញ្ជីអាពាហ៍ពិពាហ៍ (១៦) | | សង្កាត់បាក់ខែង ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | |
| អំពីឪពុក ម្ដាយ | | ខាងប្ដី | ខាងប្រពន្ធ |
| នាមត្រកូល និង នាមខ្លួនឪពុក (១៧) | | សាយ សំអឿន | អ៊ូ សែម |
| ជាអក្សរឡាតាំង (១៨) | | SAY SAM OEUN | OU SEM |
| សញ្ជាតិ (១៩) | | ខ្មែរ | ខ្មែរ |
| ថ្ងៃ ខែ ឆ្នាំកំណើត (២០) | | ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ១៩៤៦ | ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៥៥ |
| នាមត្រកូល និង នាមខ្លួនម្ដាយ (២១) | | សែម បុប្ផា | នួន ផល្លា |
| ជាអក្សរឡាតាំង (២២) | | SEM BOPHA | NUON PHALLA |
| សញ្ជាតិ (២៣) | | ខ្មែរ | ខ្មែរ |
| ថ្ងៃ ខែ ឆ្នាំកំណើត (២៤) | | ថ្ងៃទី០៥ ខែមករា ឆ្នាំ១៩៤៨ | ថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៦០ |

(២៥) ធ្វើនៅ.... បាក់ខែង .... ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១២

(២៦) មន្ត្រីអត្រានុកូលដ្ឋាន

មេឃុំ

(២៧) ហត្ថលេខា និងត្រា

កែវ សុទី

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

~~ខេត្ត~~ ក្រុង រាជធានី(១) ----- ភ្នំពេញ----
~~ក្រុង ស្រុក~~ ខណ្ឌ (២) ----- ឫស្សីកែវ ---
~~ឃុំ~~ សង្កាត់ (៣) ----- បាក់ខែង ----

# សេចក្ដីចម្លងសំបុត្រអាពាហ៍ពិពាហ៍

| ចម្លងសំបុត្រអាពាហ៍ពិពាហ៍ចេញពី | | (៤) សៀវភៅអាពាហ៍ពិពាហ៍ លេខ ៖--- ០១/២០១២------ | (៥) សំបុត្រអាពាហ៍ពិពាហ៍ លេខ ០៥ ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១២ |
|---|---|---|---|
| អំពីប្ដី ប្រពន្ធ | | ប្ដី | ប្រពន្ធ |
| នាមត្រកូល (៦) | | សាយ | អ៊ូ |
| នាមខ្លួន (៧) | | សំអាន | នួនស្រី |
| ជាអក្សរឡាតាំង (៨) | នាមត្រកូល | SAY | OU |
| | នាមខ្លួន | SAM ANN | NUON SREY |
| សញ្ជាតិ (៩) | | ខ្មែរ | ខ្មែរ |
| ថ្ងៃ ខែ ឆ្នាំកំណើត (១០) | | ថ្ងៃពុធ ទី២៥ ខែសីហា ឆ្នាំ១៩៧៣ | ថ្ងៃច័ន្ទ ទី១៧ ខែមករា ឆ្នាំ១៩៧៥ |
| ទីកន្លែងកំណើត (១១) ភូមិ ឃុំសង្កាត់ ស្រុកខណ្ឌ ខេត្តរាជ ក្រុង ប្រទេស | | ភូមិពញាឮ ឃុំពញាឮ ស្រុកពញាឮ ខេត្តកណ្ដាល ប្រទេសកម្ពុជា | ភូមិក្តីចាស់ ឃុំបាក់ខែង ស្រុកមុខកំពូល ខេត្តកណ្ដាល ប្រទេសកម្ពុជា |
| មុខរបរពេលចុះបញ្ជីអាពាហ៍ពិពាហ៍ (១២) | | សាស្ត្រាចារ្យ | គ្រូពេទ្យ |
| ទីលំនៅពេលចុះបញ្ជីអាពាហ៍ពិពាហ៍ (១៣) | | ភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា | ភូមិក្តីចាស់ សង្កាត់បាក់ខែង ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា |
| ថ្ងៃ ខែ ឆ្នាំចុះបញ្ជីអាពាហ៍ពិពាហ៍ (១៤) | | ថ្ងៃ សុក្រ ទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១២ | |
| ទីកន្លែងចុះបញ្ជីអាពាហ៍ពិពាហ៍ (១៥) | | សង្កាត់បាក់ខែង ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | |
| អំពីឪពុក ម្ដាយ | | ខាងប្ដី | ខាងប្រពន្ធ |
| នាមត្រកូល និង នាមខ្លួនឪពុក (១៦) | | សាយ សំអឿន | អ៊ូ សែម |
| ជាអក្សរឡាតាំង (១៧) | | SAY SAM OEUN | OU SEM |
| សញ្ជាតិ (១៨) | | ខ្មែរ | ខ្មែរ |
| ថ្ងៃ ខែ ឆ្នាំកំណើត (១៩) | | ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ១៩៤៦ | ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៥៥ |
| នាមត្រកូល និង នាមខ្លួនម្ដាយ (២០) | | សែម បុប្ផា | នួន ផល្លា |
| ជាអក្សរឡាតាំង (២១) | | SEM BOPHA | NUON PHALLA |
| សញ្ជាតិ (២២) | | ខ្មែរ | ខ្មែរ |
| ថ្ងៃ ខែ ឆ្នាំកំណើត (២៣) | | ថ្ងៃទី០៥ ខែមករា ឆ្នាំ១៩៤៨ | ថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៥០ |

(២៤) ធ្វើនៅ.... បាក់ខែង.... ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១២

(២៥) មន្ត្រីអត្រានុកូលដ្ឋាន-----
មេឃុំ
(២៦) ហត្ថលេខា និងត្រា
កែ សុទី

**ឧបសម្ព័ន្ធ២៖**

**នីតិវិធីសំណុំរឿងរដ្ឋប្បវេណីមិនមែនបណ្ដឹង**

- គំរូដីកាកោះអ្នកដាក់ពាក្យសុំ
- គំរូដីកាកោះភាគីម្ខាងទៀត
- គំរូលិខិតអញ្ជើញមេធាវី
- គំរូដីកាសម្រេចលើរឿងក្ដីរដ្ឋប្បវេណីមិនមែនបណ្ដឹង
- គំរូលិខិតបញ្ជាក់ការចូលស្ថាពរនៃដីកាសម្រេច

-

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រឡាបញ្ជី

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងរដ្ឋប្បវេណីមិនមែនបណ្តឹង
លេខ៖ ចុះថ្ងៃទី ខែ ឆ្នាំ

# ដីកាកោះ

យើង ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

- អញ្ជើញ ៖ លោកស្រី កើតថ្ងៃទី ខែ ឆ្នាំ
ជនជាតិខ្មែរ ជាភាគីម្ខាងទៀត
- អាសយដ្ឋាន ៖ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ
- ឱ្យចូលខ្លួនទៅកាន់ ៖ សាលាដំបូងរាជធានីភ្នំពេញ បន្ទប់ ជាន់ទី
- នៅថ្ងៃទី ៖ ថ្ងៃទី ខែ ឆ្នាំ វេលាម៉ោង និង នាទីព្រឹក
- ដើម្បី ៖ ចូលរួមនីតិវិធីសាកសួរ
- ពីដំណើររឿង ៖ សុំឱ្យតុលាការចេញដីកាសម្រេចលែងលះតាមការព្រមព្រៀង។

សាមីខ្លួនត្រូវអញ្ជើញតាមដីកាកោះនេះឱ្យបានទាន់ពេលវេលា និងយកលិខិតផ្សេងៗដែលទាក់ទងនឹងរឿងខាងលើមកជាមួយផង ប្រសិនបើមាន។

ថ្ងៃ កើត ខែ ឆ្នាំ ត្រីស័ក ព.ស.២៥
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ
ចៅក្រម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រឡាបញ្ជី

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងរដ្ឋប្បវេណីមិនមែនបណ្តឹង
លេខ៖ ចុះថ្ងៃទី ខែ ឆ្នាំ

# <u>ដីកាកោះ</u>

យើង ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

- អញ្ជើញ ៖ លោក កើតថ្ងៃទី ខែ ឆ្នាំ
  ជនជាតិខ្មែរ ជាភាគីអ្នកដាក់ពាក្យសុំ
- អាសយដ្ឋាន ៖ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ
- ឱ្យចូលខ្លួនទៅកាន់ ៖ សាលាដំបូងរាជធានីភ្នំពេញ **បន្ទប់ ជាន់ទី**
- នៅថ្ងៃទី ៖ ថ្ងៃទី ខែ ឆ្នាំ វេលាម៉ោង និង នាទីព្រឹក
- ដើម្បី ៖ ចូលរួមនីតិវិធីសាកសួរ
- ពីដំណើររឿង ៖ សុំឱ្យតុលាការចេញដីកាសម្រេចលែងលះតាមការព្រមព្រៀង។

សាមីខ្លួនត្រូវអញ្ជើញតាមដីកាកោះនេះឱ្យបានទាន់ពេលវេលា និងយកលិខិតផ្សេងៗដែលទាក់ទងនឹងរឿងខាងលើមកជាមួយផង ប្រសិនបើមាន។

ថ្ងៃ ខែ ឆ្នាំ ត្រីស័ក ព.ស.២៥
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ
ចៅក្រម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រឡាបញ្ជី

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងរដ្ឋប្បវេណីមិនមែនបណ្តឹង

លេខ៖ ចុះថ្ងៃទី ខែ ឆ្នាំ

# លិខិតអញ្ជើញ

យើង ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

បានឃើញ លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ ចុះថ្ងៃទី ខែ ឆ្នាំ របស់លោក និងលោក ។

- អញ្ជើញ ៖ លោក និងលោក ជាមេធាវីតំណាងដោយអាណត្តិឱ្យភាគីអ្នកដាក់ពាក្យសុំ
- អាសយដ្ឋាន ៖ លេខ ផ្លូវលេខ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ
- ឱ្យចូលខ្លួនទៅកាន់ ៖ សាលាដំបូងរាជធានីភ្នំពេញ **បន្ទប់ ជាន់ទី**
- នៅថ្ងៃទី ៖ ថ្ងៃទី ខែ ឆ្នាំ វេលាម៉ោង និង នាទីព្រឹក
- ដើម្បី ៖ ចូលរួមនីតិវិធីសាកសួរ
- ពីដំណើររឿង ៖ សុំឱ្យតុលាការចេញដីកាសម្រេចលែងលះតាមការព្រមព្រៀង។

សាមីខ្លួនត្រូវអញ្ជើញតាមលិខិតអញ្ជើញនេះឱ្យបានទាន់ពេលវេលា និងយកលិខិតផ្សេងៗដែលទាក់ទងនឹងរឿងខាងលើមកជាមួយផង ប្រសិនបើមាន។

ថ្ងៃ ខែ ឆ្នាំ ស័ក ព.ស.

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ

**ចៅក្រម**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**<u>សាលាដំបូងរាជធានីភ្នំពេញ</u>**

**ដីកាសម្រេច**
-លេខ៖.................
ចុះថ្ងៃទី....... ខែ.......... ឆ្នាំ.....
-សំណុំរឿងរដ្ឋប្បវេណីមិនមែនជាបណ្តឹង
លេខ....... ចុះថ្ងៃទី... ខែ ... ឆ្នាំ .......

## <u>ដីកាសម្រេច</u>
## <u>រឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង</u>

យើង ............................ ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

ដោយមានលោក ............................ ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

**បានឃើញ** មាត្រា៣ និងមាត្រាពាក់ព័ន្ធនឹងច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

**បានឃើញ** តារាងឧបសម្ព័ន្ធផ្នែកទី៤ ចំណុច៥ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនបណ្តឹង

**បានឃើញ** សំណុំរឿងរដ្ឋប្បវេណីមិនមែនជាបណ្តឹង លេខ......... ចុះថ្ងៃទី....... ខែ ....... ឆ្នាំ ......... របស់សាលាដំបូងរាជធានីភ្នំពេញ

**បានឃើញ** ពាក្យសុំលែងលះដោយការព្រមព្រៀងចុះថ្ងៃទី....... ខែ ....... ឆ្នាំ ......... របស់មេធាវី............ ជាមេធាវីតំណាងដោយអាណត្តិឱ្យអ្នកដាក់ពាក្យសុំឈ្មោះ..................

**-អ្នកដាក់ពាក្យសុំ៖** លោក ............ ថ្ងៃខែឆ្នាំកំណើត....................... ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ...................... ចុះថ្ងៃទី....... ខែ ....... ឆ្នាំ ......... មានអាសយដ្ឋានស្ថិតនៅ ..............................។

**-មេធាវីតំណាងដោយអាណត្តិ៖**

**-ភាគីម្ខាងទៀត៖** លោកស្រី .......... ខែឆ្នាំកំណើត.......................... ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ...................... ចុះថ្ងៃទី....... ខែ ....... ឆ្នាំ ......... មានអាសយដ្ឋានស្ថិតនៅ ..............................។

## អង្គហេតុនិងចំណុចវិវាទ

**១. <u>ខ្លឹមសារនៃដីកាសម្រេចដែលអ្នកដាក់ពាក្យសុំឱ្យតុលាការចេញ</u>**

១.១ ស្នើសុំលែងលះរវាងភាគីអ្នកដាក់ពាក្យសុំ ..................... និងភាគីម្ខាងទៀត................។

១.២ កំណត់យកអ្នកដាក់ពាក្យសុំ ................ ជាអ្នកមានសិទ្ធិអំណាចមេបាលើកូនឈ្មោះ ................. ភេទ... ថ្ងៃខែឆ្នាំកំណើត.........................។

១.៣ បែងចែកទ្រព្យសម្បត្តិរួមឱ្យទៅភាគី .......................... ស្របតាមការព្រមព្រៀងគ្នារបស់គូភាគី។

១.៤ ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់....................។

២. **<u>អំពីរឿងក្តី</u>**

ភាគីអ្នកដាក់ពាក្យសុំ និងភាគីម្ខាងទៀត បានរៀបអាពាហ៍ពិពាហ៍នៅថ្ងៃទី ....... ខែ ........ ឆ្នាំ .......... និងបានចុះសំបុត្រអាពាហ៍ពិពាហ៍លេខ ....... ចុះថ្ងៃទី......... ខែ......... ឆ្នាំ............ ចេញដោយមន្ត្រីអត្រានុកូលដ្ឋាន ................។ ....................................................។

**៣. អង្គហេតុដែលអះអាងដោយអ្នកដាក់ពាក្យសុំ៖**

អ្នកដាក់ពាក្យសុំ ...................... បានអះអាងនាពេលសាកសួរថា៖.....................................
....................................................................

**៤. អង្គហេតុដែលអះអាងដោយភាគីម្ខាងទៀត៖**

ភាគីម្ខាងទៀត ................... បានអះអាងនាពេលសាកសួរថា៖.....................................
....................................................................

**៥. អង្គហេតុដែលគ្មានវិវាទ**

-ភាគីបានឯកភាពគ្នាលែងលះជាមួយគ្នាដោយស្ម័គ្រចិត្ត។

-ភាគីបានឯកភាពគ្នាប្រគល់សិទ្ធិអំណាចមេបាឱ្យអ្នកដាក់ពាក្យសុំ ......................... ។

-ភាគីបានឯកភាពគ្នាបែងចែកទ្រព្យសម្បត្តិឱ្យទៅភាគីអ្នកដាក់ពាក្យសុំ ....................។

## ការពិនិត្យភស្តុតាង

**១-ភស្តុតាងជាឯកសាររបស់អ្នកដាក់ពាក្យសុំ**

-សំបុត្រអាពាហ៍ពិពាហ៍លេខ ..... ចុះថ្ងៃទី....... ខែ......... ឆ្នាំ......... ចេញដោយមន្ត្រីអត្រានុកូលដ្ឋាន ...............។

-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ...........................ចុះថ្ងៃទី....... ខែ......... ឆ្នាំ......... របស់អ្នកដាក់ពាក្យសុំឈ្មោះ................................។

-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ...........................ចុះថ្ងៃទី....... ខែ......... ឆ្នាំ......... របស់ភាគីម្ខាងទៀតឈ្មោះ................................។

-សំបុត្រកំណើតលេខ..... ចុះថ្ងៃទី........... ខែ........... ឆ្នាំ............ ចេញដោយមន្ត្រីអត្រានុកូលដ្ឋាន ................................. របស់ឈ្មោះ.........................។

-សៀវភៅគ្រួសារលេខ..................... ចុះថ្ងៃទី........... ខែ........... ឆ្នាំ................ ចេញដោយស្នងការនគរបាលរាជធានីភ្នំពេញ។

-វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ .............................. ចុះថ្ងៃទី............ ខែ........... ឆ្នាំ........... ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី...................។

-វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ .............................. ចុះថ្ងៃទី............ ខែ........... ឆ្នាំ........... ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី...................។

## សំអាងហេតុ

១-ពាក្យសុំលែងលះដោយការព្រមព្រៀងចុះថ្ងៃទី .......... ខែ............ ឆ្នាំ.......... របស់អ្នកដាក់ពាក្យសុំត្រូវនឹងផ្នែកទី៤ ចំណុច៥ នៃតារាងឧបសម្ព័ន្ធនៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ហើយយោងតាមមាត្រា ៣ នៃច្បាប់នេះ តុលាការត្រូវសម្រេចសេចក្តីដោយដីកាសម្រេច។

២-តាមការអះអាងរបស់ភាគីអ្នកដាក់ពាក្យសុំនិងភាគីម្ខាងទៀតនាពេលសាកសួរ និងតាមភស្តុតាងបានដាក់ជូនតុលាការ បញ្ជាក់ថា ភាគីទាំងពីរបានរៀបអាពាហ៍ពិពាហ៍នៅថ្ងៃទី....... ខែ........ ឆ្នាំ............ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍លេខ......... ចុះថ្ងៃទី.......... ខែ........... ឆ្នាំ............ ចេញដោយមន្ត្រីអត្រានុកូលដ្ឋាន............... ប្រាកដមែន។

៣-ភាគីអ្នកដាក់ពាក្យសុំ និងភាគីម្ខាងទៀត បានស្នើសុំលែងលះតាមការព្រមព្រៀងដោយឆន្ទៈរបស់ខ្លួនប្រាកដមែន ពុំមានការបង្ខិតបង្ខំឡើយ ដូចមានក្នុងកិច្ចព្រមព្រៀងលែងលះ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០២២ ឃើញថាការស្នើសុំនេះ ត្រឹមត្រូវស្របតាមបញ្ញត្តិមាត្រា ៩៧៩ នៃក្រមរដ្ឋប្បវេណី។

៤-តាមកំណត់ហេតុសាកសួរ ចុះថ្ងៃទី.... ខែ...... ឆ្នាំ...... បានបញ្ជាក់ថា ក្នុងចំណងអាពាហ៍ពិពាហ៍ភាគីទាំងពីរមានកូនចំនួន ១ នាក់ ឈ្មោះ ............ ភេទ...... ថ្ងៃខែឆ្នាំកំណើត.................. មានសំបុត្រកំណើតលេខ..... ចុះថ្ងៃទី........... ខែ........... ឆ្នាំ............ ចេញដោយមន្ត្រីអត្រានុកូលដ្ឋាន.................................. ដែលមិនទាន់ពេញនីតិភាពនៅឡើយ។ គូភាគីបានព្រមព្រៀងគ្នាកំណត់យក អ្នកដាក់ពាក្យសុំ ជាអ្នកមានសិទ្ធិអំណាចមេបាលើកូន ហើយភាគីម្ខាងទៀតមានសិទ្ធិទៅសួរសុខទុក្ខ និងចូលជួបប្រាស្រ័យទាក់ទងដោយត្រូវជូនដំណឹងដល់ភាគីអ្នកមានសិទ្ធិអំណាចមេបាជាមុនសិន គប្បីតុលាការពិនិត្យនិងសម្រេចតាមការព្រមព្រៀងរបស់គូភាគី។

៥-គូភាគីពុំទាន់បានកំណត់អំពីចំនួននៃការបង់សោហ៊ុយចាំបាច់សម្រាប់ចិញ្ចឹមកូននៅឡើយទេ គប្បីតុលាការមិនលើកយកមកពិចារណាទេ ទុកសិទ្ធិឱ្យគូភាគីពិភាក្សាគ្នាតាមការព្រមព្រៀង។

៦-នាពេលសាកសួរ និងតាមការព្រមព្រៀងគ្នារបស់គូភាគី គូភាគីបានអះអាងថា គូភាគីឯកភាពចំពោះការបែងចែកទ្រព្យសម្បត្តិរួមឱ្យទៅភាគីអ្នកដាក់ពាក្យសុំ ជាម្ចាស់កម្មសិទ្ធិករទាំងស្រុង ដែលតុលាការគប្បីសម្រេចតាមការព្រមព្រៀងរបស់គូភាគី។

៧-ប្រាក់ប្រដាប់ក្ដីអនុវត្តតាមមាត្រា ២២ នៃច្បាប់ស្ដីពី នីតិវិធីរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង។

## សេចក្ដីសម្រេចបញ្ចប់

១-ឱ្យភាគីអ្នកដាក់ពាក្យសុំឈ្មោះ.......................... កើតថ្ងៃទី....... ខែ............ ឆ្នាំ............ និងភាគីម្ខាងទៀតឈ្មោះ.................. កើតថ្ងៃទី............ ខែ............ ឆ្នាំ............ លែងលះតាមការព្រមព្រៀង។

២-កំណត់យកអ្នកដាក់ពាក្យសុំ ................ ជាអ្នកមានសិទ្ធិអំណាចមេបាលើកូនឈ្មោះ ................. ភេទ... ថ្ងៃខែឆ្នាំកំណើត..........................។

ដោយឡែក ភាគីដែលពុំមានសិទ្ធិអំណាចមេបាមានសិទ្ធិចូលជួបប្រាស្រ័យទាក់ទងជាមួយកូនបាន ដោយជូនដំណឹងទៅភាគីអ្នកមានសិទ្ធិអំណាចមេបាជាមុនសិន ហើយភាគីដែលមានសិទ្ធិអំណាចមេបាត្រូវបង្កភាពងាយស្រួលតាមការពិភាក្សាជាក់ស្ដែង។

៣-បែងចែកទ្រព្យសម្បត្តិទៅឱ្យអ្នកដាក់ពាក្យសុំលោក........................ រួមមាន៖

៣.១ អចលនវត្ថុជាដីនិងផ្ទះ ដែលមានទំហំ ...... ម$^2$ មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនតវត្ថុលេខ.............................. ចុះថ្ងៃទី............. ខែ............ ឆ្នាំ ........... ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី................. មានទីតាំងស្ថិតនៅភូមិ............ ឃុំ............. ស្រុក............ ខេត្ត..........។

៣.២ អចលនវត្ថុជាដីនិងផ្ទះ ដែលមានទំហំ ...... ម$^2$ មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ .............................. ចុះថ្ងៃទី............. ខែ............ ឆ្នាំ ........... ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី.................. មានទីតាំងស្ថិតនៅភូមិ............ ឃុំ.............. ស្រុក............ ខេត្ត..........។

ភាគីម្ខាងទៀត............. ធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិអចលនវត្ថុ ដូចមាននៅក្នុងសេចក្តីសម្រេច ចំណុច ៣.១ ដល់ចំណុច ៣.២ ឱ្យទៅភាគីអ្នកដាក់ពាក្យសុំ..................។

៤-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់អ្នកដាក់ពាក្យសុំ។

**ចៅក្រម**

**ហត្ថលេខានិងត្រា៖**..........................

---

**បានឃើញ**

**ចៅក្រម**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃ............ ខែ........... ឆ្នាំ..... ... ស័ក ព.ស. .......

រាជធានីភ្នំពេញ ថ្ងៃទី ........ ខែ ........ ឆ្នាំ..........

**ក្រឡាបញ្ជី**

# ឧបសម្ព័ន្ធ៣៖
# នីតិវិធីសំណុំរឿងរដ្ឋប្បវេណីទាក់ទងនឹងការលែងលះ

- គំរូដីកាកោះ
- គំរូលិខិតអញ្ជើញមេធាវី
- គំរូសាលក្រម (ដកចេញពីគេហទំព័រក្រសួងយុត្តិធម៌)
- គំរូលិខិតបញ្ជាក់ការចូលស្ដាពរ
- គំរូរូបមន្តអនុវត្ត

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**<u>សាលាដំបូងរាជធានីភ្នំពេញ</u>**

# ដីកាកោះ

<table>
<tr><td colspan="2">អញ្ជើញឈ្មោះ ................ ភេទ ........ កើតថ្ងៃទី ...... ខែ........... ឆ្នាំ ........... ជា .................។<br>អាសយដ្ឋាន៖<br>ទូរសព្ទលេខ៖</td></tr>
<tr><td>សញ្ញាណនៃរឿងក្តី (លេខ និង ភាគី)<br>-ប្តឹងសុំសាលក្រម..............</td><td>សំណុំរឿងរដ្ឋប្បវេណីលេខ ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ...<br>-ដើមចោទឈ្មោះ ............. ភេទ ........ កើតថ្ងៃទី ...... ខែ........... ឆ្នាំ ........... សញ្ជាតិខ្មែរ។<br>-ចុងចម្លើយឈ្មោះ ............. ភេទ ........ សញ្ជាតិខ្មែរ។</td></tr>
<tr><td>កាលបរិច្ឆេទ និង ទីកន្លែងដែលត្រូវបង្ហាញខ្លួន</td><td>ថ្ងៃទី ... ខែ ... ឆ្នាំ ... វេលាម៉ោង ... និង ... នាទី ។<br>បន្ទប់ “.......” ជាន់ទី .... នៃសាលាដំបូងរាជធានីភ្នំពេញ</td></tr>
<tr><td>ប្រភេទដំណាក់កាលនៃនីតិវិធី</td><td>១. ការទាញហេតុផលដោយផ្ទាល់មាត់☐ ២. ការប្រកាសសាលក្រម☐<br>៣. ការផ្សះផ្សា☐ ៤. នីតិវិធីត្រៀម☑ ៥. សាកសួរ☐</td></tr>
<tr><td>ប្រភេទនៃឯកសារដែលភ្ជាប់ជាមួយ</td><td>..........................................................................................<br>..........................................................................................</td></tr>
<tr><td>ទណ្ឌកម្ម ជាអាទិ៍ក្នុងករណីដែលមិនបានបង្ហាញខ្លួនដោយគ្មានមូលហេតុត្រឹមត្រូវ</td><td>១. ចំពោះសាមីភាគី៖ បើពុំចូលខ្លួននោះតុលាការអាចទទួលស្គាល់ថា សេចក្តីអះអាងអំពីចំណុចសាកសួររបស់ភាគីម្ខាងទៀតជាការពិតបាន។ (តាមមាត្រា ១៤០ កថាខណ្ឌទី២ ក្រមនីតិវិធីរដ្ឋប្បវេណី)<br>២. ចំពោះសាក្សី៖ បើមិនព្រមចូលខ្លួនមកតុលាការដោយគ្មានមូលហេតុត្រឹមត្រូវ តុលាការអាចពិន័យជាប្រាក់ចំនួនមិនលើសពី ១.០០០.០០០ (មួយលាន) រៀល។</td></tr>
<tr><td colspan="2">សូមបង្ហាញខ្លួនតាមវេលា និងទីកន្លែងដែលបានកំណត់ខាងលើ។<br>ថ្ងៃ............ ខែ........... ឆ្នាំ..... ... ស័ក ព.ស. .......<br>រាជធានីភ្នំពេញ ថ្ងៃទី ........ ខែ ........ ឆ្នាំ..........<br>ចៅក្រម</td></tr>
</table>

**<u>បញ្ជាក់៖</u>** ក្នុងករណីដែលមានជម្ងឺ ឬមានមូលហេតុផ្សេងទៀតដែលមិនអាចបង្ហាញខ្លួនបាន សូមដាក់ឯកសារបញ្ជាក់របស់វេជ្ជបណ្ឌិត ឬបញ្ជាក់មូលហេតុនោះ ជូនតុលាការ។ ពេលបង្ហាញខ្លួនសូមយកដីកាកោះជូនក្រឡាបញ្ជីទទួលបន្ទុក។

**សាលាដំបូងរាជធានីភ្នំពេញ**

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

# លិខិតអញ្ជើញ

| | |
|---|---|
| អញ្ជើញឈ្មោះ ................ ជាមេធាវីតំណាងដោយអាណត្តិឱ្យ**ដើមចោទ/ចុងចម្លើយ**។<br>អាសយដ្ឋាន៖ | |
| សញ្ញាណនៃរឿងក្តី (លេខ និង ភាគី)<br>-ប្តឹងសុំសាលក្រម............... | សំណុំរឿងរដ្ឋប្បវេណីលេខ ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ...<br>-ដើមចោទឈ្មោះ ............. ភេទ ........ កើតថ្ងៃទី ...... ខែ.......... ឆ្នាំ .......... សញ្ជាតិខ្មែរ។<br>-ចុងចម្លើយឈ្មោះ ............. ភេទ ........ សញ្ជាតិខ្មែរ។ |
| កាលបរិច្ឆេទ និង ទីកន្លែងដែលត្រូវបង្ហាញខ្លួន | ថ្ងៃទី ... ខែ ... ឆ្នាំ ... វេលាម៉ោង ... និង ... នាទី ។<br>បន្ទប់ "......." ជាន់ទី .... នៃសាលាដំបូងរាជធានីភ្នំពេញ |
| ប្រភេទដំណាក់កាលនៃនីតិវិធី | ១. ការទាញហេតុផលដោយផ្ទាល់មាត់☐ ២. ការប្រកាសសាលក្រម☐<br>៣. ការផ្សះផ្សា☐ ៤. នីតិវិធីត្រៀម☑ ៥. សាកសួរ☐ |
| ប្រភេទនៃឯកសារដែលភ្ជាប់ជាមួយ | ..............................................................................................<br>.............................................................................................. |
| ទណ្ឌកម្ម ជាអាទិ៍ក្នុងករណីដែលមិនបានបង្ហាញខ្លួនដោយគ្មានមូលហេតុត្រឹមត្រូវ | **១. ចំពោះសាមីភាគី៖** បើពុំចូលខ្លួននោះតុលាការអាចទទួលស្គាល់ថា សេចក្តីអះអាងអំពីចំណុចសាកសួររបស់ភាគីម្ខាងទៀតជាការពិតបាន។ (តាមមាត្រា ១៤០ កថាខណ្ឌទី២ ក្រមនីតិវិធីរដ្ឋប្បវេណី)<br>**២. ចំពោះសាក្សី៖** បើមិនព្រមចូលខ្លួនមកតុលាការដោយគ្មានមូលហេតុត្រឹមត្រូវ តុលាការអាចពិន័យជាប្រាក់ចំនួនមិនលើសពី ១.០០០.០០០ (មួយលាន) រៀល។ |
| សូមបង្ហាញខ្លួនតាមវេលា និងទីកន្លែងដែលបានកំណត់ខាងលើ។<br>ថ្ងៃ........... ខែ.......... ឆ្នាំ..... ... ស័ក ព.ស. .......<br>រាជធានីភ្នំពេញ ថ្ងៃទី ........ ខែ ........ ឆ្នាំ..........<br>**ចៅក្រម** | |

**បញ្ជាក់៖** ក្នុងករណីដែលមានជម្ងឺ ឬមានមូលហេតុផ្សេងទៀតដែលមិនអាចបង្ហាញខ្លួនបាន សូមដាក់ឯកសារបញ្ជាក់របស់វេជ្ជបណ្ឌិត ឬបញ្ជាក់មូលហេតុនោះ ជូនតុលាការ។ ពេលបង្ហាញខ្លួនសូមយកដីកាកោះជូនក្រឡាបញ្ជីទទួលបន្ទុក។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងខេត្តបាត់ដំបង

**តុលាការរដ្ឋប្បវេណី**
សំណុំរឿងរដ្ឋប្បវេណីលេខ .......
ចុះថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០២០
សាលក្រមលេខ .........
ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ២០២០

# សាលក្រម[1]
# ក្នុងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តបាត់ដំបង [2]

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅ
ថ្ងៃទី ២២ ខែកក្កដា ឆ្នាំ២០២០ [3] [4]

## ចៅក្រមជំនុំជម្រះ

លោក J ជាចៅក្រមនៃសាលាដំបូងខេត្តបាត់ដំបង

---

[1] ការសម្រេចសេចក្ដី គឺចែកចេញជា សាលក្រម និង ដីកាសម្រេច (មាត្រា ១៧៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ដូច្នេះ មានភាពចាំបាច់នៅក្នុងការបញ្ជាក់ឲ្យបានច្បាស់លាស់ថា អំពីប្រភេទនៃការសម្រេចសេចក្ដីដាក់នៅត្រង់ចំណុចចាប់ផ្ដើម។ ដោយសារតែ សាលក្រម និង ដីកាសម្រេច មានភាពខុសគ្នាចំពោះវិធីក្នុងការធ្វើឧបាស្រ័យ ជាអាទិ៍ ។ ជាគោលការណ៍ បណ្ដឹងឧបាស្រ័យចំពោះសាលក្រម គឺ បណ្ដឹងឧទ្ធរណ៍ ហើយ បណ្ដឹងឧបាស្រ័យចំពោះដីកាសម្រេច គឺ បណ្ដឹងជំទាស់ (កថាខណ្ឌទី ១ មាត្រា ២៥៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

[2] នៅក្នុងលិខិតសាលក្រមរដ្ឋប្បវេណី ត្រូវតែសរសេរអំពីចំណុចដែលចែងនៅក្នុងមាត្រា ១៨៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[3] ចំណុច ខ កថាខណ្ឌទី ១ មាត្រា ១៨៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ សាលក្រម នឹងត្រូវកំណត់ជាស្ថាពរនូវទំនាក់ទំនងសិទ្ធិ ឬទំនាក់ទំនងគតិយុត្តិ នាពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ (កថាខណ្ឌទី ២ មាត្រា ១៩៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ហេតុនេះ ចាំបាច់ត្រូវសរសេរឲ្យបានច្បាស់លាស់អំពី ពេលដែលបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់។ សាលក្រម គឺជាការសម្រេចសេចក្ដីរបស់តុលាការដែលត្រូវបានធ្វើឡើងដោយកំណត់ជាមូលដ្ឋានចម្បងនូវទំនាក់ទំនងអង្គហេតុគិតមកដល់ត្រឹមថ្ងៃបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់។

[4] ជាគោលការណ៍ ការប្រកាសសាលក្រម ត្រូវធ្វើឡើងក្នុងអំឡុងពេល ១ (មួយ) ខែ គិតចាប់ពីថ្ងៃដែលបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ (មាត្រា ១៨៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ ហើយការប្រកាសសាលក្រមចាំបាច់ត្រូវធ្វើឡើងដោយផ្អែកលើច្បាប់ដើមនៃមូលសាលក្រម (កថាខណ្ឌទី ១ មាត្រា ១៨៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ដូច្នេះហើយ ចាំបាច់ត្រូវតែបញ្ចប់នូវការតាក់តែងច្បាប់ដើមនៃមូលសាលក្រមឲ្យបាន គិតត្រឹមពេលប្រកាសសាលក្រម។

## **ក្រឡាបញ្ជី**

លោកស្រី C ជាក្រឡាបញ្ជីនៃសាលាខេត្តបាត់ដំបង

**ដើមចោទ**

ឈ្មោះ ៖ X

អាសយដ្ឋាន ៖ ផ្ទះលេខ ០០ ផ្លូវលេខ ០០ ភូមិ...... ឃុំ.......ស្រុក......... ខេត្តបាត់ដំបង។

**អ្នកតំណាងដោយអាណត្តិ**

លោក/លោកស្រី ៖ P

អាសយដ្ឋានការិយាល័យ ៖ ................................

ឈ្មោះការិយាល័យមេធាវី/ក្រុមមេធាវី/ក្រុមហ៊ុនមេធាវី ៖ .........................................

លេខទូរស័ព្ទ ៖ ..................................................

**ចុងចម្លើយ**

ឈ្មោះ ៖ Y

អាសយដ្ឋាន ៖ ផ្ទះលេខ ០០ ផ្លូវលេខ ០០ សង្កាត់មនោរម្យ ខណ្ឌ៧មករា រាជធានីភ្នំពេញ។

**អ្នកតំណាងដោយអាណត្តិ**

លោក/លោកស្រី ៖ B

អាសយដ្ឋានការិយាល័យ ៖ ................................

ឈ្មោះការិយាល័យមេធាវី/ក្រុមមេធាវី/ក្រុមហ៊ុនមេធាវី ៖ ...........................................

លេខទូរស័ព្ទ ៖ ..................................................

## អង្គហេតុ និង ចំណុចវិវាទ

### ក. ខ្លឹមសារនៃសាលក្រម និង ការចាត់ចែងបន្ទាប់បន្សំដែលដើមចោទទាមទារឲ្យតុលាការចេញ[5]៖

(១) លែងលះដើមចោទ និង ចុងចម្លើយ ។

(២) កំណត់ថា ដើមចោទជាអ្នកមានអំណាចមេបាលើកូនប្រុសរវាងដើមចោទ និង ចុងចម្លើយដែលមានឈ្មោះ សុក សុជាតិ (កើតនៅថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦) ។

(៣) កំណត់ថា ដើមចោទជាអ្នកមានអំណាចមេបាលើកូនស្រីរវាងដើមចោទ និង ចុងចម្លើយដែលមានឈ្មោះ សុក សុជាតា (កើតនៅថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១៨) ។

(៤) បង្គាប់ឲ្យចុងចម្លើយបង់ប្រាក់ចំនួន ១៥០ ដុល្លារអាមេរិកក្នុង ១ ខែ ឲ្យទៅដើមចោទ គិតត្រឹមថ្ងៃចុងក្រោយជារៀងរាល់ខែ ក្នុងអំឡុងពេលគិតចាប់ពីថ្ងៃដែលសាលក្រមនេះចូលជាស្ថាពររហូតដល់ឈ្មោះ សុក សុជាតិ ដែលបានកត់ត្រានៅក្នុងចំណុច (២) ខាងលើនេះក្លាយជានីតិជន។

(៥) បង្គាប់ឲ្យចុងចម្លើយបង់ប្រាក់ចំនួន ១៥០ ដុល្លារអាមេរិកក្នុង ១ ខែ ឲ្យទៅដើមចោទ គិតត្រឹមថ្ងៃចុងក្រោយជារៀងរាល់ខែ ក្នុងអំឡុងពេលគិតចាប់ពីថ្ងៃដែលសាលក្រមនេះចូលជាស្ថាពររហូតដល់ឈ្មោះ សុក សុជាតា ដែលបានកត់ត្រានៅក្នុងចំណុច (៣) ខាងលើនេះក្លាយជានីតិជន។

(៦) បង្គាប់ឲ្យចុងចម្លើយបង់ប្រាក់ចំនួន ១០០ ដុល្លារអាមេរិកក្នុង ១ខែ ឲ្យទៅដើមចោទ គិតត្រឹមថ្ងៃចុងក្រោយជារៀងរាល់ខែ ក្នុងអំឡុងពេលគិតចាប់ពីថ្ងៃដែលសាលក្រមនេះចូលជាស្ថាពររហូតដល់ដើមចោទរៀបអាពាហ៍ពិពាហ៍ថ្មី។

---

[5] ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ គឺជាចំណុចដែលចាំបាច់ត្រូវសរសេរនៅក្នុងពាក្យបណ្ដឹង (ចំណុច ខ កថាខណ្ឌទី ២ មាត្រា ៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ ម្យ៉ាងទៀត ប្រសិនបើតុលាការចេញសាលក្រម ឬ សាលដីកាដែលទទួលស្គាល់បណ្ដឹងទាមទារលែងលះ តុលាការនឹងត្រូវសម្រេចសេចក្ដីអំពីការចាត់ចែងបន្ទាប់បន្សំ (កំណត់អ្នកមានអំណាចមេបា ការចាត់ចែងទាក់ទងនឹងការបីបាច់រក្សាកូន ឬ ការចាត់ចែងទាក់ទងនឹងការបែងចែកទ្រព្យសម្បត្តិ) ដោយឆន្ទានុសិទ្ធិ ឬ តាមពាក្យសុំ ដូច្នេះហើយ ដើមចោទគប្បីសរសេរទុកជាមុនអំពីខ្លឹមសារនៃការចាត់ចែងបន្ទាប់បន្សំដែលទាមទារឲ្យតុលាការចេញ ទើបជាការប្រសើរ (កថាខណ្ឌទី ១ មាត្រា ២២ នៃច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល)។

(៧) បែងចែកទ្រព្យសម្បត្តិនីមួយៗ ដែលបានកត់ត្រានៅក្នុង "បញ្ជីទ្រព្យសម្បត្តិរួម" នៃឧបសម្ព័ន្ធ ដូចខាងក្រោមនេះ ៖

**ក.** ដីចំណុច ១. ដែលកត់ត្រានៅក្នុង "បញ្ជីទ្រព្យសម្បត្តិរួម" នៃឧបសម្ព័ន្ធ (តទៅហៅថា "ដី L 1") ជាកម្មសិទ្ធិអវិភាគរវាងដើមចោទ និង ចុងចម្លើយក្នុងចំណែកម្នាក់ៗចំនួន ១ ភាគ ២។

បង្គាប់ឲ្យលក់ដេញថ្លៃលើ "ដី L 1" ហើយយកចំនួនទឹកប្រាក់ដែលបានដកសោហ៊ុយសម្រាប់នីតិវិធីពីថ្លៃលក់នោះមកបែងចែកឲ្យទៅដើមចោទ និង ចុងចម្លើយក្នុងម្នាក់ៗ ចំនួន ១ ភាគ ២។

**ខ.** ដីចំណុច ២. ដែលកត់ត្រានៅក្នុង " បញ្ជីទ្រព្យសម្បត្តិរួម " នៃឧបសម្ព័ន្ធ (តទៅហៅថា "ដី L 2" ) ជាកម្មសិទ្ធិអវិភាគរវាងដើមចោទ និង ចុងចម្លើយក្នុងចំណែកម្នាក់ៗចំនួន ១ ភាគ ២ ។

បង្គាប់ឲ្យលក់ដេញថ្លៃលើ "ដី L 2" ហើយយកចំនួនទឹកប្រាក់ដែលបានដកសោហ៊ុយសម្រាប់នីតិវិធីពីថ្លៃលក់នោះមកបែងចែកឲ្យទៅដើមចោទ និង ចុងចម្លើយក្នុងម្នាក់ៗ ចំនួន ១ ភាគ ២។

គ. ឡានចំណុច ៣. ដែលបានកត់ត្រានៅក្នុង " បញ្ជីទ្រព្យសម្បត្តិរួម " នៃឧបសម្ព័ន្ធ (តទៅហៅថា " រថយន្តនៃរឿងក្តីនេះ" ) ជាកម្មសិទ្ធិរបស់ចុងចម្លើយ។

បង្គាប់ឲ្យចុងចម្លើយបង់ប្រាក់ចំនួន ៥.០០០ ដុល្លារអាមេរិកឲ្យទៅដើមចោទ។

ឃ. ម៉ូតូចំណុច ៤. ដែលបានកត់ត្រានៅក្នុង "បញ្ជីទ្រព្យសម្បត្តិរួម" នៃឧបសម្ព័ន្ធ (តទៅហៅថា "ម៉ូតូនៃរឿងក្តីនេះ" ) ជាកម្មសិទ្ធិរបស់ដើមចោទ។

ង. ប្រាក់សន្សំចំណុច ៥. ដែលបានកត់ត្រានៅក្នុង "បញ្ជីទ្រព្យសម្បត្តិរួម" នៃឧបសម្ព័ន្ធ (តទៅហៅថា " ប្រាក់សន្សំនៃរឿងក្តីនេះ") ជាកម្មសិទ្ធិចុងចម្លើយ។

បង្គាប់ឲ្យចុងចម្លើយបង់ប្រាក់ចំនួន ២៥០ ដុល្លារអាមេរិកឲ្យទៅដើមចោទ។

(៨) ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

## ខ. ដំណើររឿងក្ដី និង ចំណុចវិវាទ

### ខ.១. ការសង្ខេបអំពីរឿងក្ដី

នៅក្នុងរឿងក្ដីនេះ ដើមចោទបានអះអាងថា ទំនាក់ទំនងអាពាហ៍ពិពាហ៍ជាមួយចុងចម្លើយបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបានទេ ដូច្នេះ មានមូលហេតុនៃការលែងលះគ្នាដូចមានចែងនៅក្នុងចំណុច ង កថាខណ្ឌទី ១ មាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណី ហើយក្រៅពីធ្វើការទាមទារអំពីការលែងលះទៅកាន់ចុងចម្លើយរួចហើយ ដើមចោទក៏ទាមទារនូវការកំណត់ថាដើមចោទគឺជាអ្នកមានអំណាចមេបាលើកូនទាំងពីរ ហើយថែមទាំងបានដាក់ពាក្យសុំទាមទារនូវការបង់សោហ៊ុយចិញ្ចឹមបីបាច់ថែរក្សាកូន ការបង់អាហារកិច្ច និង ការបែងចែកទ្រព្យសម្បត្តិ ធ្វើជាការចាត់ចែងបន្ទាប់បន្សំផងដែរ។

### ខ.២. អង្គហេតុដែលជាមូលដ្ឋានដើម្បីពិចារណាអំពីចំណុចវិវាទ[6]

ខ.២.១. នៅថ្ងៃទី ៣ ខែ សីហា ឆ្នាំ ២០១៥ ដើមចោទ និង ចុងចម្លើយបានទៅចុះបញ្ជីអាពាហ៍ពិពាហ៍ ហើយបានចាប់ផ្ដើមរួមរស់ជីវភាពជាមួយគ្នានៅលំនៅដ្ឋានរបស់ចុងចម្លើយ។ (**ភស្តុតាង** $X_1$ $X_2$)

ខ.២.២. ដើមចោទមិនមានសាច់ញាតិនៅក្នុងទីក្រុងភ្នំពេញទេ។ (**ដំណើរការ និង ខ្លឹមសារនៃការទាញហេតុផលដោយផ្ទាល់មាត់**[7])

---

[6] នៅក្នុងនីតិវិធីបណ្ដឹងនៃបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល ផ្នែកដែលទាក់ទងនឹងអង្គហេតុដែលភាគីបានសារភាពចំពោះមុខតុលាការ នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៩៦ និង កថាខណ្ឌទី ២ នៃមាត្រា ១២៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី មិនត្រូវយកមកអនុវត្តឡើយ (កថាខណ្ឌទី ១ មាត្រា ១៣ នៃច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល)។ ដូច្នេះហើយ ទោះបីជាអង្គហេតុដែលគូភាគីមិនមានវិវាទក៏ដោយ ក៏តុលាការត្រូវតែទទួលស្គាល់ដោយផ្អែកតាមភស្តុតាងផងដែរ (កថាខណ្ឌទី ១ មាត្រា ១២៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

នៅក្នុងលិខិតសាលក្រមនៃបណ្ដឹងរដ្ឋប្បវេណីធម្មតា តុលាការបានសរសេរអំពី អង្គហេតុដែលមិនមែនជាចំណុចវិវាទ ពោលគឺ "អង្គហេតុដែលគ្មានវិវាទ" មុននឹងការសរសេរអំពី "ចំណុចវិវាទ" (ចំណុច ឃ កថាខណ្ឌទី ១ មាត្រា ១៨៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ ប៉ុន្តែ នៅក្នុងលិខិតសាលក្រមនៃបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល តុលាការត្រូវតែសរសេរអំពីដែលជាចំណុចវិវាទ និង អង្គហេតុដែលមិនមែនជាចំណុចវិវាទ ហើយត្រូវតែទទួលស្គាល់នូវអង្គហេតុទាំងពីរនេះដោយផ្អែកតាមភស្តុតាង។ ដូច្នេះ នៅក្នុងលិខិតសាលក្រមនៃបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល តុលាការនឹងសរសេរអំពី "អង្គហេតុដែលជាមូលដ្ឋានដើម្បីពិចារណាអំពីចំណុចវិវាទ" ដោយផ្អែកតាមភស្តុតាង។

[7] ក្នុងការចេញសាលក្រម តុលាការត្រូវវិនិច្ឆ័យទទួលស្គាល់ ឬ មិនទទួលស្គាល់ថា ការអះអាងអំពីអង្គហេតុ មាន ឬ គ្មានភាពពិត ដោយគិតពិចារណាយ៉ាងហ្មត់ចត់នូវលទ្ធផលនៃការពិនិត្យភស្តុតាង និង ដំណើរការនិងខ្លឹមសារនៃ

ខ.២.៣. ក្រោយពេលដែលបានចាប់ផ្តើមរួមរស់ជីវភាពជាមួយគ្នានិងដើមចោទ ចុងចម្លើយភាគច្រើនត្រឡប់មកផ្ទះវិញយប់ជ្រៅ។ **(ភស្តុតាង $X_5$ $Y_1$)**

ខ.២.៤. ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦ ដើមចោទ និង ចុងចម្លើយកើតបានកូនប្រុសឈ្មោះ សុក សុជាតិ (តទៅហៅថា "សុជាតិ")។ **(ភស្តុតាង $X_3$)**

ខ.២.៥. ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១៨ ដើមចោទ និង ចុងចម្លើយកើតបានកូនស្រីឈ្មោះ សុក សុជាតា (តទៅហៅថា "សុជាតា")។ **(ភស្តុតាង $X_4$)**

ខ.២.៦. ថ្ងៃទី ៤ ខែ មករា ឆ្នាំ ២០២០ ដើមចោទបាននាំសុជាតិ និង សុជាតា ត្រឡប់ទៅស្រុកកំណើតរបស់ខ្លួនវិញ។ **(ភស្តុតាង $X_6$)**

ខ.២.៧. នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកទី ១ ដែលត្រូវបានធ្វើឡើងនៅថ្ងៃទី ១២ ខែមិថុនា ឆ្នាំ ២០២០ ចុងចម្លើយបានឆ្លើយ (ឯកសារចម្លើយរបស់ចុងចម្លើយ) ថា "គ្មានមូលហេតុនៃការលែងលះគ្នាទេ" ប៉ុន្តែ នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកទី ២ ដែលត្រូវបានធ្វើឡើងនៅថ្ងៃទី ១ ខែកក្កដា ឆ្នាំ ២០២០ ចុងចម្លើយបានដកការឆ្លើយបែបនោះ និងបាននិយាយថា "ខ្លួនមិនមានឆន្ទៈបន្តអាពាហ៍ពិពាហ៍ជាមួយនិងដើមចោទតទៅទៀតទេ"។ នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកទី ២ ដើមចោទក៏បាននិយាយថា " ខ្លួនមិនមានឆន្ទៈបន្តអាពាហ៍ពិពាហ៍ជាមួយនិងចុងចម្លើយ" ដែរ ។ **(អង្គហេតុដែលមានភាពជាក់ស្តែងចំពោះតុលាការ[8])**

## ខ.៣. ចំណុចវិវាទ និង ការអះអាងរបស់គាគីចំពោះចំណុចវិវាទ

**នៅក្នុងរឿងក្តីនេះ ដើមចោទ និង ចុងចម្លើយបានលើកឡើងថា ភាគីទាំងសងខាងមិនមានឆន្ទៈបន្តអាពាហ៍ពិពាហ៍ទេ ហើយទំនាក់ទំនងអាពាហ៍ពិពាហ៍របស់ដើមចោទ និង ចុងចម្លើយត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបានទេ។ ដូច្នេះហើយ ដោយសារតែតុលាការទទួលស្គាល់អំពី**

ការទាញហេតុផលងដោយផ្ទាល់មាត់ តាមជំនឿទុកចិត្តដោយសេរីរបស់ខ្លួន (មាត្រា ១៨៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

[8] កថាខណ្ឌទី ២ មាត្រា ១២៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី និង កថាខណ្ឌទី ១ មាត្រា ១៣ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល។ នៅក្នុងនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល បើសិនជាអត្ថិភាពនៃអង្គហេតុនោះមានភាពជាក់ស្តែងចំពោះតុលាការនោះ តុលាការមិនចាំបាច់ទទួលស្គាល់ដោយផ្អែកតាមភស្តុតាងឡើយ។

មូលហេតុនៃការលែងលះគ្នាដែលមានចែងនៅក្នុងចំណុច ង កថាខណ្ឌទី ១ មាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណី ដូច្នេះ បណ្ដឹងទាមទារលែងលះរបស់ដើមចោទ គឺមានមូលហេតុ។

ហេតុនេះ ចំណុចវិវាទនៅក្នុងរឿងក្ដីនេះមានចំណុចដូចតទៅ៖

**ខ.៣.១. ការកំណត់អំពីអ្នកមានអំណាចមេបា**

**ខ.៣.១.១. ការអះអាងរបស់ដើមចោទ**

ក្រោយពេលកើតសុជាតិ និង សុជាតា ដើមចោទបានបីបាច់រក្សារូបកាយរបស់កូននីមួយៗយ៉ាងជាប់លាប់រហូតមក។ ក្រោយពេលដែលដើមចោទបានរស់នៅបែកគ្នាជាមួយចុងចម្លើយក៏ដោយ ក៏កូនទាំងពីរនាក់នេះបានរស់នៅជាមួយគ្នានិងដើមចោទ ហើយក៏បានធំលូតលាស់ផងដែរ។

ចំណែកឯចុងចម្លើយវិញ កន្លងមកនេះបានលើកហេតុផលថា ខ្លួនរវល់ខ្លាំង ហើយមិនបានចូលរួមក្នុងការមើលថែទាំកូនទាំងពីរ ហើយក៏មិនបានបីបាច់រក្សារូបកាយរបស់កូនទាំងពីរទាល់តែសោះ។

តុលាការសមតែកំណត់ដើមចោទធ្វើជាអ្នកមានអំណាចមេបាលើកូនទាំងពីរ។

**ខ.៣.១.២. ការអះអាងរបស់ចុងចម្លើយ**

ដើម្បីតែការងារភាគច្រើនចុងម្លើយបានត្រឡប់មកផ្ទះវិញយប់ជ្រៅ ប៉ុន្តែ បើទោះបីជាពេលវេលាមានកម្រិតក៏ដោយ ក៏នៅក្នុងពេលវេលាទាំងនោះ ចុងចម្លើយបានផ្ដល់នូវការថែទាំទៅសុជាតិ និង សុជាតាយ៉ាងសមរម្យផងដែរ។ ការរៀបចំកាដូគ្រិស្តម៉ាសដែលចុងចម្លើយបានធ្វើឡើងសម្រាប់កូនទាំងពីរជាដើម ក៏អាចឆ្លុះបង្ហាញឲ្យឃើញពីការផ្ដល់នូវការថែនេះផងដែរ។

ចំណែកឯដើមចោទវិញ បែរជាខឹងភ្លាមៗមួយរំពេច ហើយស្រែកខ្លាំងៗមកកាន់ចុងចម្លើយ ហើយក៏ជាមនុស្សមានសតិស្មារតីមិននឹងនរដែរ។ ដើមចោទមិនអាចចិញ្ចឹមបីបាច់កូនទាំងពីរឲ្យមានភាពត្រឹមត្រូវបានទេ។

តុលាការសមតែកំណត់ចុងចម្លើយធ្វើជាអ្នកមានអំណាចមេបាលើកូនទាំងពីរ។

**ខ.៣.២. បន្ទុកលើសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន (សោហ៊ុយចិញ្ចឹមបីបាច់កូន)**

### ខ.៣.២.១. ការអះអាងរបស់ដើមចោទ

បច្ចុប្បន្ននេះ ដើមចោទមិនមានប្រាក់ចំណូលទេ រីឯចុងចម្លើយវិញមានប្រាក់ចំណូលក្នុង ១ឆ្នាំ ប្រហែល ៧.០០០ ដុល្លារអាមេរិក។

ដូច្នេះហើយ ដើមចោទទាមទារឲ្យចុងចម្លើយទទួលបន្ទុកលើសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូនជាប្រាក់ចំនួន ១៥០ ដុល្លារអាមេរិកក្នុងកូន ១ នាក់ ( ២ នាក់ សរុបស្មើនឹង ៣០០ ដុល្លារអាមេរិក) ជារៀងរាល់ខែ ក្នុងអំឡុងគិតរហូតដល់កូនទាំងពីរក្លាយជានីតិជន ។

### ខ.៣.២.២. ការអះអាងរបស់ចុងចម្លើយ

ប្រសិនបើដើមចោទជាអ្នកមានអំណាចមេបាលើសុជាតិ និង សុជាតា ហើយគ្រប់គ្រងថែរក្សាកូនទាំងពីរនៅស្រុកកំណើតរបស់ដើមចោទ (នៅខេត្តបាត់ដំបង) នោះនឹងមានភាពខុសគ្នាពីការគ្រប់គ្រងថែរក្សាកូននៅក្នុងទីក្រុងភ្នំពេញ ដូច្នេះនឹងមិនមានការចំណាយសោហ៊ុយ ១៥០ ដុល្លារអាមេរិកក្នុងកូន ១ នាក់ នៅក្នុង ១ ខែឡើយ។ យ៉ាងច្រើនចុងចម្លើយទទួលបន្ទុក ១០០ ដុល្លារអាមេរិក ក្នុងកូន ១ នាក់នៅក្នុង ១ ខែ ( ២ នាក់ សរុបស្មើនឹង ២០០ ដុល្លារអាមេរិក) សម្រាប់ដើមចោទនោះនឹងមានភាពគ្រប់គ្រាន់។

## ខ.៣.៣. ការបង់អាហារកិច្ច

### ខ.៣.៣.១. ការអះអាងរបស់ដើមចោទ

ចំពោះទំនាក់ទំនងអាពាហ៍ពិពាហ៍របស់ ដើមចោទ និង ចុងចម្លើយ ដែលត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបាន គឺមិនមានកំហុសរបស់ដើមចោទទេ។ ដោយសារតែបច្ចុប្បន្ន ដើមចោទមិនមានប្រាក់ចំណូល ដូច្នេះហើយទើបទាមទារឲ្យចុងចម្លើយបង់អាហារកិច្ច។ ដោយផ្អែកលើប្រាក់ចំណូលរបស់ចុងចម្លើយក្នុង ១ ឆ្នាំ ប្រហែល ៧.០០០ ដុល្លារអាមេរិក និងរួមទាំងការសង្ឃឹមថាចុងចម្លើយនឹងទទួលបន្ទុកលើសោហ៊ុយចិញ្ចឹមបីបាច់កូន សុជាតិ និង សុជាតានោះ ចំនួនទឹកប្រាក់នៃអាហារកិច្ចសក្តិសមតែកំណត់ថាក្នុង ១ ខែ ១០០ ដុល្លារអាមេរិក។

### ខ.៣.៣.២. ការអះអាងរបស់ចុងចម្លើយ

ចំពោះទំនាក់ទំនងអាពាហ៍ពិពាហ៍របស់ដើមចោទ និង ចុងចម្លើយដែលត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបាន គឺដើមចោទក៏មានកំហុសដែរ មិនមែនមានតែចុងចម្លើយនោះទេ។ ចុងចម្លើយទទួលយកនូវការលែងលះគ្នាពីចុងចម្លើយ ប៉ុន្តែ មិនអាចទទួលយកនូវការបង់អាហារកិច្ចទេ។

### ខ.៣.៤. ការបែងចែកទ្រព្យសម្បត្តិ

#### ខ.៣.៤.១. ការអះអាងរបស់ដើមចោទ

រវាងដើមចោទ និង ចុងចម្លើយមានទ្រព្យសម្បត្តិរួមដូចបានកត់ត្រានៅក្នុង "បញ្ជីទ្រព្យសម្បត្តិរួម" នៃឧបសម្ព័ន្ធ។ ដើមចោទមានសិទ្ធិទទួលយក ១ ភាគ ២ នៃទ្រព្យសម្បត្តិនោះ។

ចំពោះដី L1 និង ដី L2 ដើមចោទទាមទារឲ្យលក់ដេញថ្លៃហើយយកប្រាក់ដែលបានពីការលក់នោះមកបែងចែកឲ្យទៅតាមចំណែក ដោយផ្អែកលើកម្មសិទ្ធិអវិភាគចំនួន ១ ភាគ ២ ដែលដើមចោទ និង ចុងចម្លើយម្នាក់ៗ មាន។

ចំពោះម៉ូតូនៃរឿងក្ដីនេះ បច្ចុប្បន្នដើមចោទកំពុងតែប្រើប្រាស់ ហើយវាក៏មានភាពចាំបាច់សម្រាប់ការទិញអីវ៉ាន់ប្រើប្រាស់ប្រចាំថ្ងៃ ដូច្នេះ ដើមចោទទាមទារយកមកធ្វើជាកម្មសិទ្ធិរបស់ដើមចោទ។

#### ខ.៣.៤.២. ការអះអាងរបស់ចុងចម្លើយ

ចុងចម្លើយទទួលស្គាល់ថា រវាងដើមចោទ និង ចុងចម្លើយមានទ្រព្យសម្បត្តិរួមដូចបានកត់ត្រានៅក្នុង "បញ្ជីទ្រព្យសម្បត្តិរួម" នៃឧបសម្ព័ន្ធ។ ដើមចោទមានសិទ្ធិទទួលយក ១ ភាគ ២ នៃទ្រព្យសម្បត្តិនោះ។ ប៉ុន្តែ ដីដែលបានកត់ត្រានៅក្នុងចំណុច ១. នៃឧបសម្ព័ន្ធ " បញ្ជីទ្រព្យសម្បត្តិរួម" (តទៅហៅថា "ដី L1") និងរថយន្តដែលបានកត់ត្រានៅក្នុងចំណុច ៣. នៃឧបសម្ព័ន្ធ "បញ្ជីទ្រព្យសម្បត្តិរួម" (តទៅហៅថា "រថយន្តនៃរឿងក្ដីនេះ") គឺមិនមែនជាទ្រព្យសម្បត្តិរួមសម្រាប់ធ្វើការធ្វើលទ្ធកម្មនោះទេ ទ្រព្យសម្បត្តិទាំងនោះគឺ ចុងចម្លើយមានតាំងពីមុនអាពាហ៍ពិពាហ៍ ហើយបាននិងកំពុងប្រើប្រាស់ជាទ្រព្យសម្បត្តិដោយឡែក។ នៅពេលដែលធ្វើការបែងចែកទ្រព្យសម្បត្តិរួមដែលបានកត់ត្រានៅក្នុងឧបសម្ព័ន្ធ "បញ្ជីទ្រព្យសម្បត្តិរួម" តុលាការគប្បីពិចារណាទៅលើទំហំនៃការបរិច្ចាគរបស់ចុងចម្លើយចំពោះលទ្ធកម្មនៃទ្រព្យសម្បត្តិទាំងនេះ ( "ទំហំនៃការបរិច្ចាគរបស់ភា

គឺនីមួយៗចំពោះលទ្ធកម្មនៃទ្រព្យសម្បត្តិ ការថែរក្សា ឬ ការបង្កើនទ្រព្យ" ចំណុច ខ កថាខណ្ឌទី ២ មាត្រា ៩៨០ នៃក្រមរដ្ឋប្បវេណី)។

ចំពោះដី L1 និង ដី L2 គឺត្រូវបានបង្កើតហ៊ីប៉ូតែកដើម្បីធានានូវកាតព្វកិច្ច ដោយសាមគ្គីភាពរវាងដើមចោទ និង ចុងចម្លើយ បន្ថែមពីនេះទៀត ដោយសារតែបច្ចុប្បន្ននេះដីទាំងពីរកំពុងតែបន្តឡើងថ្លៃ ហេតុនេះហើយ មិនគួរលក់ដេញថ្លៃនៅក្នុងពេលនេះទេ។ នាពេលបច្ចុប្បន្ននេះ រវាងដើមចោទ និងចុងចម្លើយមានចំណែកអវិភាគក្នុងម្នាក់ៗ ចំនួន ១ ភាគ ២ ដូច្នេះ ចាំពេលដែលកាតព្វកិច្ចបានសងរួចរាល់អស់ ហើយការចុះបញ្ជីបង្កើតហ៊ីប៉ូតែកត្រូវបានលុបចោលចាំធ្វើការពិចារណាអំពីវិធីបែងចែកទើបជាការប្រសើរ។

ចំពោះរថយន្តនៃរឿងក្ដីនេះ ចុងចម្លើយកំពុងតែប្រើប្រាស់សម្រាប់ទៅធ្វើការ ដូច្នេះ ចុងចម្លើយទាមទារធ្វើជាកម្មសិទ្ធិរបស់ចុងចម្លើយ។

## សំអាងហេតុ

## ក. ការវិនិច្ឆ័យចំពោះការកំណត់អំពីអ្នកមានអំណាចមេបា[9]

[9] " អំពីមូលដ្ឋាននៃការសម្រេចសេចក្ដីអំពីការកំណត់អ្នកមានអំណាចមេបា"

តុលាការត្រូវកំណត់អ្នកមានអំណាចមេបា ដោយពិចារណាទៅលើ "ផលប្រយោជន៍របស់កូន" (កថាខណ្ឌទី ៣ មាត្រា ១០៣៧ នៃក្រមរដ្ឋប្បវេណី)។

នៅពេលដែលតុលាការធ្វើការសម្រេចសេចក្ដីអំពីការកំណត់អ្នកមានអំណាចមេបា ឬ ការចាត់ចែងទាក់ទងនឹងការបីបាច់រក្សាកូន យោបល់របស់កូនត្រូវបានយកទៅពិចារណា ថ្លឹងថ្លែងសមស្របទៅតាមអាយុ និង សភាពចាស់ទុំរបស់កូននោះ(កថាខណ្ឌទី ៤ មាត្រា ២២ នៃច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល)។

រដ្ឋភាគី ត្រូវធានាអះអាងដល់កុមារដែលមានសមត្ថភាពបង្កើតទស្សនៈផ្ទាល់ខ្លួន នូវសិទ្ធិបញ្ចេញទស្សនៈទាំងនោះដោយសេរី លើគ្រប់បញ្ហាពាក់ព័ន្ធនឹងកុមារ។ ទស្សនៈទាំងនេះរបស់កុមារ ត្រូវបានយកទៅពិចារណាថ្លឹងថ្លែងដោយគិតទៅតាមវ័យ និងភាពចាស់ទុំរបស់កុមារ។ ក្នុងទិសដៅនេះ កុមារត្រូវបានផ្ដល់ជាពិសេសនូវឱកាសស្ដាប់នីតិវិធីតុលាការ និង រដ្ឋបាល ដែលពាក់ព័ន្ធនឹងកុមារ ទោះដោយផ្ទាល់ ឬ តាមរយៈតំណាងម្នាក់ ឬ ស្ថាប័នសមស្របមួយ ស្របតាមបទបញ្ញត្តិនីតិវិធីនៃច្បាប់ជាតិ ។ (មាត្រា ១២ នៃអនុសញ្ញាអន្តរជាតិស្ដីពី សិទ្ធិកុមារ) ។ បន្ថែមពីនេះ ប្រទេសកម្ពុជាបានចូលជាភាគីនៃអនុសញ្ញានេះកាលពីឆ្នាំ ១៩៩២។

"ផលប្រយោជន៍របស់កូន" អាចគិតទៅដល់ ① ស្ថានភាពរបស់ខាងឪពុក ឬ ម្ដាយ ② ស្ថានភាពរបស់កូន។ ① ស្ថានភាពរបស់ខាងឪពុក ឬ ម្ដាយ អាចមានដូចជា លទ្ធភាពក្នុងការគ្រប់គ្រងកូន (អាយុ និង ស្ថានភាពសុខភាពជាដើម) ស្ថានភាពសេដ្ឋកិច្ច (ប្រាក់ចំណូលប្រចាំឆ្នាំ មុខរបរ មាន ឬ គ្មានលំនៅដ្ឋានជាដើម) និងស្ថានភាពនៃការគ្រប់គ្រងកូន មាន ឬ គ្មានជំនួយពីសាច់ញាតិ ការផ្ដល់ក្ដីស្រលាញ់ចំពោះកូនជាអាទិ៍ ដែលធ្លាប់មានកន្លងមក ។ ② ស្ថានភាពរបស់កូន អាចមានដូចជា អាយុ ស្ថានភាពនៃការលូតលាស់រាងកាយ និង ចិត្តគំនិត ឆន្ទៈរបស់កូន ភាពស្អិតរមួតនៃចំណងរវាងឪពុកឬម្ដាយ និងសាច់ញាតិជាដើម។

## ក.១. ការទទួលស្គាល់អង្គហេតុ

អង្គហេតុដែលតុលាការបានទទួលស្គាល់តាមរយៈភស្តុតាងដូចបានកត់ត្រាគិតមកដល់ចំណុចចុងក្រោយខាងលើនេះ មានដូចតទៅ៖

**ក.១.១.** ដើមចោទ និង ចុងចម្លើយបង្កើតបានកូនឈ្មោះសុជាតិនៅថ្ងៃទី ១១ ខែសីហា ឆ្នាំ ២០១៦ និង សុជាតានៅថ្ងៃទី ២២ ខែកក្កដា ឆ្នាំ ២០១៨។ **(ភស្តុតាង $X_3$ $X_4$)**

**ក.១.២.** នៅថ្ងៃទី 4 ខែ មករា ឆ្នាំ ២០២០ ដើមចោទ បាននាំសុជាតិ និង សុជាតាត្រឡប់ទៅស្រុកកំណើតវិញ ហើយកំពុងតែស្នាក់នៅស្រុកកំណើតរួមគ្នាជាមួយនិងឪពុកម្ដាយរបស់ដើមចោទរហូតមកដល់បច្ចុប្បន្ននេះ។ **(ភស្តុតាង $X_6$)**

**ក.១.៣.** ក្នុងអំឡុងពេលដែលគិតមកដល់ពេលដើមចោទបានចាប់ផ្ដើមរស់នៅបែកគ្នាជាមួយចុងចម្លើយ ដើមចោទបានបន្តនូវការគ្រប់គ្រងសុជាតិ និង សុជាតាតែម្នាក់ឯង រួមទាំងពេលដែលចុងចម្លើយបានត្រឡប់មកផ្ទះវិញយប់ជ្រៅក៏ដោយ។ **(ភស្តុតាង $X_5$ $Y_1$ ដំណើរការ និង ខ្លឹមសារនៃការទាញហេតុផលដោយផ្ទាល់មាត់)**

**ក.១.៤.** ដោយសារតែដើមចោទមិនអាចទទួលបាននូវការចូលរួមសហការចំពោះការមើលថែទាំកូនពីចុងចម្លើយ ដូច្នេះហើយក៏ធ្លាប់បានធ្វើឲ្យមានការធ្វេសប្រហែសចំពោះការងារផ្ទះ និងធ្វើឲ្យមានជម្លោះពាក្យសម្ដីជាមួយចុងចម្លើយ ជាពិសេសគិតចាប់តាំងពីពេលដែលសុជាតាបានកើត។ **(ភស្តុតាង $X_5$ $Y_1$ លទ្ធផលនៃការសាកសួរសាមីដើមចោទ និងចុងចម្លើយនីមួយៗ)**

**ក.១.៥.** ..................................................................................................................

**ក.១.៦.** ..................................................................................................................

(សង្ខេប)

*※ នៅក្នុងរឿងក្ដីជាក់ស្ដែង គូភាគីទាំងសងខាងច្បាស់ជាមានការអះអាងយ៉ាងក្បោះក្បាយអំពីមូលហេតុដែលសក្ដិសមឲ្យខ្លួនអាចក្លាយទៅជាអ្នកមានអំណាចមេបា។*

*ក្នុងករណីដែលភាគីគ្រាន់តែអះអាងខ្លីៗដោយមូលហេតុបែបអត្តនោម័តថា ព្រោះ តែខ្លួនស្រលាញ់កូននោះ តុលាការចាំបាច់ត្រូវប្រើប្រាស់នូវសិទ្ធិស្រាយបំភ្លឺ ហើយឲ្យភាគីអះអាងអំពីមូលហេតុបែបសត្យានុម័តថា "តើហេតុអ្វីបានជាទាល់តែមានការមើលថែទាំកូនពីភាគីនោះទើបអាចមានលក្ខណៈវិជ្ជមានសម្រាប់កូនជាងគេ? ហេតុអ្វីបានជាភាគីម្ខាងទៀតមិនអាចធ្វើបាន?"*

*តុលាការចាំបាច់ត្រូវកំណត់អំពីអ្នកមានអំណាចមេបាដោយពិចារណាអំពីស្ថានភាពផ្សេងៗជាច្រើនដែលភាគីទាំងសងខាងបានអះអាង ហើយត្រូវគិតថាតើកំណត់យកឪពុក ឬ ម្ដាយធ្វើជាអ្នកមានអំណាចមេបាទើបអាចមាន "ផលប្រយោជន៍របស់កូន"។*

*ហើយ តុលាការត្រូវសរសេរអំពី អង្គហេតុដំបូងដើម្បីយកមកធ្វើការសម្រេចបែបនោះ និងភស្តុតាង ដាក់នៅក្នុងចំណុចចំហាទាំងនេះ។*

## **ក.២. សេចក្ដីសន្និដ្ឋាន**

ផ្អែកតាមការសរុបនូវអង្គហេតុដែលបានទទួលស្គាល់នៅក្នុងចំណុច "ក.១" ខាងលើ តុលាការទទួលស្គាល់ថា ក្រោយពេលដែលសុជាតិ និង សុជាតាកើតមក ដើមចោទបានគ្រប់គ្រងកូនទាំងពីររៀងរហូតមក ហើយក៏បានបន្តនូវការគ្រប់គ្រងនោះផងដែរបើទោះបីជាក្រោយពេលដែលបានរស់នៅបែកគ្នាជាមួយចុងចម្លើយក៏ដោយ។ ម្យ៉ាងទៀត តុលាការមិនទទួលស្គាល់ថា ស្ថានភាពនៃការគ្រប់គ្រងរបស់ដើមចោទទៅកាន់កូនទាំងពីរនេះ មិនមានបញ្ហាជាក់លាក់ណាមួយឡើយ។

យ៉ាងណាមិញ ចុងចម្លើយបានអះអាងថា ដើមចោទបានខឹងភ្លាមៗ ហើយស្រែកខ្លាំងៗទៅកាន់ចុងចម្លើយ ហើយជាមនុស្សដែលមានសតិមិននឹងនរ ដូច្នេះទើបដើមចោទមិនអាចចិញ្ចឹមបីបាច់កូនទាំងពីរឲ្យបានត្រឹមត្រូវទេ។ ជាការពិតណាស់ តុលាការទទួលស្គាល់ថា ដើមចោទធ្លាប់មានជម្លោះពាក្យសម្ដីជាមួយចុងចម្លើយ ។ ប៉ុន្តែ តុលាការក៏មិនអាចទទួលស្គាល់រហូតទៅដល់អង្គហេតុដែលដើមចោទអាចខឹង ហើយស្រែកដាក់សុជាតិ និង សុជាតានោះទេ ដូច្នេះហើយ តុលាការមិនអាចទទួលស្គាល់ថា ជម្លោះពាក្យសម្ដីរវាងចុងចម្លើយ គឺបានកើតឡើងដោយសារតែ

ដើមចោទមានស្មារតីមិននឹងនរ ហើយមូលហេតុនោះដោយសារតែដើមចោទមិនទទួលបានការសហការឲ្យបានពេញលេញពីចុងចម្លើយឡើយ។

ផ្ទុយមកវិញ ទោះជាយ៉ាងណាក៏ដោយ ក៏ចុងចម្លើយមានការស្រលាញ់ចំពោះកូនទាំងពីរ ប៉ុន្តែ ចុងចម្លើយមិនបង្ហាញឲ្យច្បាស់ថា តើខ្លួនចង់គ្រប់គ្រងថែរក្សាកូនទាំងពីរនេះជាក់ស្តែងដោយរបៀបណានោះទេ ខណៈពេលដែលភាគច្រើនខ្លួនបានត្រឡប់មកផ្ទះវិញយប់ជ្រៅដោយសារតែការងារ។

ដូច្នេះហើយ ផ្អែកតាមស្ថានភាពដែលដើមចោទកំពុងតែគ្រប់គ្រងកូនទាំងពីរនាក់ពេលបច្ចុប្បន្ននេះ គឺពុំមានបញ្ហាជាពិសេសណាមួយទេ ម្យ៉ាងទៀត ក៏មិនអាចនិយាយបានថា បើធ្វើការផ្លាស់ប្តូរស្ថានភាពនៃការគ្រប់គ្រងកូន ហើយកំណត់មកឲ្យចុងចម្លើយជាអ្នកមានអំណាចមេបាលើកូនទាំងពីរវិញ នឹងអាចធ្វើឲ្យក្លាយទៅជាប្រយោជន៍ដល់កូនទាំងពីរនោះបានដែរ ដូច្នេះហើយ គប្បីយកដើមចោទធ្វើជាអ្នកមានអំណាចមេបាទើបជាការប្រសើរ។

## ខ. ការវិនិច្ឆ័យចំពោះបន្ទុកលើសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន (សោហ៊ុយចិញ្ចឹមបីបាច់កូន)

### ខ.១. ការទទួលស្គាល់អង្គហេតុ

អង្គហេតុដែលតុលាការបានទទួលស្គាល់តាមរយៈភស្តុតាងដូចបានកត់ត្រាគិតមកដល់ចំណុចចុងក្រោយខាងលើនេះ មានដូចតទៅ៖

ខ.១.១. បច្ចុប្បន្ននេះ ដើមចោទគ្មានប្រាក់ចំណូល ។ **(លទ្ធផលនៃការសាកសួរសាមីដើមចោទ)**

ខ.១.២. ចុងចម្លើយកំពុងធ្វើការជាបុគ្គលិកក្រុមហ៊ុន ហើយមានប្រាក់ចំណូលក្នុង១ឆ្នាំ ប្រហែល ៧.០០០ ដុល្លារអាមេរិក។ **(លទ្ធផលនៃការសាកសួរសាមីចុងចម្លើយ)**

ខ.១.៣. ចុងចម្លើយត្រូវបង់ពន្ធប្រហែល...............ដុល្លារអាមេរិក ហើយបង់ថ្លៃឈ្នួលផ្ទះប្រហែល.............ដុល្លារអាមេរិកពីប្រាក់ចំណូលដែលបានកត់ត្រានៅក្នុងចំណុច "**ខ.១.២**" ខាងលើនេះ ។ **(លទ្ធផលនៃការសាកសួរសាមីចុងចម្លើយ)**

ខ.១.៤. កាលពីអំឡុងពេលដែលរស់នៅជុំគ្នាជាមួយសុជាតិ និង សុជាតានៅក្នុងលំនៅដ្ឋានរបស់ចុងចម្លើយ ចុងចម្លើយបានចំណាយសម្រាប់ថ្លៃជីវភាពរបស់កូនទាំងពីរចំនួន ៣.០០០ ដុល្លារអាមេរិក (ក្នុង ១ ខែ ប្រហែល ២៥០ ដុល្លារអាមេរិក) ពីចំនួនទឹកប្រាក់..................ដុល្លារអាមេរិកដែលបាននៅសល់បន្ទាប់ពីដកថ្លៃចំណាយក្នុងចំណុច "ខ.១.៣" ពីក្នុងប្រាក់ចំណូលនៃចំណុច "ខ.១.២" ខាងលើ។ **(លទ្ធផលនៃការសាកសួរសាមីដើមចោទ និង ចុងចម្លើយ)**

ខ.១.៥. បច្ចុប្បន្ននេះ ដើមចោទកំពុងតែគ្រប់គ្រងសុជាតិ និង សុជាតា នៅស្រុកកំណើតរបស់ដើមចោទ (ខេត្តបាត់ដំបង)។ **(ភស្តុតាង $X_6$)**

ខ.១.៦. ថ្លៃចំណាយសម្រាប់ជីវភាពនៅក្នុងខេត្តបាត់ដំបង ប្រហែលជាស្មើនឹង ៨០ % នៃថ្លៃចំណាយសម្រាប់ជីវភាពនៅក្នុងទីក្រុងភ្នំពេញ។ **(អង្គហេតុដែលមានភាពជាក់ស្តែងចំពោះតុលាការ)**

ខ.១.៧. ..........................................................................................................

(សង្ខេប)

*※ចំនួនទឹកប្រាក់នៃសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន (សោហ៊ុយចិញ្ចឹមបីបាច់កូន) ដំបូង ① ត្រូវកំណត់ជាបណ្តោះអាសន្នថា ហើយធ្វើការគណនាថា បើសិនជាកូនរស់នៅជុំគ្នាជាមួយអ្នកដែលទទួលបន្ទុក (ឪពុក ឬ ម្តាយដែលមិនមែនជាអ្នកមានអំណាចមេបា) តើចំណាយសម្រាប់ជីវភាពដែលត្រូវបានប្រើប្រាស់សម្រាប់កូននៅក្នុងករណីនេះអស់ចំនួនប៉ុន្មាន? ② យកចំនួនដែលបានគណនានេះ មកបែងចែកទៅតាមភាគរយនៃប្រាក់ចំណូលរបស់អ្នកទទួលបន្ទុក (ឪពុក ឬ ម្តាយដែលមិនមែនជាអ្នកមានអំណាចមេបា) និង អ្នកដែលទាមទារ (ឪពុក ឬ ម្តាយដែលជាអ្នកមានអំណាចមេបា) ។ នៅពេលនោះ ចំនួនទឹកប្រាក់ដែលបានមកពីការគណនាធៀបទៅនឹងភាគរយនៃប្រាក់ចំណូលរបស់អ្នកទទួលបន្ទុក នឹងក្លាយទៅជាសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន (សោហ៊ុយចិញ្ចឹមបីបាច់កូន) ដែលអ្នកទទួលបន្ទុកនោះត្រូវទទួលបន្ទុក។*

## ខ.២. សេចក្តីសន្និដ្ឋាន

តុលាការទទួលស្គាល់ថា ផ្អែកតាមខាងលើនេះ ប្រសិនបើកំណត់ជាបណ្តោះអាសន្នសិនថា បើចុងចម្លើយរស់ជុំគ្នានៅឯខេត្តបាត់ដំបងជាមួយសុជាតិ និង សុជាតា ចុងចម្លើយនឹងត្រូវចំណាយនូវថ្លៃជីវភាពចំនួនប្រហែល ២០០ ដុល្លារអាមេរិកក្នុង ១ ខែ សម្រាប់កូនទាំងពីរ (៨០% នៃចំនួន ២៥០ដុល្លារអាមេរិក) ។

ដូច្នេះ ចុងចម្លើយត្រូវទទួលបន្ទុកនូវប្រាក់ចំនួន ១០០ ដុល្លារអាមេរិកក្នុង១ខែ ចំពោះកូន ១ នាក់ ដែលជាសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូនទាំងពីរ (សោហ៊ុយចិញ្ចឹមបីបាច់កូន) ក្នុងអំឡុងពេលរហូតដល់កូនទាំងពីរនាក់ក្លាយជានីតិជន ។

# គ. ការវិនិច្ឆ័យចំពោះការបង់អាហារកិច្ច

## គ.១. ការទទួលស្គាល់អង្គហេតុ

**គ.១.១.** នៅក្នុងកាលបរិច្ឆេទនៃការត្រៀមសម្រាប់ការទាញហេតុផលលើកទី ២ ចុងចម្លើយបាននិយាយថា "មិនមានឆន្ទៈបន្តអាពាហ៍ពិពាហ៍ជាមួយដើមចោទតទៅទៀតទេ" ហើយនៅកាលបរិច្ឆេទដដែលនោះ ដើមចោទក៏បាននិយាយដែរថា "មិនមានឆន្ទៈបន្តអាពាហ៍ពិពាហ៍ជាមួយចុងចម្លើយតទៅទៀតទេ"។ **(អង្គហេតុដែលមានភាពជាក់ស្តែងចំពោះតុលាការ)**

**គ.១.២.** ចាប់តាំងពីក្រោយពេលដែលចុងចម្លើយបានរួមរស់ជីវភាពរួមគ្នា ជាមួយដើមចោទ ភាគច្រើនចុងចម្លើយបានត្រឡប់មកផ្ទះវិញយប់ជ្រៅ ហើយជាពិសេស នៅក្រោយពេលដែលបានកើតសុជាតារួចមក ចុងចម្លើយធ្លាប់បានមានជម្លោះពាក្យសម្តីរវាងដើមចោទជុំវិញការមើលថែរទាំកូន។ **(ភស្តុតាង $X_5$ ភស្តុតាង $Y_1$ លទ្ធផលនៃការសាកសួរសាមីដើមចោទ និង ចុងចម្លើយនីមួយៗ)**

## គ.២. សេចក្តីសន្និដ្ឋាន

ទំនាក់ទំនងអាពាហ៍ពិពាហ៍រវាងដើមចោទ និង ចុងចម្លើយត្រូវបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបាន គឺដោយសារតែភាគីទាំងសងខាងដែលជាដើមចោទ និង ចុងចម្លើយមិនមានឆន្ទៈបន្តអាពាហ៍ពិពាហ៍។ មិនតែ

ប៉ុណ្ណោះ ភាគីទាំងសងខាងមិនមានឆន្ទៈបន្តអាពាហ៍ពិពាហ៍ គឺដោយសារតែភាគីទាំងសងខាងមិនបានទំនាក់ទំនងនិយាយគ្នាឲ្យបានគ្រប់គ្រាន់តែប៉ុណ្ណោះទេ ថែមទាំងបណ្ដាលមកពីលទ្ធផលដែលដើមចោទមិនពេញចិត្តចំពោះចុងចម្លើយផងដែរ ដូច្នេះ គឺមិនអាចនិយាយបានថា ភាគីណាម្ខាងមានកំហុសតែម្នាក់ឯងបានទេ។

ហេតុនេះហើយ ដោយសារតែមិនអាចនិយាយឲ្យដាច់ស្រេចថា ដើមចោទមិនមានកំហុសចំពោះការលែងលះទេ ដូច្នេះហើយ តុលាការមិនអាចទទួលស្គាល់អំពីអាហារកិច្ចដែលដើមចោទទាមទារទៅកាន់ចុងចម្លើយទេ។

## ឃ. ការវិនិច្ឆ័យចំពោះការបែងចែកទ្រព្យសម្បត្តិ

### ឃ.១. ការទទួលស្គាល់អង្គហេតុ

**ឃ.១.១.** រវាងដើមចោទ និង ចុងចម្លើយ មានទ្រព្យសម្បត្តិរួមដែលបានកត់ត្រានៅក្នុងឧបសម្ព័ន្ធ "បញ្ជីទ្រព្យសម្បត្តិរួម"។ ម្យ៉ាងវិញទៀត ចំនួនទឹកប្រាក់នៃការវាយតម្លៃដែលបានធ្វើឡើងនៅពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់អំពីទ្រព្យសម្បត្តិរួមនីមួយៗ មានដូចតទៅ (**ភស្តុតាង** X7 X8 X9 X10 Y2 **លទ្ធផលនៃការសាកសួរសាមីដើមចោទ និង ចុងចម្លើយនីមួយៗ ដំណើរការ និង ខ្លឹមសារនៃការទាញហេតុផលដោយផ្ទាល់មាត់** )៖

| | |
|---|---|
| ដី L1 | ៦.០០០ ដុល្លារអាមេរិក |
| ដី L2 | ១០.០០០ ដុល្លារអាមេរិក |
| រថយន្តនៃរឿងក្ដីនេះ | ១០.០០០ ដុល្លារអាមេរិក |
| ម៉ូតូនៃរឿងក្ដីនេះ | ១.៥០០ ដុល្លារអាមេរិក |
| ប្រាក់សន្សំនៃរឿងក្ដីនេះ | ៤០០ ដុល្លារអាមេរិក |

យ៉ាងណាមិញ ចំពោះប្រាក់សន្សំនៃរឿងក្ដីនេះ នៅពេលដែលដើមចោទ និង ចុងចម្លើយបានចាប់ផ្ដើមរស់នៅបែកគ្នា (ថ្ងៃទី ៤ ខែមករា ឆ្នាំ ២០២០) នៅសល់ ៥០០ ដុល្លារអាមេរិក ប៉ុន្តែ ដោយសារតែចុងចម្លើយបានដកប្រាក់សន្សំអស់១ផ្នែក ដូច្នេះហើយ ចំនួនទឹកប្រាក់ដែលនៅសល់នៅ

ពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់មានចំនួន ៥០០ ដុល្លារអាមេរិក។

**ឃ.១.២.** ចំពោះដី L1 ដើមចោទ និង ចុងចម្លើយបានទិញនៅក្នុងតម្លៃទិញចូលចំនួន ៥.០០០ ដុល្លារអាមេរិក នៅក្នុងនោះមានប្រាក់ ១.០០០ ដុល្លារអាមេរិក (២០% នៃតម្លៃទិញចូល) ដែលបានដកចេញពីប្រាក់សន្សំដែលជាទ្រព្យសម្បត្តិដោយឡែករបស់ចុងចម្លើយ ហើយចំពោះប្រាក់ដែលខ្វះ ៤.០០០ ដុល្លារអាមេរិក ដើមចោទ និង ចុងចម្លើយបានធ្វើកម្ចីរួមគ្នាដោយសាមគ្គីភាព។ ដី L1 ត្រូវបានបង្កើតហ៊ីប៉ូតែកដើម្បីកម្ចីនេះ។ **(លទ្ធផលនៃការសាកសួរសាមីដើមចោទ និង ចុងចម្លើយនីមួយៗ)**

**ឃ.១.៣.** ចំពោះដី L2 ដើមចោទ និង ចុងចម្លើយបានទិញនៅក្នុងតម្លៃទិញចូលចំនួន ៨.០០០ ដុល្លារអាមេរិក នៅក្នុងនោះមានប្រាក់ដែលបានដកចេញពីប្រាក់សន្សំដែលជាទ្រព្យសម្បត្តិដោយឡែករបស់ដើមចោទ និង ចុងចម្លើយក្នុងម្នាក់ៗ ចំនួន ៨០០ ដុល្លារអាមេរិក (ម្នាក់ ១០ % នៃតម្លៃទិញចូល) ហើយចំពោះប្រាក់ដែលខ្វះ ៦.៤០០ ដុល្លារអាមេរិក ដើមចោទ និង ចុងចម្លើយបានធ្វើកម្ចីរួមគ្នាដោយសាមគ្គីភាព។ ដី L2 ត្រូវបានបង្កើតហ៊ីប៉ូតែកដើម្បីកម្ចីនេះ។ **(លទ្ធផលនៃការសាកសួរសាមីដើមចោទ និង ចុងចម្លើយនីមួយៗ)**

**ឃ.១.៤.** ចំពោះរថយន្តនៃរឿងក្ដីនេះ ដើមចោទ និង ចុងចម្លើយបានទិញនៅក្នុងតម្លៃ ១៥.០០០ ដុល្លារអាមេរិក នៅក្នុងនោះមានប្រាក់ចំនួន ៩.០០០ ដុល្លារអាមេរិក (៦០% នៃតម្លៃទិញចូល) គឺជាតម្លៃតបដែលទទួលបានពីការលក់រថយន្តដែលទ្រព្យសម្បត្តិដោយឡែករបស់ចុងចម្លើយ ហើយចំពោះប្រាក់ដែលខ្វះចំនួន ៦.០០០ ដុល្លារអាមេរិក ដើមចោទ និង ចុងចម្លើយបានដកចេញពីប្រាក់សន្សំដែលជាទ្រព្យសម្បត្តិរួម។ រថយន្តនៃរឿងក្ដីនេះ ចុងចម្លើយកំពុងតែប្រើប្រាស់។ **(លទ្ធផលនៃការសាកសួរសាមីដើមចោទ និង ចុងចម្លើយនីមួយៗ)**

**ឃ.១.៥.** ចំពោះម៉ូតូនៃរឿងក្ដីនេះ ដើមចោទ និង ចុងចម្លើយបានទិញនៅក្នុងតម្លៃ ២.០០០ ដុល្លារអាមេរិក នៅក្នុងនោះមានប្រាក់ចំនួន ១.៥០០ ដុល្លារអាមេរិក

(៧៥% នៃតម្លៃទិញចូល) គឺជាតម្លៃតបដែលទទួលបានពីការលក់ម៉ូតូដែលជាទ្រព្យសម្បត្តិដោយឡែករបស់ដើមចោទ ហើយចំពោះប្រាក់ដែលខ្វះចំនួន ៥០០ ដុល្លារអាមេរិក ដើមចោទ និង ចុងចម្លើយបានដកចេញពីប្រាក់សន្សំដែលជាទ្រព្យសម្បត្តិរួម។ ម៉ូតូនៃរឿងក្ដីនេះ ដើមចោទកំពុងតែប្រើប្រាស់។ **(លទ្ធផលនៃការសាកសួរសាមីដើមចោទ និង ចុងចម្លើយនីមួយៗ)**

## ឃ.២. ការវិនិច្ឆ័យ

**ឃ.២.១.** អំពីទ្រព្យសម្បត្តិដែលត្រូវក្លាយជាកម្មវត្ថុនៃការបែងចែកទ្រព្យសម្បត្តិ

ទ្រព្យសម្បត្តិដែលប្ដីប្រពន្ធទទួលបាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ជាគោលការណ៍នឹងត្រូវក្លាយជាទ្រព្យសម្បត្តិរួម (មាត្រា ៩៧៣ នៃក្រមរដ្ឋប្បវេណី) ហើយនៅក្នុងករណីដែលប្ដីប្រពន្ធលែងលះគ្នា សហព័ទ្ធនីមួយៗមានសិទ្ធិទទួលយក ១ ភាគ ២ នៃទ្រព្យសម្បត្តិរួម (ចំណុច ខ កថាខណ្ឌទី ២ មាត្រា ៩៨០ នៃក្រមរដ្ឋប្បវេណី)។ ការណ៍ដែលលើកឡើងបែបនេះគឺ ដោយសារតែប្ដីប្រពន្ធត្រូវរួមរស់ជីវភាពជាមួយគ្នា ហើយត្រូវសហការ សង្គ្រោះគ្នាទៅវិញទៅមក (មាត្រា ៩៦៦ នៃក្រមរដ្ឋប្បវេណី) ហេតុនេះគឺអាចមានការយល់ឃើញថា ទ្រព្យសម្បត្តិដែលប្ដីប្រពន្ធទទួលបាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ គឺជាទ្រព្យសម្បត្តិដែលប្ដីប្រពន្ធទទួលបានតាមរយៈការសហការគ្នារវាងប្ដីប្រពន្ធ ដូច្នេះ នៅពេលដែលប្ដីប្រពន្ធលែងលះគ្នា ក៏គប្បីយកទ្រព្យសម្បត្តិនេះមកជម្រះបញ្ជីផងដែរ។ ដូច្នេះ បើទោះបីជានៅមុនពេលដែលលែងលះគ្នាក៏ដោយ ក្នុងករណីដែលប្ដីប្រពន្ធមិនបានរួមរស់ជីវភាពជាមួយគ្នាបាត់ទៅហើយ ពោលគឺ បានរស់នៅបែកគ្នារួចហើយនោះ ទ្រព្យសម្បត្តិដែលប្ដីប្រពន្ធទទួលបាននៅក្នុងអំឡុងពេលរស់នៅបែកគ្នា គឺមិនអាចនិយាយថា ជាទ្រព្យសម្បត្តិដែលប្ដីប្រពន្ធទទួលបានតាមរយៈការសហការគ្នារវាងប្ដីប្រពន្ធបានទេ ដូច្នេះហើយទ្រព្យសម្បត្តិទាំងនោះ មិនគប្បីយកមកធ្វើជាកម្មវត្ថុនៃការបែងចែកទ្រព្យសម្បត្តិទេ។ម្យ៉ាងទៀត ជាមួយគ្នានេះ ទោះបីជាក្នុងករណីដែលប្ដី ឬ ប្រពន្ធណាម្ខាងបានប្រើប្រាស់ទ្រព្យ

សម្បត្តិរួមសម្រាប់ជីវភាពរបស់ខ្លួន នៅក្រោយពេលដែលបានរស់នៅបែកគ្នាក៏ដោយ ក៏មិនអាចនិយាយបានថា ករណីនោះគឺជាការយកមកប្រើប្រាស់សម្រាប់ការរួមរស់ជីវភាពជាមួយគ្នារបស់ប្តីប្រពន្ធបានដែរ ហេតុដូច្នេះហើយ ទើបចាំបាច់ត្រូវយកទ្រព្យសម្បត្តិនៅមុនពេលដែលត្រូវបានប្តី និង ប្រពន្ធប្រើប្រាស់សម្រាប់ជីវភាព មកធ្វើជាមូលដ្ឋាននៃការបែងចែកទ្រព្យសម្បត្តិ។ ជាពិសេស ទ្រព្យសម្បត្តិរួមដែលត្រូវក្លាយជាកម្មវត្ថុនៃការបែងចែក គួរតែជាទ្រព្យសម្បត្តិដែលប្តីប្រពន្ធទទួលបានគិតចាប់ពីពេលរៀបអាពាហ៍ពិពាហ៍រហូតដល់ពេលដែលរស់នៅបែកគ្នា។

នៅក្នុងរឿងក្តីនេះ នៅមុនពេលនៃការរស់នៅបែកគ្នា ប្រាក់សន្សំនៃរឿងក្តីនេះបាននៅសល់ចំនួន ៥០០ ដុល្លារអាមេរិក ប៉ុន្តែ ក្រោយមកដោយសារតែចុងចម្លើយបានដកយកប្រាក់សន្សំមួយផ្នែក ទើបធ្វើឲ្យចំនួនទឹកប្រាក់ដែលនៅសល់នៅពេលដែលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់មានចំនួន ៤០០ ដុល្លារអាមេរិក ហេតុនេះនៅពេលដែលធ្វើការបែងចែកទ្រព្យសម្បត្តិរវាងដើមចោទ និង ចុងចម្លើយ គប្បីយកចំនួនទឹកប្រាក់ ៥០០ ដុល្លារអាមេរិកដែលបាននៅសល់នៅពេលដែលរស់នៅបែកគ្នាដំបូងមកធ្វើជាមូលដ្ឋាន។

**ឃ.២.២.** អំពីតម្លៃនៃទ្រព្យសម្បត្តិដែលត្រូវក្លាយជាកម្មវត្ថុនៃការបែងចែកទ្រព្យសម្បត្តិ

ជាបឋម ចំពោះដី L1 មានការវាយតម្លៃជាទឹកប្រាក់ស្មើនឹងចំនួន ៦. ០០០ ដុល្លារអាមេរិក ដែលក្នុងនោះមានចំណែក ២០% ដែលស្មើនឹងទឹកប្រាក់ចំនួន ១.២០០ ដុល្លារអាមេរិក គឺជាផ្នែកដែលបានយកទ្រព្យសម្បត្តិដោយឡែករបស់ចុងចម្លើយមកធ្វើជាដើមទុន។ ដូច្នេះ ចំនួននៃផ្នែកនេះគប្បីក្លាយទៅជារបស់ចុងចម្លើយវិញ ហើយផ្នែកដែលនៅសល់ចំនួន ៤.៨០០ ដុល្លារអាមេរិក គប្បីក្លាយទៅជាកម្មវត្ថុនៃការបែងចែក។

ជាបន្តទៀត ចំពោះដី L2 មានការវាយតម្លៃជាទឹកប្រាក់ស្មើនឹងចំនួន ១០.០០០ ដុល្លារអាមេរិក ដែលក្នុងនោះមានចំណែក ១០ % ដែលស្មើនឹង ១.០០០ ដុល្លារអាមេរិក គឺជាផ្នែកដែលបានយកទ្រព្យសម្បត្តិដោយ

ឡៀករបស់ដើមចោទ និង ចំណែក ១០% ដែលស្មើនឹង១.០០០ ដុល្លារអាមេរិក គឺជាផ្នែកដែលបានយកទ្រព្យសម្បត្តិដោយឡៀករបស់ចុងចម្លើយ មកធ្វើជាដើមទុន។ ដូច្នេះ ចំនួននៃផ្នែកនេះគប្បីក្លាយទៅជារបស់ដើមចោទ និង ចុងចម្លើយនីមួយៗវិញ ហើយផ្នែកដែលនៅសល់ចំនួន ៩.០០០ ដុល្លារអាមេរិក គប្បីក្លាយទៅជាកម្មវត្ថុនៃការបែងចែក។

ចំពោះរថយន្តនៃរឿងក្តីនេះ មានការវាយតម្លៃជាទឹកប្រាក់ស្មើនឹង ចំនួន ១០.០០០ ដុល្លារអាមេរិកដែលក្នុងនោះមានចំណែក ៦០% ដែលស្មើនឹង ៦.០០០ ដុល្លារអាមេរិក គឺជាផ្នែកដែលបានយកទ្រព្យសម្បត្តិដោយឡៀករបស់ចុងចម្លើយមកធ្វើជាដើមទុន។ ដូច្នេះ ចំនួននៃផ្នែកនេះគប្បីក្លាយទៅជារបស់ចុងចម្លើយវិញ ហើយផ្នែកដែលនៅសល់ចំនួន ៤.០០០ ដុល្លារអាមេរិក គប្បីក្លាយទៅជាកម្មវត្ថុនៃការបែងចែក។

ចំពោះម៉ូតូនៃរឿងក្តីនេះ មានការវាយតម្លៃជាទឹកប្រាក់ចំនួន ១.៥០០ ដុល្លារអាមេរិក ដែលក្នុងនោះមានចំណែក ៧៥% ដែលស្មើនឹង ១.១២៥ ដុល្លារអាមេរិកគឺជាដើមទុនដែលបានយកមកពីទ្រព្យសម្បត្តិដោយឡៀករបស់ដើមចោទ។ ដូច្នេះហើយ ផ្នែកនៃទឹកប្រាក់នេះ គួរតែជារបស់ដើមចោទវិញ ហើយទឹកប្រាក់ដែលនៅសល់ចំនួន ៣៧៥ ដុល្លារអាមេរិក គួរតែយកទៅធ្វើជាកម្មវត្ថុនៃការបែងចែក។

ហេតុដូច្នេះហើយ តម្លៃរបស់ទ្រព្យសម្បត្តិដែលត្រូវក្លាយជាកម្មវត្ថុនៃការបែងចែក មានសរុបចំនួន ១៧.៦៧៥ ដុល្លារអាមេរិក ( ៤.៨០០ "ដី L1" + ៨.០០០ "ដី L2" + ៤.០០០ "រថយន្តនៃរឿងក្តីនេះ" + ៣៧៥ "ម៉ូតូនៃរឿងក្តីនេះ" +៥០០ "ប្រាក់សន្សំនៃរឿងក្តីនេះ" = ១៧.៦៧៥ )។

នៅពេលដែលយកចំនួនទឹកប្រាក់ខាងលើនេះមកបែងចែកឲ្យដើមចោទ និង ចុងចម្លើយក្នុងម្នាក់ៗ ១ ភាគ ២ ដូច្នេះនាំឲ្យដើមចោទ និង ចុងចម្លើយក្នុងម្នាក់ៗ មានសិទ្ធិទទួលបានចំនួនទឹកប្រាក់ ៨.៨៣៧,៥ ដុល្លារអាមេរិក ។

**ឃ.២.៣.** អំពីវិធីនៃការបែងចែកទ្រព្យសម្បត្តិ

ជាបឋម បើមើលទៅលើការបង្កើតហ៊ីប៉ូតែកចំពោះដី L1 និង ដី L2 ដើម្បីធានានូវកាតព្វកិច្ចដោយសាមគ្គីភាពរបស់ដើមចោទ និង ចុងចម្លើយ

គឺ ដីទាំងនេះមិនសក្តិសមយកមកធ្វើជាកម្មសិទ្ធិរបស់ ដើមចោទ ឬចុងចម្លើយតែម្នាក់ឯងទេ ដូច្នេះហើយ ដើមចោទ និង ចុងចម្លើយសក្តិសមតែមានកម្មសិទ្ធិអវិភាគក្នុងម្នាក់ៗ ចំនួន ១ ភាគ ២ ទៅលើដីនេះ។ ម្យ៉ាងទៀត តុលាការមិនទទួលស្គាល់ថា ក្នុងពេលបច្ចុប្បន្ននេះ គឺមានភាពចាំបាច់ដែលត្រូវយកដីនេះមកលក់ដោយបង្ខំភ្លាមៗទេ។ ដូច្នេះហើយ ចំពោះដី L1 នៅក្នុងចំណែកចំនួន ៤.៨០០ ដុល្លារអាមេរិកដែលត្រូវក្លាយជាកម្មវត្ថុនៃការបែងចែក នៅក្នុងនោះគឺដើមចោទគប្បីទទួលបានចំណែកចំនួន ៣.០០០ ដុល្លារអាមេរិក ហើយចុងចម្លើយគប្បីទទួលបានចំណែកចំនួន ១.៨០០ ដុល្លារអាមេរិក (បើបូកទាំងតម្លៃនៃចំនួន ១.២០០ ដុល្លារអាមេរិក ដែលយកទ្រព្យសម្បត្តិដោយឡែករបស់ចុងចម្លើយមកធ្វើជាដើមទុន ចំណែកដែលនឹងទទួលបានមានចំនួន៣០០០ ដុល្លារអាមេរិក) ។ ចំពោះដី L2 នៅក្នុងចំណែកចំនួន ៨.០០០ ដុល្លារអាមេរិកដែលត្រូវក្លាយជាកម្មវត្ថុនៃការបែងចែក នៅក្នុងនោះ គឺដើមចោទ និងចុងចម្លើយគប្បីទទួលបានចំណែករៀងៗខ្លួនចំនួន ៤.០០០ ដុល្លារអាមេរិក។

ចំពោះរថយន្តនៃរឿងក្តីនេះ គប្បីយកទៅធ្វើជាកម្មសិទ្ធិរបស់ចុងចម្លើយ ដូច្នេះហើយ ចំណែកទាំងអស់សរុបចំនួន ៤០០០ ដុល្លារអាមេរិកដែលត្រូវក្លាយជាកម្មវត្ថុនៃការបែងចែក គប្បីចុងចម្លើយជាអ្នកទទួលយក។

ចំពោះម៉ូតូនៃរឿងក្តីនេះ គប្បីយកទៅធ្វើជាកម្មសិទ្ធិរបស់ដើមចោទ ដូច្នេះហើយ ចំណែកទាំងអស់សរុបចំនួន ៣៧៥ ដុល្លារអាមេរិកដែលត្រូវក្លាយជាកម្មវត្ថុនៃការបែងចែក គប្បីដើមចោទជាអ្នកទទួលយក។

ចំពោះប្រាក់សន្សំនៃរឿងក្តីនេះ គប្បីយកទៅធ្វើជាកម្មសិទ្ធិរបស់ចុងចម្លើយដោយសារតែចុងចម្លើយជាម្ចាស់ឈ្មោះ។ ដូច្នេះ ចំណែកទាំងអស់សរុបចំនួន ៥០០ ដុល្លារអាមេរិកដែលត្រូវក្លាយជាកម្មវត្ថុនៃការបែងចែក គប្បីចុងចម្លើយជាអ្នកទទួលយក។

ហេតុដូច្នេះ ចំពោះតម្លៃរបស់ទ្រព្យសម្បត្តិដែលត្រូវក្លាយជាកម្មវត្ថុនៃការបែងចែកមានសរុបចំនួន ១៧.៦៧៥ ដុល្លារអាមេរិក ក្នុងនោះ ដើមចោទនឹងត្រូវទទួលបានចំនួន ៧.៣៧៥ ដុល្លារអាមេរិក ( ៣.០០០

"ដីL1" + ៤.០០០ "ដីL2" + ៣៧៥ "ម៉ូតូនៃរឿងក្តីនេះ" = ៧.៣៧៥ ) ហើយចុងចម្លើយទទួលបាន ១០.៣០០ ដុល្លារអាមេរិក (១.៨០០ "ដី L1" + ៤.០០០ "ដីL2" + ៤.០០០ "រថយន្តនៃរឿងក្តីនេះ" +៥០០ "ប្រាក់សន្សំនៃរឿងក្តីនេះ" = ១០.៣០០ ) ។

ហេតុនេះហើយ ចំពោះចំនួនទឹកប្រាក់ ១.៤៦២,៥ ដុល្លារអាមេរិក (៨.៨៣៧,៥ – ៧.៣៧៥ = ១.៤៦២,៥) ដែលមានគម្លាតខុសគ្នាពីចំនួនទឹកប្រាក់ចំនួន ៨.៨៣៧,៥ ដុល្លារអាមេរិកដែលដើមចោទអាចទទួលបានតាំងពីដើមនោះ គឺចុងចម្លើយចាំបាច់ត្រូវបង់ចំនួនទឹកប្រាក់ស្មើគ្នានេះឲ្យទៅដើមចោទ ដោយសារតែចំនួនដែលចុងចម្លើយនឹងត្រូវទទួលបានគឺ ៨.៨៣៧,៥ ដុល្លារអាមេរិក ប៉ុន្តែ ជាក់ស្តែង ចុងចម្លើយបានទទួលចំនួន ១០.៣០០ ដុល្លារអាមេរិក ដូច្នេះ ផ្នែកចំនួន ១.៤៦២,៥ ដុល្លារអាមេរិក (១០.៣០០ – ៨.៨៣៧,៥ = ១.៤៦២,៥ ) គឺជាចំនួនដែលទទួលបានលើស។

## ខ. សេចក្តីសន្និដ្ឋាន

ដូចបានរៀបរាប់ខាងលើនេះ ចំពោះដី L1 និង ដី L2 ដើមចោទ និង ចុងចម្លើយក្នុងម្នាក់ៗ មានចំណែក ១ ភាគ ២ ហើយរថយន្តនៃរឿងក្តីនេះជាកម្មសិទ្ធិរបស់ចុងចម្លើយ ហើយចំពោះម៉ូតូនៃរឿងក្តីនេះជាកម្មសិទ្ធិរបស់ដើមចោទ ហើយចុងចម្លើយត្រូវបង់ប្រាក់ឲ្យទៅដើមចោទចំនួន ១.៤៦២,៥ ទើបជាការសមរម្យ។

## ច. ស្តីពីបន្ទុកនៃប្រាក់ប្រដាប់ក្តី

ស្តីអំពីបន្ទុកនៃប្រាក់ប្រដាប់ក្តី តុលាការទទួលស្គាល់អំពីការទាមទាររបស់ដើមចោទ (បណ្តឹងទាមទារលែងលះគ្នា) ដោយសារតែនៅក្នុងនីតិវិធីបណ្តឹងទាំងចុងចម្លើយក៏បានអះអាងថា ខ្លួនមិនមានឆន្ទៈបន្តអាពាហ៍ពិពាហ៍ជាមួយដើមចោទដែរ ដូច្នេះ ហើយ មិនមែនមានន័យថាតុលាការបានទទួលស្គាល់អំពីមូលហេតុនៃការលែងលះដូចដើមចោទបានអះអាងនោះទេ។ ហេតុនេះ ចំពោះបន្ទុកនៃប្រាក់ប្រដាប់ក្តី ក៏គប្បីឲ្យភាគីដើមចោទដែលឈ្នះក្តីទទួលបន្ទុកមួយផ្នែកដែរ (កថាខណ្ឌទី ២ មាត្រា ៦៤ នៃ

ក្រមនីតិវិធីរដ្ឋប្បវេណី)។ ចំពោះភាគនៃបន្ទុកដែលត្រូវទទួលនោះ បើពិចារណាទៅលើសំអាងហេតុដែលតុលាការបានទទួលស្គាល់នូវការទាមទារ គប្បីឲ្យដើមចោទ និង ចុងចម្លើយទទួលបន្ទុកម្នាក់ៗចំនួន ១ ភាគ ២។

## សេចក្តីសម្រេចបញ្ចប់

១. លែងលះដើមចោទ និង ចុងចម្លើយ ។

២. កំណត់ថា ដើមចោទជាអ្នកមានអំណាចមេបាលើកូនប្រុសរវាងដើមចោទ និង ចុងចម្លើយដែលមានឈ្មោះ សុក សុជាតិ (កើតនៅថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦) ។

៣. កំណត់ថា ដើមចោទជាអ្នកមានអំណាចមេបាលើកូនស្រីរវាងដើមចោទ និង ចុងចម្លើយដែលមានឈ្មោះ សុក សុជាតា (កើតនៅថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១៨) ។

៤. បង្គាប់ឲ្យចុងចម្លើយបង់ប្រាក់ចំនួន ១00 ដុល្លារអាមេរិកក្នុង ១ ខែ ឲ្យទៅដើមចោទ គិតត្រឹមថ្ងៃចុងក្រោយជារៀងរាល់ខែ ក្នុងអំឡុងពេលគិតចាប់ពីថ្ងៃដែលសាលក្រមនេះចូលជាស្ថាពររហូតដល់ឈ្មោះ សុក សុជាតិ ដែលបានកត់ត្រានៅក្នុង **ចំណុច ២** ខាងលើនេះក្លាយជានីតិជន។

៥. បង្គាប់ឲ្យចុងចម្លើយបង់ប្រាក់ចំនួន ១00 ដុល្លារអាមេរិកក្នុង ១ ខែ ឲ្យទៅដើមចោទ គិតត្រឹមថ្ងៃចុងក្រោយជារៀងរាល់ខែ ក្នុងអំឡុងពេលគិតចាប់ពីថ្ងៃដែលសាលក្រមនេះចូលជាស្ថាពររហូតដល់ឈ្មោះ សុក សុជាតា ដែលបានកត់ត្រានៅក្នុង **ចំណុច ៣** ខាងលើនេះក្លាយជានីតិជន។

៦. បែងចែកទ្រព្យសម្បត្តិនីមួយៗ ដែលបានកត់ត្រានៅក្នុង "បញ្ជីទ្រព្យសម្បត្តិរួម" នៃឧបសម្ព័ន្ធ ដូចខាងក្រោមនេះ ៖

**ក.** ដីចំណុច ១. ដែលកត់ត្រានៅក្នុង "បញ្ជីទ្រព្យសម្បត្តិរួម" នៃឧបសម្ព័ន្ធជាកម្មសិទ្ធិអវិភាគរវាងដើមចោទ និង ចុងចម្លើយក្នុងចំណែកម្នាក់ៗចំនួន ១ ភាគ ២។

**ខ.** ដីចំណុច ២. ដែលកត់ត្រានៅក្នុង " បញ្ជីទ្រព្យសម្បត្តិរួម" នៃឧបសម្ព័ន្ធជាកម្មសិទ្ធិអវិភាគរវាងដើមចោទ និង ចុងចម្លើយក្នុងចំណែកម្នាក់ៗ ចំនួន ១ ភាគ ២ ។

គ. ឡានចំណុច ៣. ដែលបានកត់ត្រានៅក្នុង " បញ្ជីទ្រព្យសម្បត្តិរួម " នៃឧបសម្ព័ន្ធជាកម្មសិទ្ធិរបស់ចុងចម្លើយ។

ឃ. ម៉ូតូចំណុច ៤. ដែលបានកត់ត្រានៅក្នុង "បញ្ជីទ្រព្យសម្បត្តិរួម" នៃឧបសម្ព័ន្ធជាកម្មសិទ្ធិរបស់ដើមចោទ។

ង. ប្រាក់សន្សំចំណុច ៥. ដែលបានកត់ត្រានៅក្នុង " បញ្ជីទ្រព្យសម្បត្តិរួម " នៃឧបសម្ព័ន្ធជាកម្មសិទ្ធិចុងចម្លើយ។

ច. បង្គាប់ឲ្យចុងចម្លើយបង់ប្រាក់ចំនួន ១.៤៦២,៥ ដុល្លារអាមេរិកឲ្យទៅដើមចោទ។

៧. ច្រានចោលពាក្យសុំដែលដើមចោទទាមទារទៅចុងចម្លើយឲ្យបង់អាហារកិច្ច។

៨. ប្រាក់ប្រដាប់ក្តីចែកជា ២ ចំណែក ដោយ ១ ផ្នែកគឺជាបន្ទុករបស់ដើមចោទ ផ្នែកដែលនៅសល់គែជាបន្ទុករបស់ចុងចម្លើយ។

សាលក្រមនេះ ត្រូវបានប្រកាសនៅសវនការជាសាធារណៈ នៅថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០២០ ។ ក្នុងករណីដែលប្តឹងឧទ្ធរណ៍ ត្រូវតែធ្វើឡើងនៅក្នុងរយៈពេល ០១ (មួយ) ខែ គិតចាប់ពីថ្ងៃបានទទួលការបញ្ជូនលិខិតសាលក្រមនេះ។

ថ្ងៃព្រហស្បត្តិ៍ ទី២កើត ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ខេត្តបាត់ដំបង, ថ្ងៃទី ១២ ខែ សីហា ឆ្នាំ២០២០

**ចៅក្រម**

**ឧបសម្ព័ន្ធ**

## បញ្ជីទ្រព្យសម្បត្តិរួម

១. អចលនវត្ថុ

"ទីតាំងដី" ផ្លូវលេខ...... ភូមិ........ ឃុំ............ ស្រុក........ ខេត្តបាត់ដំបង

"លេខក្បាលដី" ..........

២. អចលនវត្ថុ

"ទីតាំងដី" ផ្លូវលេខ...... ភូមិ........ ឃុំ............ ស្រុក........ ខេត្តបាត់ដំបង

"លេខក្បាលដី" .........

៣. រថយន្ត

"ប្រភេទ" ទេសចរណ៍

"ម៉ាក" **LEXUS RX300**

"ពណ៌" ស

"កម្មសិទ្ធិករ" ចុងចម្លើយ

"អាសយដ្ឋាន" ផ្ទះលេខ 00 ផ្លូវ 00 សង្កាត់មនោរម្យ ខណ្ឌ៧មករា ភ្នំពេញ

"ផ្លាកលេខ" ......-........

៤. ម៉ូតូ

"ប្រភេទ" ស្រី

"ម៉ាក" **YAMAHA QBIX**

"ពណ៌" ខ្មៅ

"កម្មសិទ្ធិករ" ដើមចោទ

"អាសយដ្ឋាន" ផ្ទះលេខ 00 ផ្លូវ 00 សង្កាត់មនោរម្យ ខណ្ឌ៧មករា ភ្នំពេញ

"ផ្លាកលេខ" ......-........

៥. ប្រាក់សន្សំ

"ស្ថាប័នហិរញ្ញវត្ថុ" ធនាគារ...... សាខា........

"ប្រភេទ និង លេខគណនី" ប្រាក់សន្សំធម្មតា ××× ××× ×××

"ឈ្មោះម្ចាស់គណនី" ចុងចម្លើយ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

**លេខ៖** ....................

# លិខិតបញ្ជាក់ការចូលជាស្ថាពរនៃសាលក្រម

យើង ............................ ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

**-បានឃើញ** មាត្រា ២៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

**-បានឃើញ** សំណុំរឿងរដ្ឋប្បវេណី លេខ ..... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ... របស់សាលាដំបូងរាជធានីភ្នំពេញ។

**-បានឃើញ** សាលក្រមរដ្ឋប្បវេណី លេខ ..... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ... របស់សាលាដំបូងរាជធានីភ្នំពេញ។

**-បានឃើញ** របាយការណ៍អំពីការបញ្ជូន ចុះថ្ងៃទី ... ខែ ... ឆ្នាំ ... ស្តីពីការបញ្ជូនសេចក្តីចម្លងនៃសាលក្រមរដ្ឋប្បវេណី លេខ ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ... របស់សាលាដំបូងរាជធានីភ្នំពេញ បញ្ជាក់ថាដើមចោទឈ្មោះ ... បានទទួលនៅថ្ងៃទី ... ខែ ... ឆ្នាំ ... ។

**-បានឃើញ** ពាក្យសុំឱ្យបញ្ជាក់ការចូលស្ថាពរនៃសាលក្រម ចុះថ្ងៃទី ... ខែ ... ឆ្នាំ ... របស់លោក............ មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ ដែលមានខ្លឹមសារសុំបញ្ជាក់ការចូលជាស្ថាពរនៃសាលក្រមលេខ ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ... របស់សាលាដំបូងរាជធានីភ្នំពេញ។

## បញ្ជាក់ថា

**១**-សាលក្រមរដ្ឋប្បវេណី លេខ ..... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ... របស់សាលាដំបូងរាជធានីភ្នំពេញ បានចូលជាស្ថាពរគិតចាប់ពីថ្ងៃទី ... ខែ ... ឆ្នាំ... រួចហើយ។

**២**-លិខិតបញ្ជាក់ការចូលជាស្ថាពរនៃសាលក្រមនេះ ចេញឱ្យសាមីខ្លួនដើម្បីយកទៅប្រើប្រាស់តាមច្បាប់។

ថ្ងៃ........... ខែ.......... ឆ្នាំ..... ... ស័ក ព.ស. .......
រាជធានីភ្នំពេញ ថ្ងៃទី ........ ខែ ........ ឆ្នាំ..........

**ក្រឡាបញ្ជី**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**<u>សាលាដំបូងរាជធានីភ្នំពេញ</u>**

**លេខ៖** ...................

# រូបមន្តអនុវត្តសាលក្រម

យើង ............................ ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

**-បានឃើញ** មាត្រា ៣៥៤, ៣៥៥, ៣៥៧ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០០៦ ។

**-បានឃើញ** សំណុំរឿងរដ្ឋប្បវេណី លេខ ..... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ... របស់សាលាដំបូងរាជធានីភ្នំពេញ។

**-បានឃើញ** សាលក្រមរដ្ឋប្បវេណី លេខ ..... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ... របស់សាលាដំបូងរាជធានីភ្នំពេញ។

**-បានឃើញ** ពាក្យសុំរូបមន្តអនុវត្តសាលក្រម ចុះថ្ងៃទី ... ខែ ... ឆ្នាំ ... របស់លោក............ មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទឈ្មោះ...........................។

**សូមបញ្ជាក់អំពីខ្លឹមសារនៃការអនុវត្តដូចខាងក្រោម៖**

**ម្ចាស់បំណុល៖** ឈ្មោះ .............. មានទីលំនៅបច្ចុប្បន្នស្ថិតនៅផ្ទះ...... ផ្លូវ......... សង្កាត់............. ខណ្ឌ................. ខេត្ត/រាជធានី.........។

**អាចអនុវត្តដោយបង្ខំ៖** តាមអំណាចសាលក្រមរដ្ឋប្បវេណីលេខ ........ ចុះថ្ងៃទី ... ខែ ... ឆ្នាំ ... ត្រង់ចំណុចទី .... នៃសេចក្តីសម្រេចបញ្ចប់។

**កូនបំណុល៖** ឈ្មោះ .............. មានទីលំនៅបច្ចុប្បន្នស្ថិតនៅផ្ទះ...... ផ្លូវ......... សង្កាត់............. ខណ្ឌ................. ខេត្ត/រាជធានី.........។

*សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកស្ថាប័នអនុវត្ត ឱ្យសម្រេចតាមសាលក្រមស្ដាពរនេះ និងឱ្យអាជ្ញាធរសាធារណៈ ជួយអនុវត្តសាលក្រមនេះ បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។*

ថ្ងៃ........... ខែ.......... ឆ្នាំ..... ... ស័ក ព.ស. .......
រាជធានីភ្នំពេញ ថ្ងៃទី ........ ខែ ........ ឆ្នាំ..........

**ក្រឡាបញ្ជី**